សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ ២០១៦

# លីអាហូណា

## រឿងអំពីព្រះយេស៊ូវ ៖ ការដកស្រង់សំខាន់ៗពីការប្រកួតរូបគំនូរជាអន្តរជាតិលើកទី ១០ ទំព័រ ២២

ការរៀបចំដួងចិត្ត និង គេហដ្ឋានរបស់អ្នកសម្រាប់ការយាងត្រលប់មកវិញរបស់ព្រះអង្គសង្គ្រោះ ទំព័រ ១០

អែលឌើរ បាឡឺដ មានប្រសាសន៍ស្ដីពីការអប់រំក្នុងសាសនាចក្រនៅក្នុងសតវត្សរ៍ទី ២១នេះ ទំព័រ ២៨

សេចក្ដីជំនឿរបស់ឪពុកម្ដាយខ្ញុំ ៖ ជនភៀសខ្លួនមកពីប្រទេសឆេកូស្លូវ៉ាគី ទំព័រ ៣៦





*« ហេតុដូច្នោះហើយ អស់អ្នកណាជឿដល់ព្រះ អាចសង្ឃឹមជាប្រាកដថា នឹងបានពិភពលោកមួយដ៏ប្រសើរលើសលែងទៅទៀត មែនហើយ គឺកន្លែងមួយដែលនៅខាងស្តាំព្រះហស្តនៃព្រះ ឯសេចក្តីសង្ឃឹមនោះកើតមកពីសេចក្តីជំនឿ ធ្វើជាយុថ្កាមួយដល់ព្រលឹងមនុស្ស ដែលនឹងធ្វើឲ្យពួកគេស្ថិតស្ថេរនៅនឹងធឹង ហើយខ្ជាប់ខ្ជួន គឺនៅក្នុងកិច្ចការល្អដ៏បរិបូរជាដរាប ដែលនាំឲ្យសរសើរតម្កើងដល់ព្រះ »*

**អេធើរ ១២:៤**

# លីអាហូណា ខែ ធ្នូ ឆ្នាំ ២០១៦



៤

## សារលិខិត


**៤** **សារលិខិតគណៈប្រធានទីមួយ: ភាពសុខសាន្តនៅក្នុងជីវិតនេះ**
ដោយប្រធាន ហិនរី ប៊ី អាវរិង

**៧** **សារលិខិតបង្រៀនសួរសុខទុក្ខ: អំណរនៃក្រុមគ្រួសារគឺមាននៅក្នុងសេចក្ដីសុចរិត**


## អត្ថបទពិសេសៗ


**១០** **ការរៀបចំកន្លែងមួយសម្រាប់ព្រះអម្ចាស់**
ដោយ ប៊ីស្សព ហ្គែរ៉ល កូសសេ
*យើងម្នាក់ៗមានកាតព្វកិច្ចរៀបចំខ្លួនសម្រាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ ។*

**១៤** **អំណាចនៃព្រះគុណរបស់ព្រះ**
ដោយ អែលឌើរ ជេម ជេ ហាមូឡា
*ពួកយើងទាំងអស់គ្នាត្រូវការព្រះគុណរបស់ព្រះអម្ចាស់ ។ នេះជារបៀបប្រាំមួយយ៉ាង ដែលយើងអាចទទួលបានអំណាចដែលអាចធ្វើបាននេះ ។*

**២២** **ការប្រកួតរូបគំនូរជាអន្តរជាតិលើកទី ១០ ៖ សូមប្រាប់ខ្ញុំពីរឿងព្រះយេស៊ូវ**
*សូមរីករាយនឹងរូបគំនូររបស់ព្រះអង្គសង្គ្រោះទាំង ១៦ ដែលបានជ្រើសរើស ។*

**២៨** **ដោយការសិក្សា និងដោយសេចក្ដីជំនឿ**
ដោយអែលឌើរ អិម សែុល បាឡឹដ
*វាតម្រូវឲ្យមានទាំងការសិក្សា និង សេចក្ដីជំនឿដើម្បីឲ្យការសិក្សាដំណឹងល្អមានប្រសិទ្ធភាព ហើយគ្រូបង្រៀនដើរតួយ៉ាងសំខាន់នៅក្នុងការជួយសិស្សឲ្យធ្វើចំណុចទាំងពីរនេះបញ្ចូលគ្នា ។*

**៣៦** **ភៀសខ្លួនស្វែងរកសេចក្ដីជំនឿ និង សេរីភាព**
ដោយ អ៊ីវ៉ា វែលប៊ើរហ្គើរ
*នៅក្នុងការរត់គេចរបស់ពួកគាត់ដើម្បីរកសេរីភាព នោះឪពុកម្ដាយរបស់ខ្ញុំបានឃើញពរជ័យនានានៃដំណឹងល្អតាមរបៀបជាច្រើន ។*


## ផ្នែកនានា


**៨** **ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ: ការប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ**
ដោយ ដេវិន ជី ឌើរ៉ាន់

**៤០** **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០** **លុះត្រាជួបទៀត: និស្ស័យដ៏ពិតនៃព្រះ**
ដោយ អែលឌើរ ដែហ្វ្រី អ័រ ហូឡិន




**នៅលើក្របមុខ**
ខាងមុខ ៖ ដកស្រង់ចេញពី ចូរយើងទៅថ្វាយបង្គំទ្រង់ ដោយ ដាណា ម៉ារីអូ រ៉ូត ទទួលបានសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ ហាមថតចម្លង ។ ខាងក្នុងគម្របមុខ ៖ រូបថតមកពី iStock/Thinkstock ។

## យុវមជ្ឈិមវ័យ





**៤៤ សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ៖ គុណធម៌ដែលវេញត្របាញ់ចូលគ្នា**
ដោយអែលឌើរ ឈី ហុង (សាំ ) វ៉ុង
*នៅពេលសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និង សេចក្ដីសប្បុរសវេញត្របាញ់បញ្ចូលគ្នា អាចជួយយើងឲ្យក្លាយទៅជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទកាន់តែល្អប្រសើរឡើង ។*

**៤៨ ការបង្កើតឲ្យមានជីវិតដ៏រីករាយដែលគ្មានទីបញ្ចប់**
ដោយ យូរី ខូតេពូវ
*ខ្ញុំបានតាំងចិត្តថារៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ហើយព្រះអម្ចាស់បាននាំខ្ញុំឲ្យជួបនឹងដៃគូអស់កល្បជានិច្ចរបស់ខ្ញុំ តាមរបៀបមួយដែលនឹងស្មានមិនដល់ ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្នកចែកចាយពរជ័យដំណឹងល្អជាមួយអ្នកដទៃទៀតតាមរបៀបណា ?***

## យុវវ័យ


**៥០ ភាពរឹងមាំដើម្បីជ្រើសរើស**
ដោយ ម៉ែខល ភីកខែត
*ក្ដីសុបិនរបស់ខ្ញុំ—ក្លាយជាកីឡាករកាយវប្បកម្មអាជីព—គឺនៅនឹងមុខរបស់ខ្ញុំហើយ ។ ចុះបែបបទបេសកកម្មដែលខ្ញុំទើបតែដាក់បញ្ជូនទៅនោះ ?*

**៥២ ចូរធ្វើជាវីរបុរសដ៏ពិត**
ដោយ ឆាឡុត ឡាកាបាល
*ឈានទៅមុខមានន័យថា ជាការចេញទៅធ្វើសកម្មភាព ទោះបីជារឿងនោះហាក់បីដូចជាគួរឲ្យខ្លាច ឬ ពុំប្រាកដប្រជាក្ដី ។*

**៥៦ សំណួរ និង ចម្លើយ**
*ខ្ញុំមានការលំបាកក្នុងការសិក្សាព្រះគម្ពីរ ។ ហេតុអ្វីវាសំខាន់ដើម្បីសិក្សាព្រះគម្ពីរ ?*

**៥៨ ការផ្ដល់ឲ្យដែលលើសពីអំណោយទៅទៀត**
ដោយ អែមម៉ាលីន អ័រ វីលសុន
*តើអំណោយអ្វីខ្លះ ដែលអ្នកនឹងចែកឲ្យគេ នារដូវបុណ្យគ្រីស្ទម៉ាសនេះ ? ចូរមើលថា តើអ្នកចង់ធ្វើជាអ្នកបរិច្ចាគបែបណា ដោយធ្វើលំហាត់នេះ ។*

**៦១ ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនាដែលខ្ញុំត្រូវការ**
ដោយ កាព្រីយ៉េល ខុស្តា ស៊ីលវ៉ា
*ខ្ញុំមានភាពឯកោ ហើយត្រូវការមិត្តភក្តិ ប៉ុន្តែខ្ញុំពុំធ្លាប់ស្រមៃថា អ្នកផ្សព្វផ្សាយសាសនាគឺជាចម្លើយចំពោះការអធិស្ឋានរបស់ខ្ញុំទេ ។*

**៦២ ប័ណ្ណប្រកាស: ចូរកុំពន្យារពេល**

**៦៣ ចម្លើយមកពីថ្នាក់ដឹកនាំសាសនាចក្រ: របៀបអត់ធ្មត់**
ដោយ ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ





## កុមារ





**៦៤ បុណ្យគ្រីស្ទម៉ាស់ដ៏ប្លែកមួយ**
ដោយ ជេន ម៉ាកប្រាយដ៍ ធូត
*អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្ដូរចាប់តាំងពីការលែងលះគ្នាមក ។ តើបុណ្យគ្រីស្ទម៉ាស់នៅតែជាគ្រាដែលសប្បាយដែរឬទេ ?*

**៦៦ កុមារដែលឈររឹងប៉ឹង: ពរជ័យមកពីប្លេះស៊ី**

**៦៨ វីរបុរសក្នុងព្រះគម្ពីរមរមន: ការអញ្ជើញរបស់មរ៉ូណៃ**

**៦៩ ខ្ញុំអាចអានព្រះគម្ពីរមរមន**

**៧០ ចម្លើយមកពីសាវក: តើខ្ញុំអាចមានអារម្មណ៍កាន់តែខិតជិតព្រះអង្គសង្គ្រោះតាមរបៀបណា ?**
ដោយ អែលឌើរ ឌេល ជី រេនឡាន់

**៧១ កាតសាក្សីពិសេស**

**៧៥ ទំព័ររបស់យើង**

**៧៦ រឿងចេញពីព្រះគម្ពីរមរមន: ការសន្យាដ៏ពិសេសរបស់មរ៉ូណៃ**

**៧៩ ទំព័រផាត់ពណ៌: ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ**

**ខែ តុលា ឆ្នាំ ២០១៦ ភាគ ៤០ លេខ ១០៤**
**លីអាហូណា 13292 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូប៊ឺត ឌី ហេល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌែល ជី រេនឡាន់

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការអ្នកកែសម្រួល ៖** ជេមស៍ ប៊ី ម៉ាទីណូ, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រេន ខេ អាស្តុន, រ៉នដល អេ បិនណ្ណិត, ក្រេក អេ ខារដុន, ឆារិល អេ អេសព្លិន, គ្រីស្តូហ្វែល ហ្គូលឌិន, ដូហ្គ្លាស ឌី ហូលមែស, ល៉ែរី អរ ឡរិន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** ភីធើរ អេហ្វ អ៊ីវ៉ាន
**នាយកគ្រប់គ្រងប្រតិបត្តិការ ៖** វិនសិន អេ វ៉ូន
**នាយកគ្រប់គ្រងទស្សនាវដ្ដីសាសនាចក្រ ៖** អាឡែន អ័រ ឡយបិហ្គ
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ វ៉ាល ចនសុន
**ជំនួយការការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខា
**ជំនួយការបោះពុម្ព ៖** មេហ្គេន វើរហើហ្វ ស៊ីស្ស
**និពន្ធ និងកែសម្រួលដោយ ៖** ប្រ៊ឺតចានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាថាយ ឌី ហ្វ៊ីតតុន, ឡារី ហូល៉េរ, ហ្គារ៉េត អេច ហ្គាហ្វ, ឡាប៉ែន ផតទើរ ហ្គាន, ជីល ហាកឃឹង, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរីក ប៊ី មើរដុក សាលី ចនសុន អូដេឃឹក, យ៉ូស្វេ ជេ ភឺគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី អាន សេលូ, ប៉ុល វ៉ានឌិនប៊ើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ថេដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, វ៉ាជែល ស្មីធ ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡហ្វ្រ៊ីន, ស្កុត អិម ម៉ូយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហ្វ៊ីស
**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលេត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ហ្គេន អារ៉ោរ, ខន្នី ប៊ីវទួប ប្រ៊ីច, ជូលី ប៊ឺដេត, ខេទី ដានខាន, ប្រែអិន ដ័បុលយូ ជីជី, ជីន្នី ជេ និលសុន, ហ្គែល ធេត រ៉ាហ្វីធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ស្ទីវិន ធី ឡេវីស
**នាយកផ្នែកចែកចាយ ៖** ស្ទីវិន អ័រ គ្រីស្ទានសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វ៊ីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2016 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
December 2016 Vol. 15 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់នានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



« **ការរៀបចំកន្លែងមួយសម្រាប់ព្រះអម្ចាស់** » ទំព័រ ១០ ៖ ប៊ីស្សព ហ្គែរ៉ល កូសសែ រំឭកអំពីការទទួលខុសត្រូវរបស់យើងដើម្បីរៀបចំសម្រាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ ។ របៀបមួយដើម្បីរៀបចំកន្លែងមួយសម្រាប់ព្រះអម្ចាស់ គឺជួយមនុស្សដែលត្រូវការផ្ទះរស់នៅ ។ សូមគិតពីការស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលដែលមើលថែអ្នកដែលគ្មានផ្ទះ ប្រមូលសម្ភារផ្គត់ផ្គង់នានាជូនដល់ជនភៀសខ្លួន បង្កើនការបង់ប្រាក់ទៅក្នុងមូលនិធិជំនួយមនុស្សធម៌របស់សាសនាចក្រ ឬ ចុះប្រឡូកនឹងសកម្មភាពបម្រើនានានៅក្នុងសហគមន៍របស់អ្នក ។ អ្នកក៏អាចពិភាក្សាផងដែរអំពីរបៀបឃ្វូរអង្វែងទៅមុខទៀត ដែលអ្នកអាចបម្រើដល់អ្នកដែលគ្មានទីជម្រក ដូចជាបង្កើននូវមិត្តភាពជាដើម ។

« **តើខ្ញុំអាចមានអារម្មណ៍កាន់តែខិតជិតព្រះអង្គសង្គ្រោះតាមរបៀបណា ?** » ទំព័រ ៧០ ៖ ប្រាកដណាស់ ព្រះយេស៊ូវគ្រីស្ទគឺជាបុព្វហេតុសម្រាប់រដូវកាលនេះ ប៉ុន្តែអ្នកអាចពិចារណាពីរបៀបនានា ដែលអ្នកអាចចងចាំពីគំរូរបស់ព្រះអង្គសង្គ្រោះពេញមួយឆ្នាំ ។ អ្នកអាចគិតពីរបៀបនានាដើម្បីបង្កើតគេហដ្ឋានមួយដែលផ្ដោតលើព្រះយេស៊ូវគ្រីស្ទកាន់តែខ្លាំង ដូចជាដាក់តាំងរូបភាពរបស់ព្រះអង្គសង្គ្រោះនៅក្នុងផ្ទះរបស់អ្នក ទន្ទេញខគម្ពីរអំពីព្រះអង្គសង្គ្រោះរៀងរាល់សប្ដាហ៍ ឬ យកចិត្តទុកដាក់កាន់តែខ្លាំងលើការរៀបចំខ្លួនសម្រាប់ថ្ងៃឈប់សម្រាក ។ សូមដាក់ផែនការអនុវត្តយោបល់របស់អ្នក ហើយកត់ពីរបៀបដែលការខិតខំនោះ បានជួយឲ្យអ្នកខិតកាន់តែជិតព្រះគ្រីស្ទ នៅក្នុងសៀវភៅទិនានុប្បវត្តិរបស់អ្នក ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើរណែត

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។ សូមមើលគេហទំព័រ **facebook.com/liahona.magazine** ( ដែលមានជាភាសាអង់គ្លេស ភាសាព័រទុយហ្គាល់ និង ភាសាអេស្ប៉ាញ ) ដើម្បីរកសារលិខិតដ៏បំផុសគំនិតនានា គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ និងឯកសារដែលអ្នកអាចចែកចាយជាមួយមិត្តភក្តិ និង គ្រួសាររបស់អ្នក ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺ តំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការបង្រៀន, ៧, ២៨*
*ការបម្រើ, ១០, ៥៨, ៦១, ៦៤, ៨០*
*ការយាងមកជាលើកទីពីរ, ១០*
*ការលែងលះ, ៦៤*
*ការសាកល្បង, ៤, ៤០, ៤៣, ៦១*
*ការសិក្សាព្រះគម្ពីរ, ២៨, ៥៦, ៦៩*
*ការអត់ធ្មត់, ៤៨, ៦៣*
*ការអធិស្ឋាន, ៤៨, ៦១*
*កិច្ចការផ្សព្វផ្សាយសាសនា, ៣៦, ៤១, ៤៤, ៥០, ៦១, ៦៦*
*កុមារ, ៤២, ៦៤, ៦៦, ៧៥*
*ក្រុមគ្រួសារ, ៧, ៤០, ៦៤, ៧៩*
*ជនភៀសខ្លួន, ១០, ៣៦*
*ថ្នាក់សាលាថ្ងៃអាទិត្យ, ៨, ២៨*
*ទីបន្ទាល់, ២៨*
*បុណ្យគ្រីស្ទម៉ាស់, ១០, ៤០, ៤១, ៤២, ៤៣, ៥៨, ៦២, ៦៤, ៦៦, ៦៩, ៧០, ៧៥*
*ពិធីសាក្រាម៉ង់, ៤*
*ពួកសាវក, ៧១*
*ព្យាការី, ៧១, ៧៦*
*ព្រះគម្ពីរមរមន, ៤១, ៥២, ៦៨, ៧៦*
*ព្រះគុណ, ១៤*
*ព្រះយេស៊ូវគ្រីស្ទ, ១៤, ២២, ៤២, ៤៤, ៥៨, ៦២, ៦៩, ៧០, ៨០*
*ព្រះវិញ្ញាណបរិសុទ្ធ, ៤*
*ព្រះវិហារបរិសុទ្ធ, ១០, ៣៦, ៤៨*
*ភាពសុខសាន្ត, ៤*
*សេចក្ដីជំនឿ, ១៤, ២៨, ៣៦, ៤៤, ៤៨, ៥០, ៥២*
*សេចក្ដីសប្បុរស, ៤៤*
*សេចក្ដីសុចរិត, ៧*
*សេចក្ដីសង្ឃឹម, ៣៦, ៤៤*
*អាទិភាព, ៨, ៥០*
*អាពាហ៍ពិពាហ៍, ២៨, ៤៨*
*អ្នកត្រួសត្រាយ, ៣៦*



**ប្រធាន ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# ភាពសុខសាន្ត
## នៅក្នុងជីវិតនេះ

ចំពោះពួកយើងទាំងអស់គ្នា ដែលកើតមកក្នុងជីវិតរមែងស្លាប់នេះ ព្រះអង្គសង្គ្រោះមានបន្ទូលថា « នៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្ដីវេទនាមែន » ( យ៉ូហាន ១៦:៣៣ ) ។ ប៉ុន្តែទ្រង់បានប្រទានការសន្យាដ៏អស្ចារ្យនេះដល់ពួកសិស្សរបស់ទ្រង់ អំឡុងពេលការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ៖ « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ » ( យ៉ូហាន ១៤:២៧ ) ។ វាជាការលួងលោមចិត្តមួយដោយដឹងថា ការសន្យានៃភាពសុខសាន្តផ្ទាល់ខ្លួននេះបន្តមានដល់ពួកសិស្សរបស់ទ្រង់នាសព្វថ្ងៃនេះ ។

ពួកយើងមួយចំនួនរស់នៅក្នុងបរិយាកាសដ៏ស្រស់ស្អាត និង មានភាពសុខសាន្ត ប៉ុន្តែយើងកំពុងជួបប្រទះនូវភាពចលាចលផ្ទាល់ខ្លួនរបស់យើង ។ មានអ្នកខ្លះទទួលអារម្មណ៍សុខសាន្ត និង ភាពស្ងប់សុខក្នុងអំឡុងពេលនៃការបាត់បង់ សោកនាដកម្ម និង ការសាកល្បងដែលមានជាបន្តបន្ទាប់ផ្ទាល់ខ្លួន ។

អ្នកប្រហែលជាធ្លាប់ឃើញអព្ភូតហេតុនៃភាពសុខសាន្តនៅលើទឹកមុខសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ឬ ស្ដាប់ឮពាក្យនោះពីពួកគាត់ ។ ខ្ញុំបានឃើញអព្ភូតហេតុនោះជាច្រើនដង ។ ជួនកាលខ្ញុំបានឃើញវាកើតឡើងនៅក្នុងបន្ទប់មន្ទីរពេទ្យ ជាកន្លែងដែលអ្នកបម្រើរបស់ព្រះបានមកជួបជុំគ្នានៅជុំវិញគ្រួសារមួយដែលមានមនុស្សហៀបនឹងស្លាប់ ។

ខ្ញុំចាំពីការទៅសួរសុខទុក្ខស្ត្រីម្នាក់នៅក្នុងមន្ទីរពេទ្យ ពីរបីថ្ងៃពីមុនគាត់បានចែកឋានទៅ ដោយសារជំងឺមហារីក ។ ខ្ញុំបាននាំកូនស្រីខ្ញុំពីរនាក់ទៅជាមួយខ្ញុំដែរ ដោយសារស្ត្រីដ៏អស្ចារ្យនោះធ្លាប់ធ្វើជាគ្រូបឋមសិក្សារបស់ពួកគេ ។

សមាជិកគ្រួសាររបស់គាត់បានជួបជុំគ្នាជុំវិញគ្រែដេករបស់គាត់ ដោយចង់នៅជាមួយគាត់អំឡុងគ្រាចុងក្រោយនៃជីវិតរបស់គាត់នៅលើផែនដីនេះ ។ ខ្ញុំមានការភ្ញាក់ផ្អើលដោយសារគាត់បានក្រោកអង្គុយនៅលើគ្រែ ។ គាត់បានឈោងដៃទៅរកកូនស្រីខ្ញុំ ហើយបានណែនាំកូនស្រីទាំងពីរនាក់របស់ខ្ញុំឲ្យសមាជិកគ្រួសារគាត់ស្គាល់ម្នាក់ម្ដងៗ ។ គាត់បាននិយាយដូចជាកូនស្រីរបស់ខ្ញុំទាំងពីរជាពូជស្ដេចដែលកំពុងមានវត្តមាននៅឯព្រះរាជវាំងរបស់ម្ចាស់ក្សត្រី ។ គាត់បាននិយាយពីរបៀបដែលបុគ្គលម្នាក់ៗនៅក្នុងបន្ទប់នោះគឺជាសិស្សរបស់ព្រះអង្គសង្គ្រោះ ។ ខ្ញុំនៅចាំពីពាក្យសម្ដីដ៏រឹងប៉ឹង សុភាពទន់ភ្លន់ និង មានក្ដីស្រឡាញ់របស់គាត់ ។ ហើយខ្ញុំនៅចាំពីភាពអស្ចារ្យចំពោះស្នាមញញឹមដ៏រីករាយរបស់គាត់ ទោះបីជាគាត់បានដឹងថាគាត់នឹងជិតស្លាប់ក្ដី ។

គាត់បានទទួលការប្រសិទ្ធពរបព្វជិតភាពនៃការលួងលោម ប៉ុន្តែគាត់បានថ្លែងទីបន្ទាល់ដោយក្ដីសោមនស្សដល់ពួកយើងទាំងអស់គ្នាថា ការសន្យារបស់ព្រះអង្គសង្គ្រោះអំពីភាពសុខសាន្តនោះគឺជាការពិត ៖ « ខ្ញុំប្រាប់សេចក្ដីទាំងនេះដើម្បីឲ្យអ្នករាល់គ្នា បានសេចក្ដីសុខសាន្ត ។ ដោយសារខ្ញុំ នៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្ដីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកិយហើយ » ( យ៉ូហាន ១៦:៣៣ ) ។

គាត់បានទទួលយកការអញ្ជើញរបស់ទ្រង់ ជាអ្វីដែលពួកយើងអាចធ្វើបានផងដែរ ទោះបីជាយើងមានការសាកល្បង និង មានក្ដីអំពល់យ៉ាងណាក្ដី ៖

« អស់អ្នកដែលនឿយព្រួយ និងមានបន្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានកន្លែងសម្រាក។

« ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្ដីសម្រាកដល់ព្រលឹង » ( ម៉ាថាយ ១១:២៨–២៩ ) ។

មានតែតាមរយៈការធ្វើតាមព្រះអង្គសង្គ្រោះប៉ុណ្ណោះ ដែលយើងម្នាក់ៗអាចជួបនូវភាពសុខសាន្ត និង ភាពស្ងប់សុខនៅក្នុងការសាកល្បងនានាដែលនឹងកើតឡើងចំពោះរូបយើងនោះ ។

ពាក្យអធិស្ឋានសាក្រាម៉ង់ជួយយើងឲ្យដឹងពីរបៀប ដើម្បីស្វែងរកភាពសុខសាន្តនៅក្នុងអំឡុងពេលនៃសេចក្ដីទុក្ខលំបាកក្នុងជីវិតនេះ ។ នៅពេលយើងទទួលទានសាក្រាម៉ង់ យើងអាចកំណត់ពីភាពស្មោះត្រង់ចំពោះសេចក្ដីសញ្ញារបស់យើង ដើម្បីធ្វើតាមទ្រង់ ។

យើងម្នាក់ៗសន្យាថាចងចាំព្រះអង្គសង្គ្រោះ ។ អ្នកអាចជ្រើសរើសចងចាំទ្រង់



តាមរបៀបមួយដែលចិត្តរបស់អ្នកខិតកាន់តែជិតទ្រង់បំផុត ។ ចំពោះរូបខ្ញុំ ជួលកាល ក្នុងគំនិតខ្ញុំស្រមៃឃើញទ្រង់លុតជង្គង់ចុះនៅក្នុងច្បារគែតសេម៉ានី ឬឃើញទ្រង់ហៅ ឡាសារ ឲ្យចេញមកពីផ្នូរ ។ នៅពេលខ្ញុំមានអារម្មណ៍បែបនោះ ខ្ញុំកាន់តែមានអារម្មណ៍ជិតស្និទ្ធនឹងទ្រង់ និងមានក្ដីកតញ្ញូតា ដែលធ្វើឲ្យចិត្តខ្ញុំមានភាពសុខសាន្ត ។

អ្នកក៏សន្យាថា រក្សាបទបញ្ញត្តិរបស់ទ្រង់ដែរ ។ អ្នកសន្យាថា លើកដាក់មកលើខ្លួនអ្នកនូវព្រះនាមរបស់ទ្រង់ ហើយធ្វើជាសាក្សីទ្រង់ ។ ទ្រង់សន្យាថា នៅពេលអ្នករក្សាសេចក្ដីសញ្ញារបស់អ្នកជាមួយទ្រង់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយអ្នក ។ ( សូមមើល គ. និង ស. ២០:៧៧, ៧៩ ) ។

យ៉ាងហោចណាស់ការធ្វើបែបនេះ នាំឲ្យមានភាពសុខសាន្តតាមរបៀបពីរយ៉ាង ។ ព្រះវិញ្ញាណបរិសុទ្ធសម្អាតយើងពីអំពើបាប ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ហើយព្រះវិញ្ញាណបរិសុទ្ធអាចប្រទានភាពសុខសាន្តដល់យើង ដែលកើតមកពីការអនុម័តរបស់ព្រះ និង សេចក្ដីសង្ឃឹមនៃជីវិតអស់កល្បជានិច្ច ។

សាវកប៉ុលបានមានប្រសាសន៍អំពីពរជ័យដ៏អស្ចារ្យនេះ ៖ « តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាពសប្បុរស ស្មោះត្រង់ » ( កាឡាទី ៥:២២ ) ។

នៅពេលសារទូតរបស់ស្ថានសួគ៌បានប្រាប់ឲ្យដឹងជាមុនអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ នោះពួកគេបានប្រកាសថា « សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយ *សេចក្ដីសុខសាន្ត* នៅផែនដីនៅបណ្ដាលមនុស្ស » ( លូកា ២:១៤ ការគូសបញ្ជាក់បានបន្ថែម ) ។ ខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំក្នុងនាមជាសាក្សីមួយរូបរបស់ព្រះយេស៊ូវគ្រីស្ទថា ព្រះវរបិតា និង បុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់ អាចបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ ដើម្បីធ្វើឲ្យយើងអាចជួបនូវភាពសុខសាន្តនៅក្នុងជីវិតនេះ មិនថាការសាកល្បងបែបណាដែលនឹងកើតឡើងចំពោះយើង និង មនុស្សដែលយើងស្រឡាញ់នោះឡើយ ។ ■

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន អាវរិងបង្រៀនថា ពាក្យអធិស្ឋានសាក្រាម៉ង់អាចជួយយើងឲ្យដឹងពីរបៀបស្វែងរកភាពសុខសាន្តអំឡុងពេលនៃការសាកល្បងរបស់យើង ។ ពាក្យទាំងនោះរំឭកយើងថា នៅពេលពួកយើងរក្សាសេចក្ដីសញ្ញារបស់យើង នោះយើងទទួលបានការសន្យារបស់ព្រះដែលថា ព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយពួកយើង ។ សូមគិតពីការសួរអស់អ្នកដែលអ្នកបង្រៀន ពីរបៀបដែលការមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើង អាចជួយយើងឲ្យមានភាពសុខសាន្ត ។ អ្នកក៏អាចចែកចាយគំនិត ឬ បទពិសោធន៍របស់អ្នក អំពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកឲ្យទទួលអារម្មណ៍សុខសាន្តនៅអំឡុងពេលនៃការសាកល្បង ។ អ្នកអាចលើកទឹកចិត្តដល់អស់អ្នកដែលអ្នកបង្រៀនឲ្យសញ្ជឹងគិតពីសារលិខិតនេះអំឡុងពេលពិធីសាក្រាម៉ង់នាសប្ដាហ៍នេះ ។



## តើអ្នកនឹងចងចាំព្រះអង្គសង្គ្រោះដោយរបៀបណានាសប្ដាហ៍នេះ ?

ប្រធាន អារវិង លើកទឹកចិត្តពួកយើងឲ្យ « ជ្រើសរើសចងចាំ [ ព្រះអង្គសង្គ្រោះ ] តាមរបៀបមួយដែលធ្វើឲ្យចិត្តរបស់អ្នកខិតកាន់តែជិតទ្រង់បំផុត » ។

តើអ្នក « ចងចាំទ្រង់ជានិច្ច » ពេញមួយសប្ដាហ៍ដោយរបៀបណា ( សូមមើល គ. និង ស. ២០:៧៧, ៧៩ ? )

តើអ្នកមានខគម្ពីរដែលអ្នកពេញចិត្តអំពីព្រះអង្គសង្គ្រោះដែរឬទេ ? អ្នកអាចគូសចំណាំខគម្ពីរផ្សេងៗរៀងរាល់ថ្ងៃនាសប្ដាហ៍នេះ ហើយចែកចាយខគម្ពីរនោះជាមួយមនុស្សម្នាក់ទៀត ។

តើអ្នកច្រៀងទំនុកតម្កើង ឬ បទចម្រៀងលើកស្ទួយដួងចិត្តណាមួយនៅក្នុងចិត្តដែរឬទេ ពេលអ្នកកំពុងកើតទុក្ខនោះ ? ប្រហែលជាអ្នកអាចជ្រើសយកបទចម្រៀងមួយដែលផ្ដោតជាពិសេសអំពីព្រះអង្គសង្គ្រោះនាសប្ដាហ៍នេះ ។

តើអ្នកសញ្ជឹងគិតអំពីព្រះជន្ម និង ពលិកម្មដ៏ធួនរបស់ព្រះអង្គសង្គ្រោះអំឡុងពេលពិធីសាក្រាម៉ង់រៀងរាល់សប្ដាហ៍ដែរឬទេ ? អ្នកអាចរៀបចំខ្លួនសម្រាប់ពីធីសាក្រាម៉ង់ ដោយរំឭកពីជម្រើសនានារបស់អ្នកពេញមួយសប្ដាហ៍ ដើម្បីចងចាំព្រះអង្គសង្គ្រោះជានិច្ច ហើយប្រែចិត្តនៅពេលអ្នកមានការពិបាកនឹងចងចាំទ្រង់ ។

តើអ្នកអធិស្ឋានទូលសូមឱកាស ដើម្បីចែកចាយដំណឹងល្អរៀងរាល់ថ្ងៃដែរឬទេ ? សូមព្យាយាមពិភាក្សាអំពីដំណឹងល្អក្នុងសប្ដាហ៍នេះ ដែលផ្ដោតលើព្រះអង្គសង្គ្រោះ ។ អ្នកអាចថ្លែងទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះ អំឡុងពេលរាត្រីជួបជុំក្រុមគ្រួសារ ឬ និយាយប្រាប់មិត្តភក្តិនៅសាលារៀនអំពីបទពិសោធន៍ ដែលអ្នកមាននៅព្រះវិហារ ។

សូមដាក់គោលដៅដើម្បីចងចាំព្រះអង្គសង្គ្រោះតាមរបៀបដ៏ពិសេសមួយនាសប្ដាហ៍នេះ ។ សូមប្រាប់ឪពុកម្ដាយ បងប្អូនបង្កើត អ្នកដឹកនាំ ឬ មិត្តភក្តិអំពីគោលដៅរបស់អ្នក ។ នៅចុងសប្ដាហ៍ សូមប្រាប់ពួកគេអំពីអ្វីដែលបានកើតឡើង ។ អ្នកនឹងមានទាំងអារម្មណ៍សុខសាន្ត និង សុភមង្គល ដែលប្រធានអារវិងបានមានប្រសាសន៍នោះ ។



## មកឯព្រះគ្រីស្ទ

ព្រះអង្គសង្គ្រោះបានសន្យាផ្ដល់ភាពសុខសាន្តដល់យើង នៅពេលយើង « មកឯ [ ទ្រង់ ] » ( ម៉ាថាយ ១១:២៨ ) ។ នេះមានន័យថា ការធ្វើតាមគំរូរបស់ទ្រង់ និង ការព្យាយាមនៅជិតទ្រង់ ។ សូមកាត់ប័ណ្ណនេះ ហើយព្យួរវានៅកន្លែងដែលអ្នកនឹងមើលឃើញវាញឹកញាប់ ។ តើមានរបៀបណាផ្សេងទៀតដែលអ្នកអាចមករកព្រះគ្រីស្ទ ?

- មានគារវភាពអំឡុងពេលពិធីសាក្រាម៉ង់ ។
- ជ្រើសយកការមានចិត្តសប្បុរស ហើយមិនវិនិច្ឆ័យអ្នកដទៃ ។
- អានព្រះគម្ពីរអំពីព្រះអង្គសង្គ្រោះ ។
- ______________________
  ______________________
  ______________________
- ______________________
  ______________________
  ______________________



គំនូរព្រាងដោយ ខេស៊ី ណេលសិន

*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន និងស្វែងរកការបំផុសគំនិត ដើម្បីដឹងពីអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » បង្កើនជំនឿរបស់អ្នកទៅលើព្រះ ហើយផ្ដល់ពរដល់អ្នកទាំងឡាយដែលអ្នកថែទាំតាមរយៈការបង្រៀនសួរសុខទុក្ខយ៉ាងដូចម្ដេច ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# អំណរនៃក្រុមគ្រួសារ គឺមាននៅក្នុង សេចក្ដីសុចរិត

ព្រះ « បានស្ថាបនាក្រុមគ្រួសារ ដើម្បីនាំយកសុភមង្គលមកឲ្យយើង ដើម្បីជួយយើងរៀនគោលការណ៍ដ៏ត្រឹមត្រូវ នៅក្នុងបរិយាកាសដ៏កក់ក្ដៅមួយ និង ដើម្បីរៀបចំយើងសម្រាប់ជីវិតដ៏អស់កល្បជានិច្ច » ។[១] ប្រធាន រ័សុល អិម ណិលសុន ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ស្ដីពី « ផែនការនៃសុភមង្គលដ៏មហិមា » របស់ព្រះ ( អាលម៉ា ៤២:៨ ) នោះដូចនេះ ៖ « ផែនការរបស់ទ្រង់បានប្រកាសថា មានបុរស និង ស្ត្រី ‹ ដើម្បីឲ្យគេអាចមានសេចក្ដីអំណរ › [ នីហ្វៃទី ២ ២:២៥ ] ។ អំណរនោះកើតឡើងនៅពេលយើងជ្រើសរើសរស់នៅស្របតាមផែនការអស់កល្បជានិច្ចរបស់ព្រះ » ។[២]

គេហដ្ឋានមួយដែលផ្ដោតលើព្រះគ្រីស្ទផ្ដល់ឱកាសដ៏អស្ចារ្យសម្រាប់ភាពជោគជ័យ ។ អែលឌើរ រីឆាដ ជី ស្កុត ( ឆ្នាំ ១៩២៨–២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ពិពណ៌នាពីគេហដ្ឋានថាជាកន្លែងមួយ « ដែលដំណឹងល្អត្រូវបានបង្រៀន រក្សាសេចក្ដីសញ្ញា និង ពោរពេញដោយក្ដីស្រឡាញ់ » ជាកន្លែងដែលក្រុមគ្រួសារអាចរស់នៅ « ក្នុងជីវិតដែលគោរពប្រតិបត្តិ » ហើយប្រែជា « ចាក់ឫសយ៉ាងមាំនៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ។[៣]

ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ដូចនេះ ៖



« យើងអាចសម្រេចចិត្តថា យើងនឹងធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីនាំយកព្រះចេស្ដានៃស្ថានសួគ៌ចូលមកក្នុងគ្រួសារ [ របស់យើង ] » ។ ហើយយើងទំនងជាជំរុញឲ្យមានសេចក្ដីស្រឡាញ់ ការបម្រើ ការគោរពប្រតិបត្តិ និង សុភមង្គលនៅក្នុងគេហដ្ឋានរបស់យើងដោយសារ « [ កូនៗរបស់យើង ] ស្ដាប់ព្រះបន្ទូលរបស់ព្រះ ហើយពួកគេសាកល្បងវាដោយសេចក្ដីជំនឿ ។ ប្រសិនបើពួកគេធ្វើបែបនោះ លក្ខណៈសម្បត្តិរបស់ពួកគេនឹងផ្លាស់ប្ដូរក្នុងរបៀបមួយដែលបង្កើតនូវសុភមង្គលដែលពួកគេស្វែងរក » ។[៤]

### *បទគម្ពីរបន្ថែម*

យ៉ូហានទី ៣ ១:៤; នីហ្វៃទី ១ ៨:១២; នីហ្វៃទី ២ ៥:២៧

### សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ

### *គេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ*

យើងមានគំរូនៃគេហដ្ឋានដែលផ្ដោតលើព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរ ។ បន្ទាប់ពីឪពុករបស់លោកគឺ លីហៃបានស្លាប់ទៅ នោះនីហ្វៃបាននាំគ្រួសាររបស់លោក និង អ្នកដទៃទៀតដែលបានជឿលើការព្រមាន និង វិវរណៈរបស់ព្រះ និង អស់អ្នកណាដែលស្ដាប់តាមពាក្យរបស់នីហ្វៃ ចេញពីដែនដីនៃពួកលេមិន ។ នៅក្នុងកន្លែងថ្មីនេះ ប្រជាជននីហ្វៃអាចរក្សាសេចក្ដីយុត្តិធម៌ទាំងឡាយ និងក្រឹត្យក្រមទាំងឡាយ និងព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ចំពោះការណ៍ទាំងអស់ ស្របតាមក្រឹត្យវិន័យលោកម៉ូសេ ( សូមមើល នីហ្វៃទី ២ ៥:៦–១០ ) ។ ប៉ុន្តែនៅក្នុងចំណោមពួកសាសន៍នីហ្វៃ មានអ្នកខ្លះបានប្រែជាមិនគោរពប្រតិបត្តិតាមទៅវិញ ។

ហើយជួនកាលខណៈដែលសមាជិកគ្រួសារយើងអាចឈប់រស់នៅក្នុងភាពសុចរិតដូចជាពួកនីហ្វៃ នោះអែលឌើរ ស្កុត បានមានប្រសាសន៍ថា គេហដ្ឋានដែលផ្ដោតលើព្រះគ្រីស្ទនៅតែ « ផ្ដល់ជាការអះអាងដ៏មហិមាបំផុតសម្រាប់ភាពសុខសាន្ត និងជម្រកក្នុងគេហដ្ឋានរបស់យើង » ។ លោកបានទទួលស្គាល់ថា « វាក៏នឹងនៅមានឧបសគ្គ ឬ ការខូចចិត្តជាច្រើនផងដែរ តែទោះជាស្ថិតនៅក្នុងការលំបាកក្ដី ក៏យើងអាចរីករាយនឹងភាពសុខសាន្ត និង សុភមង្គលក្នុងខ្លួនរបស់យើងដែរ » ។[៥]

### *សូមពិចារណាអំពីសំណួរនេះ*

តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីរស់នៅឲ្យកាន់តែសុចរិតនៅក្នុងក្រុមគ្រួសាររបស់យើង ?

កំណត់ចំណាំ

១. *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ ២០១០ ) ចំណុច ១.១.៤ ។
២. រ័សុល អិម ណិលសុន « Celestial Marriage » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៩២ ។
៣. រីឆាត ជី ស្កុត « For Peace at Home » *Liahona* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៣០, ៣១ ។
៤. ហិនរី ប៊ី អាវរិង « The Teachings of ‹ The Family: A Proclamation to the World › » *New Era* ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៥, ៦ ។
៥. រីឆាត ជី ស្កុត « For Peace at Home » ទំព័រ ៣១ ។



ដោយ ដេវិន ជី ឌើរ៉ាន់
ទីប្រឹក្សាទីមួយ
គណៈប្រធានសាលាថ្ងៃអាទិត្យទូទៅ

# ការប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ

*ថ្នាក់សាលាថ្ងៃអាទិត្យដើរតួយ៉ាងសំខាន់នៅក្នុងការជួយពួកយើង ទាំងអស់គ្នា ឲ្យប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ ។ តើអ្នកកំពុងដាក់ថ្នាក់សាលាថ្ងៃអាទិត្យជាអាទិភាពដែរឬទេ ?*

នៅក្នុងព្រះគម្ពីរមរមន អាមូលេកប្រកាសនូវទេសនាកថាដ៏មានឥទ្ធិពលមួយអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ( សូមមើល អាលម៉ា ៣៤ ) ។ ក្នុងចំណោមខគម្ពីរដ៏អស្ចារ្យជាច្រើននៅក្នុងជំពូកនេះ មានខគម្ពីរមួយដែលទាក់ចិត្តខ្ញុំគឺនៅពេលអាមូលេកថ្លែងថា « ដ្បិតមើលចុះ ជីវិតនេះគឺជាពេលវេលាសម្រាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ » ( អាលម៉ា ៣៤:៣២ ) ។

ដោយជឿថាគោលបំណងនៃជីវិតនេះគឺ « ដើម្បីប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ » នោះយើងអាចសួរខ្លួនយើងនូវសំណួរទាំងនេះ ៖ តើខ្ញុំកំពុងធ្វើអ្វីខ្លះរៀងរាល់ថ្ងៃ រាល់សប្តាហ៍ និង រាល់ខែ ដើម្បីប្រុងប្រៀបខ្លួនសម្រាប់ឱកាសជួបជុំគ្នាដ៏អស្ចារ្យជាមួយព្រះវរបិតាសួគ៌របស់យើងនោះ ? តើខ្ញុំនឹងជ្រើសរើសចំណាយពេលវេលាដ៏មានតម្លៃដែលផ្តល់ដល់ខ្ញុំដោយរបៀបណា ?

### តើយើងនឹងប្រុងប្រៀបខ្លួនយ៉ាងដូចម្តេច ?

មានរបៀបជាច្រើនដែលយើងអាចចំណាយពេលវេលារបស់យើង ដើម្បីប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ ។ ពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ខ្ញុំជឿថា យើងអាចយល់ស្របថា ពេលវេលាដ៏សំខាន់បំផុតនៃសប្តាហ៍ គឺជាពេលចំណាយដើម្បីទទួលទានសាក្រាម៉ង់ ដោយរំឭកសេចក្តីសញ្ញាយើងជាមួយព្រះវរបិតាសួគ៌ និង សេចក្តីសង្ឃឹមដែលយើងទាំងអស់គ្នាអាចមាន ដែលជាលទ្ធផលនៃដង្វាយធួនរបស់បុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំក៏ជឿផងដែរថា ពេលវេលាដែលយើងចំណាយនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ អាចមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រុងប្រៀបខ្លួនរបស់យើងជាងអ្វីដែលយើងដឹងទៅទៀត ។ ប៉ុន្តែដើម្បីទទួលបានអត្ថប្រយោជន៍ពីឱកាសនោះ យើងត្រូវតែវាយតម្លៃពីរបៀបដែលយើងចូលរួមថ្នាក់សាលាថ្ងៃអាទិត្យ ។

គោលបំណងនៃថ្នាក់សាលាថ្ងៃអាទិត្យគឺដើម្បី « ពង្រឹងដល់សេចក្តីជំនឿរបស់បុគ្គលម្នាក់ៗ និង សេចក្តីជំនឿរបស់ក្រុមគ្រួសារ ទៅលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទតាមរយៈការបង្រៀន ការរៀន និង ការរាប់អាន » ។[១] ធាតុនៃការប្រែចិត្តជឿដ៏ចាំបាច់ទាំងនេះ មានសារៈសំខាន់នៅក្នុងការខិតខំប្រុងប្រៀបខ្លួនរបស់យើងទៅជួបនឹងព្រះ ។ យើងមានចិត្តរំភើបជាខ្លាំង ដែលគ្រូបង្រៀននៅទូទាំងសាសនាចក្រកំពុងធ្វើការកែលម្អសមត្ថភាពរបស់ពួកគាត់ក្នុងការបង្រៀនដោយប្រើ *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* និង ការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន ។

ប៉ុន្តែការកែលម្អការបង្រៀនតែមួយមុខ វាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ វាត្រូវផ្គូបផ្គងនឹងកិច្ចខិតខំរបស់យើងដើម្បីរៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។ ទ្រង់មានព្រះបន្ទូលថា យើងត្រូវតាំងចិត្តរៀនសូត្រ « ដោយការសិក្សា និង ដោយសេចក្តីជំនឿផងដែរ » ( គ. និង ស. ១០៩:៧ ) ។ សេចក្តីជំនឿគឺជាគោលការណ៍នៃសកម្មភាព ។ យើងត្រូវតែ *ធ្វើ* ប្រសិនបើយើងចង់ *ដឹង* ( សូមមើល យ៉ូហាន ៧:១៧ ) ។

ថ្នាក់រៀននៅសាលាថ្ងៃអាទិត្យរបស់យើង អាចលើកកម្ពស់ការបង្រៀន និង ការរៀនសូត្របែបនេះបាន នៅពេលដែលថ្នាក់រៀនទាំងនោះគឺជាកន្លែងដ៏មានសុវត្ថិភាព ដើម្បីចែកចាយបទពិសោធន៍ដែលយើងមាន និង ការបំផុសគំនិតដែលពួកគេបានទទួលអំឡុងពេលក្នុងសប្តាហ៍ ខណៈដែលពួកគេកំពុងរៀន និង អនុវត្តខគម្ពីរនៅក្នុងរៀបចំដើម្បីមករៀន ។ នៅពេលយើង « បង្រៀនគ្នាទៅវិញទៅមកអំពីគោលលទ្ធិនៃនគរ . . . ឲ្យទាំងអស់បានស្អាងឡើងទាំងអស់គ្នា » ( គ. និង ស. ៨៨:៧៧, ១២២ ) ។

### រាប់ថ្ងៃឈប់សម្រាកទុកជាទីរីករាយចិត្ត

ថ្មីៗនេះ គណៈប្រធានទីមួយបានអញ្ជើញពួកយើងម្នាក់ៗឲ្យ « រាប់ថ្ងៃឈប់សម្រាកទុកជាទីរីករាយចិត្ត » ( អេសាយ ៥៨:១៣ ) នៅក្នុងជីវិតរបស់យើង ។ បទពិសោធន៍ប្រជុំបីម៉ោងនាថ្ងៃអាទិត្យជួយយើងឲ្យសម្រេចបាននូវគោលដៅនោះ ។

នៅក្នុងស្មារតីនេះ ខ្ញុំសូមសួរសំណួរមួយផ្សេងទៀត ៖ ជួនកាលហេតុអ្វីយើងជ្រើសរើសពុំចាប់យកឱកាសចូលរួមពេញលេញក្នុងថ្នាក់សាលាថ្ងៃអាទិត្យដូច្នេះ ?

នៅប៉ុន្មានឆ្នាំថ្មីៗនេះ ខ្ញុំបានឃើញ « ការដាក់ជំនួស » ជាច្រើនផ្សេងៗគ្នា ក្នុងម៉ោងថ្នាក់សាលាថ្ងៃអាទិត្យ រួមមានការសួរសុខទុក្ខនៅតាមផ្លូវដើរក្នុងសាលប្រជុំ ថ្នាក់ដឹកនាំរួដធ្វើការសម្ភាសន៍នានា ថ្នាក់





ដឹកនាំស្តេកបំពាក់បំប៉នអ្នកនៅក្រោមឱវាទរបស់ពួកគេនៅក្នុងវួដ និង ថ្នាក់ដឹកនាំយុវវ័យរៀបរាប់ពីកម្មវិធីនានាដែលជាកង្វល់របស់ពួកគេ ។

ដោយសារការត្រូវការពេលវេលាដ៏ច្រើនរបស់ពួកគេ នោះខ្ញុំយល់ពីមូលហេតុដែលថ្នាក់ដឹកនាំប្រើពេលវេលានៃថ្នាក់សាលាថ្ងៃអាទិត្យ ដើម្បីធ្វើកិច្ចការផ្សេងៗ ។ ប៉ុន្តែវាជាពរជ័យអ្វីម្ល៉េះដល់អស់អ្នកដែលពាក់ព័ន្ធទាំងអស់ នៅពេលថ្នាក់ដឹកនាំវួដញែកពេលមួយម៉ោងចូលរួមនៅក្នុងការពិភាក្សាដំណឹងល្អជាមួយសមាជិកនៃក្រុមជំនុំរបស់ខ្លួន ។

ខ្ញុំមានទំនុកចិត្តថា អ្នកធ្លាប់មានបទពិសោធន៍ផ្សេងទៀតនៃ « ការព្រងើយកន្តើយនឹងថ្នាក់សាលាថ្ងៃអាទិត្យ » ។ ដ្បិតដោយសារហេតុផលណាមួយ ឬ ហេតុផលផ្សេងទៀត ពួកយើងជាច្រើននាក់បានមានអារម្មណ៍ថា ជាច្រើនលើកច្រើនគ្រាយើងពុំបានប្រយោជន៍អ្វីច្រើនពីថ្នាក់សាលាថ្ងៃអាទិត្យដូចចិត្តយើងចង់បានឡើយ ។ ខ្ញុំបានរៀនថា បទពិសោធន៍ដ៏អស្ចារ្យនៃថ្នាក់សាលាថ្ងៃអាទិត្យរបស់ខ្ញុំ ត្រូវបានកំណត់កាន់តែច្រើនតាមរយៈការរៀបចំ និង ការចូលរួមរបស់ខ្ញុំ ដូចគ្រូបង្រៀនរបស់ខ្ញុំបានធ្វើផងដែរ ។

បងប្រុស ថាត អរ ខាលីស្ទើរ ប្រធានថ្នាក់សាលាថ្ងៃអាទិត្យទូទៅបានសរសេរថា « គ្រប់ពេលយើងសិក្សាព្រះគម្ពីរ មកថ្នាក់រៀនដោយមានការរៀបចំខ្លួនប្រសើរជាងមុនបន្តិច ចូលរួមការពិភាក្សាក្នុងថ្នាក់ សួរសំណួរ និង កត់ត្រាការបំផុសគំនិតដ៏ពិសិដ្ឋនានា នោះយើងប្រែក្លាយកាន់តែដូចជាព្រះ ហេតុដូច្នេះហើយវាបង្កើនសមត្ថភាពរបស់យើងដើម្បីដកពិសោធន៍នូវអំណរដែលទ្រង់មាន » ។[២]

## ការរៀបចំ និង ការរក្សាម៉ោងរៀននាថ្នាក់សាលាថ្ងៃអាទិត្យ

ខ្ញុំសូមអញ្ជើញបងប្អូនឲ្យប្រឹងអស់ពីសមត្ថភាពខ្លួន ដើម្បីរៀបចំ និង រក្សាម៉ោងរៀននាថ្នាក់សាលាថ្ងៃអាទិត្យ ។ សមាជិកវួដ និង សាខាម្នាក់ៗ រួមទាំងថ្នាក់ដឹកនាំរបស់យើង គួរតែមានពរជ័យដ៏អស្ចារ្យនៃការប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ អំឡុងពេលដ៏សំខាន់នេះរៀងរាល់សប្តាហ៍ ។ ■

**កំណត់ចំណាំ**

១. *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ ២០១០ ) ចំណុច ១២.១ ។

២. ថាត អរ ខាលីស្ទើរ « The Joy of Learning » *Liahona* ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ១៤ ។



រៀនបន្ថែមទៀតអំពី *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* និង ក្រុមប្រឹក្សាគ្រូបង្រៀននៅគេហទំព័រ teaching.lds.org/khm ។



ដោយ ប៊ីស្សព ហ្គេរ៉ល កូសសេ
ប៊ីស្សពជាអធិបតី

# ការរៀបចំកន្លែងមួយសម្រាប់ ព្រះអម្ចាស់

*គ្រប់ពេលដែលខ្ញុំបានស្ដាប់ឮអំពីរឿងនៃការប្រសូត និង ការបម្រើនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះ ខ្ញុំគិតអំពីការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើង ដើម្បីរៀបចំកន្លែងដ៏ស្វាគមន៍សម្រាប់ទ្រង់នាថ្ងៃដែលទ្រង់យាងត្រឡប់មកវិញ ។*

ឆ្នាំមុនពីមុនបុណ្យគ្រីស្ទម៉ាស់ ខ្ញុំបានចូលរួមទទួលទានអាហារពេលល្ងាច ដែលផ្ដល់ឲ្យដោយកិត្តិយសពីមន្ត្រីបារាំងដ៏មានបុណ្យសក្តិខ្ពស់ម្នាក់ ដែលពុំមែនជាសមាជិកសាសនាចក្រឡើយ ។ ការទទួលទានអាហារពេលល្ងាចនេះត្រូវបានធ្វើឡើងនៅអគាររំឮកចាំ យ៉ូសែប ស្ម៊ីធ នៅក្នុងទីក្រុង សតល៍ លេក រដ្ឋ យូថាហ៍ ។

ពីមុនអង្គុយបរិភោគអាហាររបស់យើង យើងបាននាំភ្ញៀវរបស់យើងទៅមើលតាមបង្អួចនៅជាន់ទី ១០ ដែលភ្ញៀវរបស់យើងអាចមើលឃើញទេសភាពដ៏ស្រស់ត្រកាលរបស់វិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ ។ ទេសភាពនោះគឺអស្ចារ្យបំផុត ដោយមានព្រះវិហារបរិសុទ្ធ សលត៍ លេក ឈរយ៉ាងខ្ពស់សន្លឹមនៅកណ្ដាលពន្លឺភ្លើងពណ៌ព្រិចៗជាច្រើន ។ ពួកយើងបានឈរនៅទីនោះអស់ពេលបួនប្រាំនាទី ដោយរកអ្វីមកថ្លែងពុំបានឡើយ ។

នៅពេលត្រឡប់មកបន្ទប់ទទួលទានអាហាររបស់យើងវិញ មន្ត្រីរូបនោះបានសួរសំណួរដ៏គួរឲ្យភ្ញាក់ផ្អើលមួយដល់ពួកយើង ៖ « តើលោកជឿលើការបញ្ចប់នៃពិភពលោកដែរឬទេ ? » សំណួរនេះនាំឲ្យមានការបំផុសឲ្យមានការពិភាក្សាមួយ អំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ និង សារៈសំខាន់សម្រាប់ពួកយើងគ្រប់គ្នាដើម្បីត្រៀមខ្លួនទទួលទ្រង់នៅថ្ងៃដែលទ្រង់យាងត្រឡប់មកវិញ ។

នៅពេលខ្ញុំកំពុងគិតអំពីព្រះវិហារបរិសុទ្ធដែលយើងទើបតែបានសរសើរនោះ គំនិតដ៏អស្ចារ្យមួយបានផុសឡើងក្នុងចិត្តខ្ញុំ ៖ « នៅពេលទ្រង់យាងមកវិញ *យ៉ាងហោចណាស់* ព្រះយេស៊ូវនឹងមានកន្លែងដ៏ស្រស់ស្អាតមួយដើម្បីគង់នៅ ! »

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ចែងថាព្រះវិហារបរិសុទ្ធគឺ « *ពិតជាដំណាក់នៃព្រះអម្ចាស់* » ។[1] និយាយម្យ៉ាងទៀតថា ព្រះវិហារបរិសុទ្ធមិនមែនគ្រាន់តែជានិមិត្តរូបនៃទីកន្លែងមួយឡើយ ។ ព្រះវិហារបរិសុទ្ធនាគ្រាកាន់កាប់ត្រួតត្រារបស់យើងនេះ គឺជាដំណាក់ដែលត្រូវបានរៀបចំ និងឧទ្ទិសឡើង ជាទីដែលទ្រង់អាចយាងមកគង់នៅ ។ ព្រះអម្ចាស់មានព្រះបន្ទូលថា សាសនាចក្ររបស់ទ្រង់គួរតែត្រូវបានស្ថាបនាឡើង « ប្រយោជន៍ឲ្យរាស្ត្ររបស់យើង ដែលនៅក្នុងសេចក្ដីសញ្ញា អាចបានប្រមូលគ្នាតែមួយ នៅក្នុងថ្ងៃនោះ *កាលដែលយើងនឹងយាងមកព្រះវិហាររបស់យើង* » ( គ. និង ស. ៤២:៣៦ ការគូសបញ្ជាក់បានបន្ថែម ) ។

វាជាភាពផ្ទុយគ្នាមួយដ៏គួរឲ្យចាប់អារម្មណ៍ជាមួយនឹងការចាប់ផ្ដើមក្នុងជីវិតរមែងស្លាប់ដ៏រាបទាបរបស់ព្រះអង្គសង្គ្រោះ ។ ទ្រង់គឺជាស្ដេចនៃអស់ទាំងស្ដេច ហើយជាព្រះអម្ចាស់នៃអស់ទាំងព្រះអម្ចាស់ បានប្រសូតមកនៅក្នុងក្រោលសត្វដ៏សាមញ្ញ ហើយផ្ទុំនៅក្នុងស្នូក « ពីព្រោះក្នុងផ្ទះសំណាក់ . . . គ្មានកន្លែងណានៅទេ » ( លូកា ២:៧ ) ។ អំឡុងពេលកុមារភាពរបស់ទ្រង់ ព្រះយេស៊ូវគ្មានពេលរីករាយនឹងការគង់នៅជាប់ជានិច្ចនៅក្នុងផ្ទះដ៏ស្រណុកសុខស្រួលឡើយ ដូចជាគ្រាដែលគ្រួសាររបស់ទ្រង់បានរត់ភៀសខ្លួនទៅប្រទេសអេស៊ីព្ទ ដើម្បីគេចខ្លួនពីភាពសាហាវឃោរឃៅរបស់ក្សត្រដែលកាន់អំណាចផ្ដាច់ការ ( សូមមើល ម៉ាថាយ ២:១៣–១៤ ) ។

យើងពុំបានដឹងច្បាស់អំពីរយៈពេលដែលគ្រួសារទ្រង់ទៅប្រទេសអេស៊ីព្ទឡើយ ប៉ុន្តែទំនងជាទ្រង់ និង ឪពុកម្ដាយទ្រង់បានរស់នៅក្នុងស្ថានភាពយ៉ាងយាប់យឺន

រូបភ្លើងពន្លឺ© ISTOCK/THINKSTOCK



ជាជនភៀសខ្លួន—ជាស្ថានភាពរស់នៅដែលអាចប្រៀបទៅនឹងជនចំណាកស្រុកជាច្រើននាជំនាន់យើងនេះ ដែលបានរត់គេចខ្លួនពីការគំរាមកំហែងនៃសង្គ្រាម និង ជម្លោះផ្ទៃក្នុងនៅក្នុងប្រទេសអាហ្វ្រិក និង ពួកមជ្ឈិមប្រទេស ។

ទោះបីអំឡុងពេលពេញវ័យក្ដី ព្រះយេស៊ូវបានបង្ហាញថា ទ្រង់គ្មានផ្ទះជាប់លាប់ឡើយ ។ នាថ្ងៃមួយបុរសម្នាក់បានមកជួបទ្រង់ ហើយនិយាយថា « ព្រះអម្ចាស់អើយ ទូលបង្គំនឹងតាមទ្រង់ ទោះបើទ្រង់យាងទៅក្នុងទីណាក៏ដោយ » ។ ព្រះអង្គសង្គ្រោះបានតបវិញថា « កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុកដែរ តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ » ( លូកា ៩:៥៧, ៥៨ ) ។

បងប្អូនប្រុសស្រី គ្រប់ពេលដែលខ្ញុំបានស្ដាប់ឮអំពីរឿងនៃការប្រសូត និង ការបម្រើនៅលើផែនដីរបស់ព្រះយេស៊ូវគ្រីស្ទ ខ្ញុំគិតអំពីការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើង ដើម្បីរៀបចំកន្លែងដ៏ស្វាគមន៍សម្រាប់ទ្រង់នាថ្ងៃដែលទ្រង់យាងត្រឡប់មកវិញ ។ តើយើងអាចធ្វើអ្វីខ្លះ ?

## ទៅព្រះវិហារបរិសុទ្ធ

ទីមួយ ចូរយើងត្រៀមខ្លួនដើម្បីទទួលទ្រង់នៅក្នុងដំណាក់របស់ទ្រង់ផ្ទាល់—គឺព្រះវិហារបរិសុទ្ធ ។ តើមាននរណាខ្លះដែលនៅក្នុងចំណោមពួកយើងមិនធ្លាប់ស្រមៃថា ទៅទស្សនាកន្លែងនានាដែលព្រះអង្គសង្គ្រោះបានប្រសូត គង់នៅ និង បានសម្រេចការងារបម្រើរបស់ទ្រង់នៅលើផែនដីនេះនោះ ? មានមនុស្សជាច្រើន ដោយមានការលះបង់ខ្ពស់ បានធ្វើដំណើរទៅទឹកដីដ៏បរិសុទ្ធទាំងនោះ ។ ប៉ុន្តែវាសំខាន់ខ្លាំងណាស់ ដែលយើងទស្សនាទីកន្លែងនានាដែលទ្រង់អាចនឹងយាងត្រឡប់មកវិញនាពេលខាងមុខ ។ វិធីមួយដ៏ប្រសើរបំផុត ក្នុងនាមយើងជាពួកសិស្សរបស់ទ្រង់អាចធ្វើ ដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់នោះ គឺការទៅព្រះដំណាក់ដ៏បរិសុទ្ធរបស់ទ្រង់ឲ្យបានទៀងទាត់ ហើយចុះកិច្ចសន្យារវាងពួកយើងនឹងទ្រង់តាមរយៈសេចក្ដីសញ្ញាដ៏ពិសិដ្ឋ ។

## រៀបចំគេហដ្ឋានរបស់អ្នក

ទីពីរ យើងអាចធ្វើឲ្យគេហដ្ឋានរបស់យើងក្លាយជាកន្លែងមួយ ដែលព្រះអម្ចាស់មានព្រះទ័យគង់នៅ ។ នៅក្នុងព្រះគម្ពីរ យើងបានអានដំណើររឿងជាច្រើននៃមនុស្សមានចិត្តសប្បុរសដែលស្វាគមន៍ និង ទទួលព្រះអង្គសង្គ្រោះឲ្យទៅផ្ទះរបស់ពួកគេ ។ ដូច្នេះចូរពួកយើងសួរសំណួរនេះដល់ខ្លួនយើង ៖ តើព្រះអម្ចាស់ទទួលយកផ្ទះរបស់ខ្ញុំដែរឬទេ ? តើផ្ទះរបស់ខ្ញុំជាកន្លែងដែលមានសុវត្ថិភាព សុខសាន្ត និង ជាកន្លែងដែលពោរពេញដោយព្រះវិញ្ញាណ ជាកន្លែងដែលទ្រង់នឹងមានអារម្មណ៍នៃជាសុកភាពដែរទេ ? គេហដ្ឋានរបស់យើងពុំចាំបាច់ថាត្រូវតែធំ ឬ ល្អប្រណិតនោះឡើយ ។ គេដ្ឋានដែលមានការរស់នៅដ៏រាបទាប ផ្ដោតលើដំណឹងល្អ និង ពោរពេញដោយគ្រួសារ និង មិត្តភក្ដិដែលចេះមើលថែទាំគ្នា នោះធ្វើឲ្យទ្រង់សប្បាយព្រះទ័យហើយ ។

## ប្រមូលពួកអ្នករើសតាំង

ទីបី យើងអាចជួយប្រមូលពួកអ្នករើសតាំងរបស់ទ្រង់ មកពីគ្រប់ទិសទីលើពិភពលោកនេះ—ទោះបី ការធ្វើការណ៍នេះតម្រូវឲ្យយើងចាកចោលផ្ទះសម្បែងរបស់យើងមួយរយៈ ដើម្បីជួយស្ថាបនានគររបស់ទ្រង់នៅលើផែនដីនេះក្ដី ។ ប្រវត្តិរបស់វាស្ត្រនៃព្រះគឺជាប្រវត្តិនៃពួកបរិសុទ្ធ ដែលត្រៀមខ្លួនរួចជាស្រេច និង មានឆន្ទៈដើម្បីចេញទៅទីកន្លែងដែលព្រះអម្ចាស់មានព្រះទ័យឲ្យពួកគេទៅ ។ ខ្ញុំគិតអំពីព្យាការីពីបុរាណដូចជា អ័ប្រាហាំ អ៊ីសាក យ៉ាកុប យ៉ូសែប ម៉ូសេ លីហៃ និង ព្យាការីជាច្រើនទៀត ។ ខ្ញុំគិតពីពួកសាវករបស់ព្រះអម្ចាស់នៅក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ដែលប្រកាសដំណឹងដោយឥតឈប់ឈរនៅទូទាំងប្រទេសតំបន់មេឌីទែរ៉ាណេ ។

ពួកព្យាការី និង ពួកសាវកថ្ងៃចុងក្រោយ រួមទាំងពួកអ្នកផ្សព្វផ្សាយសាសនារាប់ពាន់នាក់ បានយក និង កំពុងបន្តនាំយកសារលិខិតរបស់ព្រះគ្រីស្ទទៅកាន់ទិសទាំងបួននៃផែនដីនេះ ។ ពួកគេមានឆន្ទៈចាកចេញពីផ្ទះដ៏ស្រណុកសុខស្រួលរបស់ខ្លួនដើម្បីផ្ដល់ការបម្រើរបស់ពួកគេនៅក្នុងចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់ ។

## ជួយដល់អស់អ្នកដែលខ្វះខាត

ជាទីបញ្ចប់ របៀបមួយដ៏អស្ចារ្យដើម្បីរៀបចំកន្លែងមួយសម្រាប់ព្រះអម្ចាស់ គឺជួយអ្នកជិតខាងរបស់យើងដែលគ្មានផ្ទះនៅ ។ នាគ្រាដំបូងៗនៃការស្ដារឡើងវិញ រួមទាំងពេលដែលពួកបរិសុទ្ធគ្មានទីជម្រកជ្រកកោនផងដែរ ។ ជាញយៗ ការគ្មានសេរីភាពខាងសាសនា និង អំពើទុច្ចរិតមកពីសត្រូវរបស់ខ្លួន នោះពួកបរិសុទ្ធបានបង្ខំចិត្តចាកចោលពីផ្ទះសម្បែងរបស់ខ្លួន នៅក្នុងការស្វែងរកក្រុងស៊ីយ៉ូនរបស់ពួកគេ ។

ប្រធាន ព្រិកហាំ យ៉ង់ ( ឆ្នាំ ១៨០១-៧៧ ) បានប្រើពាក្យដ៏រំជួលចិត្តទាំងនេះ ដើម្បីពិពណ៌នាអំពីស្ថានភាពដ៏លំបាករបស់ពួកគេដូចនេះ ៖ « យើងត្រូវបានបណ្ដេញចេញម្ដងហើយម្ដងទៀត ពីផ្ទះដ៏សុខសាន្តរបស់យើង ហើយភរិយា និង កូនៗរបស់យើងត្រូវបានបង្ខំឲ្យរស់នៅលើទីវាលដ៏ធំ នៅក្នុងព្រៃ នៅតាមដងផ្លូវ និង នៅក្នុងពាង នៅក្នុងរដូវរងារ ដោយរងការឈឺចាប់នៃក្ដីលំបាកគ្រប់បែបយ៉ាង រហូតឈានទៅដល់ការបាត់បង់ជីវិត » ។[២]

ព្រឹត្តិការណ៍ដ៏បំផុសគំនិតមួយចេញពីយុគសម័យនោះ ផ្ដោតសំខាន់លើភូមិឃ្វីនស៊ី ដ៏តូចមួយនៃរដ្ឋ អិលលីណោយ អំឡុងរដូវរងានាឆ្នាំ ១៨៣៩ ។ នាគ្រានោះ សហគមន៍នៃអ្នកតាំងទីលំនៅ និង កសិករបានតាំងទីលំនៅលើដងទន្លេមិស៊ីស៊ីបពី ដោយមានមនុស្សប្រហែល ១៥០០ នាក់រស់នៅក្នុងស្ថានភាពមួយដ៏ត្រដាបត្រដួស ។ នៅពាក់កណ្ដាលនៃរដូវរងាដ៏ត្រជាក់ខ្លាំងនោះ ពួកគេបានជួបនឹងការមកដល់នៃសមាជិកសាសនាចក្រប្រហែលជា ៥០០០ នាក់ ដែលបានរត់ភៀសខ្លួនពីការបញ្ជាសម្លាប់ផ្ដាច់ពូជ ដែលបានចេញដោយអភិបាលនៃរដ្ឋមិសសួរី ។ ពួកបរិសុទ្ធបានស្ថិតក្នុងសភាពក្រតោកយ៉ាក និង មានទុក្ខព្រួយបំផុត ដោយត្រូវដើរឆ្លងកាត់ទឹកដែលកកនៃទន្លេមិស៊ីស៊ីបពី ។ ដោយសេចក្ដីសប្បុរសដ៏អស្ចារ្យ ពួកប្រជាពលរដ្ឋនៃភូមិ ឃ្វីនស៊ី បានស្វាគមន៍ពួកគេដោយភាពកក់ក្ដៅ ដោយបើកផ្ទះពួកគេឲ្យពួកបរិសុទ្ធស្នាក់នៅ និង ចែកស្បៀងបន្តិចបន្តួចដែលពួកគេមានដល់ពួកបរិសុទ្ធ ។

ប្រជាពលរដ្ឋម្នាក់នៃភូមិ ឃ្វីនស៊ី បានពិពណ៌នាអំពី ការមកដល់នៃពួកជនភៀសខ្លួនទាំងនេះ ៖ « ពួកបរិសុទ្ធជាច្រើនបានសប្បាយចិត្តនឹងបានជម្រកជ្រកកោននៅក្នុងផ្ទះរបស់ខ្ញុំ ពីព្យុះភ្លៀង រហូតដល់ពួកគេអាចរកបានកន្លែងមួយ



រស់នៅ ។ រៀងរាល់យប់ ទាំងនៅលើកម្រាលឥដ្ឋ ជាន់លើ និង ជាន់ក្រោម មានសុទ្ធតែគ្រែដេកកៀកៗគ្នា ដែលមិនអាចជាន់ទីណាបានក្រៅពីជាន់លើគ្រែដេកឡើយ » ។[៣]

ចំពោះពួកយើងដែលមានពរដោយបានរស់នៅ ក្នុងស្ថានភាពដ៏ស្ងប់សុខ និង រុងរឿងជាងនោះ ដំណើររឿងនេះមានឥទ្ធិពលដ៏អស្ចារ្យណាស់ ។ ពួកគេបង្រៀនយើងឲ្យធ្វើជាមនុស្សដែល ត្រៀមខ្លួនជានិច្ចដើម្បីជួយដល់អ្នកដែលគ្មានផ្ទះ និង ក្រតោកយ៉ាក ។ មិនថាយើងរស់នៅក្នុងតំបន់ដែលមានការហូរចូលយ៉ាងច្រើន ឬ តិចតួច ឬ សហគមន៍ដែលដាច់ស្រយាលតែឯងនៃជនភៀសខ្លួនយ៉ាងណានោះទេ មានរបៀបជាច្រើនដែលយើងបម្រើដល់អស់អ្នកដែល ជួបការលំបាកដើម្បីមានវត្ថុចាំបាច់បន្តិចបន្តួចសម្រាប់ជីវិតរស់នៅ ។ យើងអាចបរិច្ចាគទៅឲ្យមូលនិធិជំនួយសប្បុរសធម៌របស់សាសនាចក្រ ។ យើងអាចធ្វើការជាមួយអ្នកដទៃនៅក្នុងសហគមន៍របស់យើង ដែលផ្តល់ការបម្រើដោយក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទទៅដល់ជនទុគ៌តទាំងនោះ ។ ពួកយើងអាចបង្កើនមិត្តភាពរបស់យើងដល់អស់អ្នកដែលត្រូវបានបណ្តេញចេញ នៅពេលពួកគេបានមកដល់សហគមន៍របស់យើង ។ យើងអាចស្វាគមន៍យ៉ាងកក់ក្តៅដល់ជនប្លែកមុខដែលមកលេងវួដ និង សាខារបស់យើង ។

ទំនុកតម្កើងដ៏ពិរោះបំផុតមួយរបស់យើង រំឭកអំពីដំណើររបស់ជនប្លែកមុខម្នាក់ដែលបានទីជ្រកកោនពីបុរសម្នាក់ដែលមានចិត្តសប្បុរសដ៏ខ្លាំង ។

*កាលយប់យន់ទឹកជោរជន់ហូរមក*
*ព្យុះភ្លៀងផាត់បក់បោកពីចម្ងាយ ។*

*ខ្ញុំឮសំឡេងគាត់នៅឯនាយ*
*ដង្ហោយអង្វរសុំផ្ទះជ្រកកោន*
*ខ្ញុំបំពាក់អាវឲ្យភ្ញៀវកក់ក្តៅ*
*ដាក់ឲ្យគាត់នៅសម្រាកលើគ្រែ*
*ឯខ្ញុំយកធរណីស្រមៃធ្វើ*
*ហាក់ដូចជាបាននៅសួនអេដែន ។ . . .*

*រំពេចនោះខ្ញុំបានឃើញយ៉ាងច្បាស់*
*ស្គាល់ស្នាមដែកគោលដែលនៅព្រះហស្ត*
*ខ្ញុំចាំយ៉ាងជាក់ព្រះអង្គសង្គ្រោះ*
*ប្រត្យក្សទ្រង់ឈរចំពោះមុខខ្ញុំ*
*ដោយរាបទាបទ្រង់ហៅឈ្មោះខ្ញុំទាំងថា*
*« អ្នកឥតអាម៉ាសដល់ខ្ញុំឡើយ ។*
*កិច្ចការអ្នកធ្វើនឹងត្រូវចងចាំ*
*កុំភ័យ ដ្បិតអ្នកបានធ្វើដល់ខ្ញុំ » ។*[៤]

ខ្ញុំមានមោទនភាពក្នុងការធ្វើជាសមាជិកក្នុងសាសនាចក្រមួយដែល ជួយដល់ជនក្រីក្រ និង អ្នកខ្វះខាតនៅលើផែនដីនេះ ។ ខ្ញុំមានក្តីរាបទាបដោយសារទង្វើនៃក្តីស្រឡាញ់ និង សប្បុរសដែលរាប់មិនអស់ ទាំងតូច ទាំងធំ ដែលបានធ្វើឡើងរៀងរាល់ថ្ងៃដោយសាសនាចក្រ និង សមាជិកសាសនាចក្រ ។ ទង្វើទាំងនេះនឹងក្លាយជាផ្នែកមួយដ៏ចាំបាច់នៃបេសកកម្មរបស់សាសនាចក្រ ដោយសារនេះជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ហើយយើងព្យាយាមធ្វើតាមគំរូរបស់ទ្រង់ ។

ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ និង ជាព្រះប្រោសលោះរបស់យើង ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ទ្រង់បានប្រសូតមកក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ថាទ្រង់មានព្រះជន្មរស់ ហើយថាថ្ងៃខាងមុខ ទ្រង់នឹងយាងត្រឡប់មកវិញ ដោយនៅក្នុងសិរីល្អ ដើម្បីគ្រប់គ្រង និង គ្រងរាជលើនគរទ្រង់នៅលើផែនដីនេះ ។

តាមរបៀបនៃការរៀបចំ នោះខ្ញុំសូមអញ្ជើញបងប្អូនឲ្យទៅដំណាក់ដ៏បរិសុទ្ធរបស់ទ្រង់កាន់តែញឹកញាប់ បង្កើតបរិយាកាសមួយដែលមានសុខសុវត្ថិភាព ក្តីស្រឡាញ់ និង សុខសាន្តនៅក្នុងគេហដ្ឋានរបស់បងប្អូន ហើយចូលរួមក្នុងការប្រមូលពួកអ្នករើសតាំងរបស់ទ្រង់ពីទិសទាំងបួននៃផែនដីនេះ ។ ខ្ញុំក៏សូមអធិស្ឋានថា បងប្អូននឹងមានក្តីប្រាថ្នាយ៉ាងពិសេស ដើម្បីជួយដោយក្តីស្រឡាញ់ដល់អស់អ្នកដែលនៅក្នុងចំណោមពួកយើង ដែលគ្មានផ្ទះសម្បែង និង ក្រលំបាកតោកយ៉ាក ។ តាមរយៈការធ្វើបែបនេះ នោះបងប្អូននឹងរៀបចំកន្លែងមួយនៅក្នុងចិត្ត និង គេហដ្ឋានរបស់បងប្អូន ដើម្បីស្វាគមន៍ព្រះអង្គសង្គ្រោះ និង ការយាងត្រឡប់មកវិញរបស់ទ្រង់ ដែលពិតជានឹងក្លាយជាថ្ងៃមួយដ៏មហិមា និង អស្ចារ្យ ។ ■

**កំណត់ចំណាំ**

១. សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះវិហារបរិសុទ្ធ » ការគូសបញ្ជាក់បានបន្ថែម ។
២. ព្រិកហាំ យ៉ង់ នៅក្នុង B. H. Roberts *A Comprehensive History of the Church* ២:៥០៩ ។
៣. Wandle Mace នៅក្នុង Ora H. Barlow *The Israel Barlow Story and Mormon Mores* ( ឆ្នាំ ១៩៦៨ ) ទំព័រ ១៥៦ សូមមើលផងដែរនៅទំព័រ ១៥៤–៥៥ ។
៤. « អ្នកធ្វើដំណើរដ៏ក្រតោកយ៉ាក » *ទំនុកតម្កើង* លេខ ១៧ ។





ដោយ អែលឌើរ ជេម ជេ ហាមូឡា
នៃពួកចិតសិបនាក់

# អំណាចនៃ ព្រះគុណ របស់ព្រះ

*ព្រះគុណមានបំណងធ្វើឲ្យយើងអាចកាន់តែរក្សាបទបញ្ញត្តិបានល្អឥតខ្ចោះ ហើយរស់នៅកាន់តែដូចជាព្រះគ្រីស្ទ រហូតយើងបានដល់កម្ពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ ។*

លក្ខណៈមួយដែលប្រហែលជាសំខាន់ខ្លាំងបំផុតរបស់ព្រះយេស៊ូវគ្រីស្ទនោះគឺថាទ្រង់ « មានពេញជាព្រះគុណ » ( យ៉ូហាន ១:១៤ ) ។ ជាញយៗនៅក្នុងព្រះគម្ពីរពាក្យ *ព្រះគុណ* សំដៅលើការផ្ដល់ឲ្យ និង អំណាចរបស់ព្រះដើម្បីប្រទានពរ ផ្ដល់អំណោយទាន ឬ បើពុំនោះសោតទេជាការធ្វើទង្វើដែលផ្គាប់ចិត្តមនុស្ស ។ Bible Dictionary បានថ្លែងពីពាក្យនេះតាមរបៀបដូចនេះ ៖ « គំនិតដ៏សំខាន់នៃពាក្យ [*ព្រះគុណ*] គឺជាមធ្យោបាយនៃជំនួយ ឬ កម្លាំងមកពីព្រះ ។ . . . ព្រះគុណគឺជាអំណាចដែលអាចធ្វើឲ្យទៅរួចបាន » ( « Grace » ) ។ វាអាចធ្វើឲ្យអ្នកទទួលធ្វើ និង ក្លាយជាអ្វីដែលពួកគាត់ពុំអាចធ្វើ ឬ ពុំអាចប្រែក្លាយបាន ប្រសិនបើទុកឲ្យធ្វើដោយមធ្យោបាយនៃខ្លួនពួកគាត់ផ្ទាល់ ។

ពួកយើងទាំងអស់គ្នាត្រូវការអំណាចមួយដែលអាចធ្វើឲ្យទៅរួចនោះ ។ យើងគឺជាបុត្រា និង បុត្រីទាំងឡាយរបស់ព្រះ ។ ហេតុដូច្នោះហើយ យើងមានសក្ដានុពលដើម្បីប្រែក្លាយដូចជាទ្រង់ ។

រូបគំនូរមកពី *THEY BROUGHT THEIR LITTLE CHILDREN* ដោយ វ៉លធើរ រ៉ាណេ ហាមថតចម្លង

### អសមត្ថភាពរបស់យើងនៅក្នុងវិញ្ញាណ និង រូបកាយ

ខណៈដែលរំពឹងទុកថា យើងត្រូវសម្រេចបាននូវ « សេចក្ដីពោរពេញផងព្រះគ្រីស្ទ » ( អេភេសូរ ៤:១៣ ) នោះយើងពិតជាពុំអាចធ្វើកិច្ចការនោះដោយខ្លួនឯងឡើយ ។ យើងម្នាក់ៗកើតឡើងពីធាតុពីរយ៉ាង—វិញ្ញាណអស់កល្បជានិច្ច និង រូបកាយរមែងស្លាប់ ( សូមមើល អ័ប្រាហាំ ៣:១៨ ) ។ វិញ្ញាណអស់កល្បជានិច្ចរបស់យើងមកកាន់ផែនដីនេះគឺជាលទ្ធផលនៃការជ្រើសរើសដែលបានធ្វើកាលពីពិភពមុនឆាកជីវិតនេះ ។ ជម្រើសកាលពីជីវិតមុនផែនដីទាំងនេះ គឺជាផ្នែកមួយនៃបុគ្គលិកលក្ខណៈ អត្តចរិត និង បញ្ញាខាងវិញ្ញាណរបស់យើង ។ ប្រាកដណាស់ វិញ្ញាណពីរពុំអាចមានលក្ខណៈដូចគ្នាបានឡើយ ( សូមមើល អ័ប្រាហាំ ៣:១៩ ) ។ វិញ្ញាណនីមួយៗរីកចម្រើនតាមកម្រិតផ្សេងៗគ្នានៃបញ្ញាខាងវិញ្ញាណ ឬ ពន្លឺ និង សេចក្ដីពិត ( សូមមើល គ. និង ស. ៩៣:៣៦ ) ស្របទៅតាមជម្រើសកាលពីជីវិតមុនផែនដីរបស់ពួកគេ ។ ទោះបីជាវិញ្ញាណរបស់យើងម្នាក់ៗ អាចមកក្នុងរូបកាយនៃជីវិតរមែងស្លាប់នេះនៅពេលកើតទាំងមានភាពស្អាតស្អំ និង បរិសុទ្ធ ហើយសូម្បីតែ វិញ្ញាណថ្លៃថ្នូរ ហើយអស្ចារ្យក្ដី ក៏គ្មានវិញ្ញាណរបស់យើងណាមួយបានអភិវឌ្ឍទៅរកភាពល្អឥតខ្ចោះចំពោះសេចក្ដីពោរពេញផងព្រះគ្រីស្ទនៅឡើយដែរ ។ ភាពល្អឥតខ្ចោះនៃ

*នៅពេលពេត្រុសបានសម្លឹងមើលទៅព្រះអម្ចាស់ ហើយប្រព្រឹត្តិដោយសេចក្ដីជំនឿ នោះលោកមានអំណាចដើម្បីធ្វើអ្វីដែលលោកពុំអាចធ្វើដោយខ្លួនលោកផ្ទាល់—គឺការដើរលើទឹក ។ បទពិសោធន៍នោះបង្ហាញពីព្រះគុណរបស់ព្រះអម្ចាស់នៅក្នុងគ្រាដែលយើងត្រូវការ ។*

វិញ្ញាណអាចត្រូវបានស្វែងរកបានអំឡុងពេលនៃការរៀនសូត្រនៃជីវិតរមែងស្លាប់នេះ និង បទពិសោធន៍បន្ថែមទៀតនៃពិភពវិញ្ញាណ ប៉ុន្តែភាពល្អឥតខ្ចោះនៃវិញ្ញាណមិនទាន់បញ្ចប់ទាំងស្រុងនៅឡើយទេ រហូតដល់ការរស់ឡើងវិញ ។

ក្រៅពីភាពមិនល្អឥតខ្ចោះនាបច្ចុប្បន្ននេះនៃវិញ្ញាណរបស់យើង នោះរូបកាយរមែងស្លាប់របស់យើងក៏មិនល្អឥតខ្ចោះផងដែរ ។ ទោះបីវាជារឿងដែលគួរឲ្យចម្លែកចិត្តក្ដី រូបកាយរមែងស្លាប់របស់យើងនឹងត្រូវពុករលួយ ទ្រុឌទ្រោមទៅៗ ហើយស្លាប់ព្រមទាំងមានបំណងប្រាថ្នា ស្រេកឃ្លាន និង ដែលយើងមិនធ្លាប់ជួបប្រទះដូចកាលពីជីវិតមុខផែនដីឡើយ ។ នៅក្នុងស្ថានភាពបែបនេះ វាមានការលំបាកជាខ្លាំង ដើម្បីឲ្យរូបកាយចុះចូលនឹងឆន្ទៈនៃវិញ្ញាណទាំងស្រុងនោះ ។ ជាញឹកញាប់វិញ្ញាណមានទំនោរទៅតាមស្ថានភាពនៃរូបកាយ ។ វិញ្ញាណដ៏អស្ចារ្យមួយចំនួនដែលមកលើផែនដីនេះ មានការលំបាកដើម្បីបង្ក្រាបរូបកាយសាច់ឈាមរបស់ពួកគេ ។ នីហ្វៃបានស្រែកថា « ចិត្តខ្ញុំសោកសៅ ព្រោះតែសាច់ឈាមរបស់ខ្ញុំ ។ ខ្ញុំត្រូវបានហ៊ុមព័ទ្ធ ព្រោះតែការល្បួងទាំងឡាយ និងអំពើបាបទាំងឡាយដែលរំខានខ្ញុំដោយងាយ » ( នីហ្វៃទី ២ ៤:១៧, ១៨ សូមមើលផងដែរ ខទី ២៧ ) ។

ភាពពិតនៃជីវិតរមែងស្លាប់កាន់តែធ្វើឲ្យសង្គ្រាមរវាងវិញ្ញាណ និង រូបកាយកាន់តែមានការពិបាកខ្លាំងឡើង ។ រូបកាយសាច់ឈាមរបស់យើងត្រូវបានបង្កើតឡើងដោយធាតុនៃពិភពលោក « ដែលធ្លាក់ » ដោយផ្ដល់ដល់សាតាំងនូវ « អំណាចឲ្យចាប់ឃុំឃាំង » ( នីហ្វៃទី ២ ២:២៩ ) ។ ប្រធាន ព្រិកហាំ យ៉ង់ ( ឆ្នាំ ១៨០១–៧៧ ) បានធ្វើការអង្កេតដូចតទៅនេះ លោកបានមានប្រសាសន៍ដូចនេះ ៖ « សូមកុំគិតស្មានថា យើងដែលនៅក្នុងសាច់ឈាមនេះនឹងរួចផុតពីការល្បួងឲ្យធ្វើបាបនោះឡើយ ។ មានមនុស្សខ្លះស្មានថា នៅក្នុងសាច់ឈាមនេះ ពួកគេអាចត្រូវបានញែករូបកាយ និង វិញ្ញាណ ហើយប្រែជាបរិសុទ្ធ ដែលពួកគេនឹងមិនទទួលរងឥទ្ធិពលនៃអំណាចរបស់សាតាំងឡើយ ។ ប្រសិនបើមនុស្សម្នាក់ អាចទទួលបានកម្រិតនៃភាពល្អឥតខ្ចោះនេះនៅក្នុងសាច់ឈាម នោះគាត់មិនអាចស្លាប់ ហើយបន្តរស់នៅក្នុងពិភពលោកដែលមានឥទ្ធិពលនៃអំពើបាបនេះទេ ។ . . . ខ្ញុំគិតថាយើងនឹងកាន់តែទទួល ឬ កាន់តែគ្មានអារម្មណ៍ទទួលឥទ្ធិពលនៃអំពើបាប ដរាបណាយើងនៅមានជីវិតរស់នៅ ហើយទីបំផុតត្រូវឆ្លងកាត់នូវការសាកល្បងដែលជាសេចក្ដីស្លាប់ » ។[១]

### អំណាចនៃព្រះគុណរបស់ព្រះ

យើងត្រូវការអំណាចរបស់ព្រះ ដែលអាចផ្លាស់ប្រែព្រលឹងរបស់យើង រួមទាំងភាពទន់ខ្សោយ និង កង្វះខាតនាពេលបច្ចុប្បន្ននេះរបស់យើង ឲ្យទៅជាមានលក្ខណៈជាព្រះ ដោយរួមមានទាំងភាពខ្លាំងក្លា គុណធម៌ និង សមត្ថភាព ។ សំណាងល្អ អំណាចរបស់ព្រះបែបនេះបន្តនៅមាន វាគឺជាព្រះគុណនៃព្រះ ។ មានតែតាមរយៈអំណោយទានពិសិដ្ឋនៃព្រះគុណរបស់ព្រះប៉ុណ្ណោះដែលយើង « ត្រូវបានបន្ថែមឡើង » ( អ័ប្រាហាំ ៣:២៦ ) ដែលក្នុងពេលបែបនោះ ដែលយើងទទួលបានសេចក្ដីពោរពេញផងព្រះគ្រីស្ទ ។ ប្រាកដណាស់ នេះគឺពិតជារបៀបដែលព្រះបានទទួលសេចក្ដីពោរពេញរបស់ទ្រង់ ។

ដូចព្រះអម្ចាស់បានប្រាប់ដល់យ៉ូសែប ស្ម៊ីធថា « អ្នកណាដែលទទួលពន្លឺ ហើយនៅជាប់ក្នុងព្រះ នោះទទួលពន្លឺថែមទៀត ហើយពន្លឺនោះភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ » ( គ. និង ស. ៥០:២៤ ) ។ ប៉ុន្តែប្រសិនបើយើងធ្វើជាធម្មតា ទុកវាមួយអន្លើ ឬ ពង្រើយកន្តើយនឹងពរជ័យនៃសេចក្ដីមេត្តាករុណា ដែលយើងទទួលពីព្រះអម្ចាស់ នោះ « ការណ៍ដ៏ធំលើសលែងទៅទៀត នឹងពុំត្រូវបានសម្ដែង » ដល់ពួកយើងឡើយ ( នីហ្វៃទី ៣ ២៦:១០ ) ។ នៅក្នុងស្ថានភាពបែបនោះ

រូបគំនូរមកពី *THE SAVIOR WALKED ON WATER* ដោយ រ៉ូប៊ើត ធី បារ៉េត



យើងទទួល « ព្រះគុណរបស់ព្រះដោយបែបឥតប្រយោជន៍ » ( កូរិនថូសទី ២ ៦:១ ) ហើយទីបំផុត « ធ្លាក់ចេញពីព្រះគុណ » ( គ. និង ស. ២០:៣២ ) ទាំងអស់គ្នា ។

អ្វីៗទាំងអស់នេះផ្ដល់យោបល់ថា យើងត្រូវតែរៀនអត់ធ្មត់ជាមួយនឹងខ្លួនយើង និង ជាមួយអ្នកដទៃនៅក្នុងភាពទន់ខ្សោយ និង ភាពមិនល្អឥតខ្ចោះបច្ចុប្បន្នរបស់យើងនេះ ហើយយើងត្រូវតែរៀនតស៊ូនៅក្នុងដំណើរការសន្សឹមៗដែលមិនអាចចៀសរួចនោះនៃការរីកចម្រើនទៅរកភាពល្អឥតខ្ចោះ ។

*សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ*

ការយល់ដឹងពីរបៀបដែលព្រះគុណត្រូវបានប្រទានឲ្យ ជួយយើងឲ្យយល់ពីរបៀបដែលគោលការណ៍មួយចំនួន អាចធ្វើឲ្យព្រះគុណបំពេញក្នុងខ្លួនពួកយើងទាំងស្រុង ។ សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាគោលការណ៍ទីមួយដែលនាំពួកយើងទៅរកព្រះគុណ ( សូមមើល រ៉ូម ៥:១-២ ) ។ សេចក្ដីពិត សេចក្ដីសង្ឃឹម សកម្មភាព និង សាក្សីបញ្ជាក់គឺជាធាតុសំខាន់នៃសេចក្ដីជំនឿ ហើយគឺជាមាគ៌ាដើម្បីទទួលបានព្រះគុណរបស់ព្រះអម្ចាស់ ។

ឧទាហរណ៍ សូមពិចារណាពីបទពិសោធន៍របស់ពេត្រុសដែលបានដើរលើទឹកទៅរកព្រះអម្ចាស់ ។ ជាច្រើនលើកច្រើនគ្រា ដូចជារូបយើងផងដែរ ពេត្រុស និង ពួកសិស្សកំពុងនៅក្នុងព្យុះសមុទ្រ ។ ព្រះយេស៊ូវបានយាងមករកពួកលោក ដោយយាងដើរលើទឹក ហើយបង្គាប់ឲ្យពួកគេដើរមករកទ្រង់ ។ ដោយសេចក្ដីជំនឿ ពេត្រុសបានចុះចេញពីទូក ដើរទៅក្នុងរលកសមុទ្រឈូឆរ ហើយបានដើរទៅរកព្រះអម្ចាស់ ។ សេចក្ដីសង្ឃឹមរបស់លោកលើព្រះគ្រីស្ទ រួមផ្សំនឹងទង្វើនៃការប្ដេជ្ញាចិត្ត ធ្វើឲ្យលោកទទួលអំណាចនៃការដើរលើទឹក ។ ប៉ុន្តែ ដោយបានមើលទៅព្យុះនៅជុំវិញលោក នោះពេត្រុសមានមន្ទិលសង្ស័យ ហើយចាប់ផ្ដើមលិចចុះទៅក្នុងទឹក ។ លោកបានស្រែកឡើងថា « ព្រះអម្ចាស់អើយ សូមជួយសង្គ្រោះទូលបង្គំផង » ។ ជាចម្លើយឆ្លើយតបព្រះគម្ពីរកត់ត្រាថា « ស្រាប់តែព្រះយេស៊ូវទ្រង់លូកព្រះហស្តទៅចាប់គាត់ភ្លាម » ( ម៉ាថាយ ១៤:៣០–៣១ ) ។ នៅពេលពេត្រុសបានសម្លឹងមើលទៅព្រះអម្ចាស់ ហើយប្រព្រឹត្តិដោយសេចក្ដីជំនឿ នោះលោកមានអំណាចដើម្បីធ្វើអ្វីដែលលោកពុំអាចធ្វើដោយខ្លួនលោកផ្ទាល់—គឺការដើរលើទឹក ។

នៅពេលពេត្រុសពុំបានសម្លឹងមើលទៅព្រះអម្ចាស់ ហើយសង្ស័យ នោះពេត្រុសបានបំបែកខ្លួនលោកពីអំណាចនោះដោយទុកឲ្យនៅតែអំណាចខ្លួនឯង ហើយបានចាប់ផ្ដើមលិចចុះទៅក្នុងទឹក ។ សូមកត់សម្គាល់ឲ្យច្បាស់ពីការឆ្លើយតប

របស់ព្រះអម្ចាស់ចំពោះការស្រែករកជំនួយរបស់ពេត្រុស ។ « ស្រាប់តែ » ព្រះអម្ចាស់បានលាតព្រះហស្តទ្រង់សង្គ្រោះលោក ។ បទពិសោធន៍នោះបង្ហាញពីព្រះគុណរបស់ព្រះអម្ចាស់នៅក្នុងគ្រាដែលយើងត្រូវការ ។

*ការប្រែចិត្ត*

ការប្រែចិត្តជាគោលការណ៍ទីពីរដែលអាចធ្វើឲ្យព្រះគុណបំពេញក្នុងខ្លួនរបស់យើង ។ មរមនបានបង្រៀនដូចនេះ ៖ « មានពរហើយដល់អស់អ្នកណាដែលនឹងប្រែចិត្ត ហើយប្រុងស្ដាប់តាមសំឡេងនៃព្រះអម្ចាស់ជាព្រះរបស់គេ ព្រោះគឺគេទាំងនេះហើយដែលនឹងបានសង្គ្រោះ ។ ហើយសូមឲ្យព្រះប្រទាន . . . ឲ្យមនុស្សអាចបាននាំទៅកាន់ការប្រែចិត្ត និងកិច្ចការល្អទាំងឡាយ ដើម្បីឲ្យពួកគេអាចបានសាងឡើងវិញ ពីគុណមួយទៅគុណមួយ ស្របតាមកិច្ចការទាំងឡាយរបស់គេ » ( ហេលេមិន ១២:២៣–២៤ ) ។ ចេញពីខគម្ពីរនេះ វាបង្ហាញច្បាស់ថា ដួងចិត្តដែលប្រែចិត្ត និង កិច្ចការល្អគឺវាស្របគ្នានឹងព្រះគុណ ។

*សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាគោលការណ៍ទីមួយដែលនាំពួកយើងទៅរកព្រះគុណ ។ ការប្រែចិត្តជាគោលការណ៍ទីពីរដែលអាចធ្វើឲ្យព្រះគុណបំពេញក្នុងខ្លួនរបស់យើង ។*

សូមពិចារណាអំពីគំរូរបស់អាលម៉ាជាកូន ។ លោក និង បុត្រាទាំងឡាយរបស់ម៉ូសាយ « ជាមនុស្សដែលមានបាបទាំងឡាយ » ( ម៉ូសាយ ២៨:៤ ) ។ នៅពេលទេវតានៃព្រះអម្ចាស់បានបង្ហាញព្រះកាយដល់អាលម៉ា លោកបានប្រឈមមុខជាមួយនឹងអំពើបាប និង អំពើទុច្ចរិតទាំងអស់ក្នុងជីវិតលោក ។ នាគ្រានោះលោកបានប្រែជា « ញាំញីដោយសេចក្ដីទុក្ខវេទនាដ៏នៅអស់កល្បជានិច្ច » ( អាលម៉ា ៣៦:១២ ) ។ លោកបានមានប្រសាសន៍ថា « គ្រាន់តែគិតដល់ការចូលទៅក្នុងវត្តមាននៃព្រះរបស់ឪពុក ក៏បានញាំញីព្រលឹងឪពុកទៅហើយ ដោយសេចក្ដីរន្ធត់ដ៏មិនអាចថ្លែងបាន » ( អាលម៉ា ៣៦:១៤ ) ។ ប៉ុន្តែអាលម៉ាចងចាំថា ឪពុករបស់លោកបានមានប្រសាសន៍អំពីការយាងមកនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីមកធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក ។ ការចងចាំនេះធ្វើឲ្យលោករំជួលចិត្ត ដោយយំក្នុងចិត្តលោកថា « ឱព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំផង » ( អាលម៉ា ៣៦:១៨ ) ។ ស្រាប់តែលោក « ឈប់នឹកឃើញការឈឺចាប់ [ របស់លោក ] ទៀត ហើយក៏អស់កើតទុក្ខដោយការនឹកឃើញអំពើបាបរបស់ [ លោក ] ទៀតទៅ » ( អាលម៉ា ៣៦:១៩ ) ។

ព្រលឹងទុក្ខព្រួយដែលប្រែចិត្តរបស់អាលម៉ា បាននាំទៅរកអំណាចដែលសម្អាត និង ផ្លាស់ប្រែលោកឲ្យក្លាយទៅជាសត្វលោកថ្មី ។ លោកឈប់ចង់ព្យាយាមបំផ្លិចបំផ្លាញសាសនាចក្ររបស់ព្រះទៀតហើយ ។ ផ្ទុយទៅវិញ អស់មួយជីវិតរបស់លោកអាលម៉ាបានធ្វើការ ដើម្បីស្ថាបនាសាសនាចក្រឡើង ដោយជួយដល់មនុស្សដទៃឲ្យប្រែចិត្ត ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ ។ ការប្រែចិត្តជឿរបស់អាលម៉ាជាកូនពីមនុស្សដែលមានបាបទាំងឡាយ ទៅជាព្យាការីរបស់ព្រះ គឺជាគំរូមួយដ៏អស្ចារ្យអំពីអំណាចនៃព្រះគុណរបស់ព្រះអម្ចាស់ ដើម្បីរាប់ទុកជាសុចរិត និង ញែកពួកយើងម្នាក់ៗ ។

*ភាពទាបរាបសា*

គោលការណ៍ទីបីគឺភាពទាបរាបសា ។ ព្រះអម្ចាស់បានបង្រៀនមរ៉ូណៃថា « គុណរបស់យើង មានគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ ដែលបន្ទាបខ្លួននៅចំពោះយើង ដ្បិតបើសិនជាពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយមានសេចក្ដីជំនឿជឿដល់យើង លំដាប់នោះយើងនឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះពួកគេវិញ » ( អេធើរ ១២:២៧ ) ។ ការធ្វើឲ្យអ្វីដែលទន់ខ្សោយប្រែទៅជាខ្លាំងគឺជាកិច្ចការនៃព្រះគុណ ។

ប្រសិនបើភាពទាបរាបសាមានភាពចាំបាច់ នោះយើងគួរនិយាយអំពីអ្វីដែលជាភាពទាបរាបសា ។ និយាយឲ្យខ្លីទៅ ភាពទាបរាបសាគឺជាឆន្ទៈចុះចូលរបស់បុគ្គលម្នាក់ទៅនឹងព្រះទ័យរបស់ព្រះ និង ការថ្វាយកិត្តិយសដល់ទ្រង់ សម្រាប់អ្វីដែលបានសម្រេចមក ។ ក្នុងស្មារតីនេះ ព្រះយេស៊ូវគ្រីស្ទជាគំរូដ៏ល្អបំផុតរបស់យើង ។ ភាពទាបរាបសា និង ការចុះចូលរបស់

ទ្រង់បានបង្ហាញយ៉ាងល្អឥតខ្ចោះ អំឡុងពេលពលិកម្មធួនរបស់ទ្រង់ ។ ព្រះយេស៊ូវបានអធិស្ឋានថា « ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពីទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ » ( ម៉ាថាយ ២៦:៣៩ ) ។ ភាពពោរពេញនៃព្រះគុណរបស់ព្រះបានបំពេញក្នុងព្រះគ្រីស្ទនៅក្នុងឱកាសនេះឯង ។

***សេចក្តីឧស្សាហ៍***

គោលការណ៍ទីបួនគឺភាពឧស្សាហ៍ព្យាយាម ។ ដូចនីហ្វៃបានបង្រៀនប្រជាជនរបស់លោក « មានតែដោយព្រះគុណទេ ទើបយើងបានសង្គ្រោះបន្ទាប់ពីអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន » ( នីហ្វៃទី ២ ២៥:២៣ ) ។ អ្នកខ្លះពេលអានខគម្ពីរនេះហើយគិតថា ព្រះគុណរបស់ព្រះត្រូវបានសម្តែងឡើង លុះត្រាយើងខំប្រឹងឲ្យអស់ពីសមត្ថភាពរបស់យើង ។ ខ្ញុំមិនយល់វាតាមរបៀបនេះឡើយ ។ មានឧទាហរណ៍សាមញ្ញជាច្រើនអំពីព្រះគុណរបស់ព្រះដែលបានប្រទានដល់មនុស្ស ដោយបុគ្គលនោះពុំបានធ្វើអ្វីសោះឡើយ ។ ឧទាហរណ៍ អំណាចនៃការរស់ឡើងវិញ ត្រូវបានប្រទានដល់មនុស្សទាំងអស់ដោយសារព្រះគុណនៃព្រះ ដោយមិនគិតពីកិច្ចខិតខំរបស់បុគ្គលម្នាក់ៗឡើយ ។ ខ្ញុំយល់ពីពាក្យរបស់នីហ្វៃដែលថា « អ្វីៗទាំងអស់ដែលយើងអាចធ្វើ » មានន័យថា ព្រះគុណនៃព្រះត្រូវបានប្រទានដល់ពួកយើង នៅពេលយើងមានសេចក្តីឧស្សាហ៍ព្យាយាម ។ ដូចអែលឌើរ ប្រ៊ុស ស៊ី ហាហ្វេន អតីតសមាជិកនៃពួកចិតសិបនាក់បានសរសេរថា « អំណោយទាននៃព្រះគុណរបស់ព្រះអង្គសង្គ្រោះចំពោះពួកយើងមិនចាំបាច់តែក្នុងការកំណត់ថា ‹ បន្ទាប់ពី › គ្រប់អ្វីៗទាំងអស់ដែលយើងអាចធ្វើនោះទេ ។ យើងអាចទទួលបានព្រះគុណរបស់ទ្រង់ មុនពេល អំឡុងពេល និង បន្ទាប់ពីពេលដែលយើងធ្វើការខិតខំផ្ទាល់ខ្លួនរបស់យើងទៅទៀត » ។[២]

សូមពិចារណាពីគំរូនៃបងរបស់យ៉ារេឌ ។ លោកត្រូវបានបង្គាប់ឲ្យសង់ភេត្រា ហើយជិះវាឆ្លងកាត់មហាសមុទ្រ ។ មួយជំហានម្តងៗ បងរបស់យ៉ារេឌមានចិត្តឧស្សាហ៍ព្យាយាមក្នុងការធ្វើតាមការបង្គាប់របស់ព្រះអម្ចាស់ ។ នៅពេលលោកបានសង់ភេត្រារួច បងរបស់យ៉ារេឌបានខ្វល់ពីភាពងងឹតនៅក្នុងភេត្រា ហើយបានទូលសុំដល់ព្រះអម្ចាស់ឲ្យប្រទានពន្លឺដល់ពួកគេ ។ ខណៈដែលព្រះអម្ចាស់អាចប្រទានមធ្យោបាយរួចជាស្រេចដល់បងរបស់យ៉ារេឌ ផ្ទុយទៅវិញទ្រង់បានសួរថា « តើអ្នកចង់ឲ្យយើងធ្វើអ្វី ដើម្បីឲ្យអ្នកមានពន្លឺនៅក្នុងភេត្រាទាំងឡាយរបស់អ្នក ? » ( អេធើរ ២:២៣ ) ។ នៅក្នុង



ដកស្រង់ចេញពី អាលម៉ាដឹងខ្លួនឡើងវិញ ដោយ វ៉លធើរ រ៉ាណេ ហាមថតចម្លង



ការឆ្លើយតបវិញ បងរបស់យ៉ារេឌបានរៀបចំ ក្រួស ១៦ ដុំ ដាក់បង្ហាញដល់ព្រះអម្ចាស់ ហើយបានទូលសូមឲ្យព្រះអម្ចាស់ពាល់វាប្រយោជន៍ « ឲ្យវាអាចបានភ្លឺចែងចាំងក្នុងទីងងឹត » ( សូមមើល អេធើរ ៣:១–៤ ) ។

បងរបស់យ៉ារេឌពុំបានបំពេញគ្រប់កិច្ចការទាំងអស់ដែលព្រះអម្ចាស់បានប្រទានឲ្យលោកធ្វើឡើយ ប៉ុន្តែព្រះអម្ចាស់បានប្រទានព្រះចេស្ដារបស់ទ្រង់ជំនួសឲ្យបងរបស់យ៉ារេឌ ដោយពាល់ក្រួសនីមួយៗ ហើយធ្វើឲ្យក្រួសនោះមានពន្លឺដែលចាំបាច់សម្រាប់ការធ្វើដំណើរតាមសមុទ្រដោយបានគិតគូរទុកជាមុន ។ នៅក្នុងការធ្វើដូច្នោះ ព្រះអម្ចាស់បានបង្ហាញព្រះទ័យ និងភាពត្រៀមរួចជាស្រេចរបស់ទ្រង់ ដើម្បីប្រទានអំណាចជាព្រះរបស់ទ្រង់ដល់ពួកយើង នៅពេលយើងឧស្សាហ៍ព្យាយាមធ្វើកិច្ចការឲ្យអស់ពីសមត្ថភាពរបស់យើង ។

*ការគោរពប្រតិបត្តិ*

គោលការណ៍ទីប្រាំគឺការគោរពប្រតិបត្តិ ។ ព្រះអម្ចាស់បានមានបន្ទូលថា « ដ្បិតបើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នកនឹងបានទទួលព្រះគុណថែមលើព្រះគុណ » ( គ. និង ស. ៩៣:២០ ) ។ ម៉ូរ៉ូណៃបានសរសេរបែបនេះ ៖ « បើសិនជាអ្នករាល់គ្នានឹងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក នោះព្រះគុណរបស់ទ្រង់ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ » ( ម៉ូរ៉ូណៃ ១០:៣២ ) ។

ដោយពុំបន្ទាបបន្ថោកការបញ្ជារបស់ព្រះអម្ចាស់ ឲ្យរក្សាបទបញ្ញត្តិ ឬ ការបង្គាប់របស់ម៉ូរ៉ូណៃឲ្យយើងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ នោះយើងគប្បីយល់ថា ព្រះគុណគឺមិនពឹងផ្អែកលើការគោរពតាមដ៏ឥតខ្ចោះរបស់យើងឡើយ ។ ប្រសិនបើព្រះគុណពឹងផ្អែកលើការគោរពបទបញ្ញត្តិឲ្យល្អឥតខ្ចោះរបស់យើង ឬ ការលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធរបស់យើងធ្វើបានល្អឥតខ្ចោះ នោះភាពមិនល្អឥតខ្ចោះដែលនៅជាប់នឹងយើងក្នុងជីវិតរមែងស្លាប់នេះ នឹងរារាំងយើងពីការទទួលបានព្រះគុណជារៀងរហូត ។ លើសពីនេះទៀត ព្រះគុណមានបំណងធ្វើឲ្យយើងអាចកាន់តែរក្សាបទបញ្ញត្តិបានល្អឥតខ្ចោះ ហើយរស់នៅកាន់តែដូចជាព្រះគ្រីស្ទ រហូតយើងបានដល់កំពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ ។

ការបញ្ជារបស់ព្រះអម្ចាស់ ឲ្យរក្សាបទបញ្ញត្តិ ឬ ការបង្គាប់

របស់មរ៉ូណៃឲ្យយើងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ ត្រូវយល់ថា ធ្វើកិច្ចការទាំងនេះដោយអស់ពីសមត្ថភាពរបស់យើង ។ ខណៈដែលទង្វើរបស់យើងវាសំខាន់ នោះចេតនានៃចិត្តរបស់យើងកាន់តែសំខាន់ជាងនេះទៅទៀត ។

***ការទទួលព្រះវិញ្ញាណបរិសុទ្ធ និង ការស្វែងរកអំណោយទាននៃព្រះវិញ្ញាណ***

គោលការណ៍ចុងក្រោយគឺ ការទទួលព្រះវិញ្ញាណបរិសុទ្ធ និង ការស្វែងរកអំណោយទាននៃព្រះវិញ្ញាណ ( សូមមើល ម៉ូសាយ ១៨:១៦ ) ។ ប្រាកដណាស់ យើងត្រូវបានបំពេញដោយព្រះគុណនៃព្រះ នៅពេលយើងទទួលព្រះវិញ្ញាណបរិសុទ្ធ ដ្បិតព្រះវិញ្ញាណបរិសុទ្ធនេះហើយដែលផ្តល់ និង ប្រទានដល់យើងនូវអំណាចនៃការញែក ការធ្វើទៅបាន និង ភាពល្អឥតខ្ចោះរបស់ព្រះ ។

ទាក់ទងនឹងរឿងនេះ អែលឌើរ ប៉ាលី ភី ប្រាត្ត ( ឆ្នាំ ១៨០៧–៥៧ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនដូចតទៅនេះ ៖ « អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ. . .ដាស់រាល់ប្រាជ្ញាញាណ បង្កើន ពង្រីក ពន្លាត បន្សុទ្ធរាល់តណ្ហា និងការស្រឡាញ់ ហើយសម្របពួកគេ តាមរយៈអំណោយទាននៃប្រាជ្ញា ចំពោះការប្រើប្រាស់ស្របច្បាប់របស់ពួកគេ ។ ព្រះវិញ្ញាណបំផុស អភិវឌ្ឍ បណ្តុះ និងធ្វើឲ្យមានភាពចាស់ទុំក្នុងការដុសខាត់ចិត្តឲ្យល្អ ក្តីអំណរ រសជាតិ អារម្មណ៍សាច់ញាតិ និងក្តីស្រឡាញ់ពីកំណើតរបស់យើង ។ ព្រះវិញ្ញាណបំផុសឲ្យមានគុណធម៌ ចិត្តល្អ សេចក្តីល្អ ភាពទន់ភ្លន់ ភាពផ្អែមល្ហែម និងសប្បុរស ។ ព្រះវិញ្ញាណអភិវឌ្ឍសម្រស់រូបរាង និងលក្ខណៈរបស់មនុស្ស ។ ព្រះវិញ្ញាណប្រទានសុខភាព កម្លាំង ជីវចល និងអារម្មណ៍មានទំនាក់ទំនងក្នុងសង្គម ។ ព្រះវិញ្ញាណធ្វើឲ្យមានភាពរឹងមាំដល់សមត្ថភាពនៃរាងកាយ និងបញ្ញាមនុស្ស ។ ព្រះវិញ្ញាណពង្រឹង ហើយផ្តល់កម្លាំងទៅកាន់សរសៃប្រសាទ ។ សរុបសេចក្តីទៅ ព្រះវិញ្ញាណជាខួរឆ្អឹង ជាអំណរដល់ដួងចិត្ត ជាពន្លឺដល់កែវភ្នែក តន្ត្រីដល់ត្រចៀក និងជីវិតដល់រូបរាងកាយទាំងមូល » ។[៣]

ពរជ័យទាំងនោះកើតឡើងចំពោះយើង នៅពេលយើងទទួលព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់របស់យើង ។ អែលឌើរ អ្សូរសុន ប្រាត្ត ( ឆ្នាំ ១៨១១–៨១ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « នៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធមាននៅក្នុងខ្លួនមនុស្សម្នាក់ វាពុំគ្រាន់តែសម្អាត ញែកឲ្យបរិសុទ្ធ ហើយធ្វើឲ្យគាត់បរិសុទ្ធប៉ុណ្ណោះទេ តែគាត់ទទួលបាននូវឥទ្ធិពលដល់ខ្លួនគាត់ ក៏ផ្តល់ឲ្យនូវអំណោយទានមួយចំនួន ដែលសម្រាប់ជាប្រយោជន៍របស់គាត់ និងមនុស្សផ្សេងទៀតផងដែរ ។ . . . អំណោយទានខាងវិញ្ញាណទាំងនេះ គឺត្រូវបានប្រទានឲ្យដល់សមាជិកនៃសាសនាចក្រ ស្របតាមសេចក្តីស្មោះត្រង់ កាលៈទេសៈ សមត្ថភាពពីធម្មជាតិ កាតព្វកិច្ច និងការហៅបម្រើទាំងឡាយរបស់ពួកគេ ដើម្បីមនុស្សទាំងអស់ អាចត្រូវបានណែនាំដោយត្រឹមត្រូវ បានបញ្ជាក់ បានធ្វើឲ្យល្អឥតខ្ចោះ និងបានសង្គ្រោះ » ។[៤]

**ភាពល្អមគ្រប់គ្រាន់របស់ព្រះគុណនៃព្រះ**

ព្រះយេស៊ូវគ្រីស្ទពោរពេញដោយព្រះគុណ ។ ព្រះគ្រីស្ទបានទទួលព្រះគុណរបស់ទ្រង់ដ៏បរិបូរមកពីព្រះវរបិតាទ្រង់ ហើយបានធ្វើឲ្យមាន « ព្រះគុណថែមលើព្រះគុណ » ( គ. និង ស. ៩៣:១២ ) ។ តាមរបៀបនោះ យើងទទួលព្រះគុណថែមលើព្រះគុណ ។ យើងនឹងត្រូវបានប្រទានឲ្យនូវគ្រប់ចរិតលក្ខណៈ និង បុគ្គលិកលក្ខណៈរបស់ព្រះ ។ ទីបំផុត អំណាចនៃព្រះគុណដែលអាចធ្វើទៅរួច និង អំណាចនៃភាពល្អឥតខ្ចោះ អាចកើតមានតាមរយៈគោលការណ៍នៃសេចក្តីជំនឿ ការប្រែចិត្ត ភាពទាបរាបសា សេចក្តីឧស្សាហ៍ព្យាយាមការគោរពប្រតិបត្តិ និង ការស្វែងរកព្រះវិញ្ញាណ និង អំណោយទាននៃព្រះវិញ្ញាណ ។

ព្រះគុណរបស់ព្រះអម្ចាស់គឺមានគ្រប់គ្រាន់ ដើម្បីលើកស្ទួយបងប្អូនឡើងចេញពីសេចក្តីស្លាប់ និងអំពើបាប ហើយផ្តល់ជីវិតអស់កល្បជានិច្ចដល់បងប្អូន ។ វាគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរបងប្អូន ផ្លាស់ប្រែបងប្អូន និង ធ្វើឲ្យបងប្អូនបានល្អឥតខ្ចោះ ។ វាគ្រប់គ្រាន់អាចធ្វើឲ្យបងប្អូន ដឹងទាំងស្រុងពីសក្តានុពលនៃភាពជាព្រះរបស់បងប្អូនក្នុងនាមជាបុត្រា ឬ បុត្រីរបស់ព្រះ ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋានមួយនៃប្រព័ន្ធអប់រំសាសនាចក្រ « ព្រះគុណរបស់ទ្រង់ល្អមគ្រប់គ្រាន់សម្រាប់អ្នក » បានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់-ហាវ៉ៃ នៅថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ។ សម្រាប់សុន្ទរកថាទាំងមូល សូមចូលទៅគេហទំព័រ devotional.byuh.edu ។*

*ព្រះគុណរបស់ព្រះអម្ចាស់គឺមានគ្រប់គ្រាន់ ដើម្បីលើកស្ទួយបងប្អូនឡើងចេញពីសេចក្តីស្លាប់ និងអំពើបាប ហើយផ្តល់ជីវិតអស់កល្បជានិច្ចដល់បងប្អូន ។ ព្រះគុណមានភាពល្អមគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរបងប្អូន ប្រែបងប្អូន និង ធ្វើឲ្យបងប្អូនបានល្អឥតខ្ចោះ ។*

**កំណត់ចំណាំ**

១. ព្រិកហាំ យ៉ង់ នៅក្នុង *Deseret News* ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៨៦៣ ។
២. ប្រ៊ូស ស៊ី ហាហ្វេន *The Broken Heart: Applying the Atonement to Life's Experiences* ( ឆ្នាំ ១៩៨៩ ) ទំព័រ ១៥៥–៥៦ ។
៣. ប៉ាលី ភី ប្រាត្ត *Key to the Science of Theology: A Voice of Warning* ( ឆ្នាំ ១៩៧៨ ) ទំព័រ ៦១ ។
៤. អ្សូរសុន ប្រាត្ត នៅក្នុង *Masterful Discourses and Writings of Orson Pratt* comp. N. Lundwall ( ឆ្នាំ ១៩៦២) ទំព័រ ៥៧០, ៥៧១ ។




*ជ័រ អូទ្បែនដូ ខុកកូ សាន់តាន់ហ្គេឡូ ការហៅ ( សូមមើល ម៉ាថាយ ៤:១៩–២០ ) ប្រទេស អាហ្សង់ទីន ជាអ្នកទទួលបានពាន់រង្វាន់ជ័យលាភី*

ការប្រកួតរូបគំនូរជាអន្តរជាតិលើកទី ១០ ៖

សូមប្រាប់ខ្ញុំពីរឿង

# ព្រះយេស៊ូវ

*សាប្រីណា ដឹល ស្គាយអើរ អាហារយប់ថ្ងៃចុងក្រោយ ( សូមមើល យ៉ូហាន ១៣:១–៣៥ ) សហរដ្ឋអាមេរិក*



ខាងក្រោមនេះគឺជាគំរូនៃរូបគំនូរ មកពីការប្រកួតរូបគំនូរជាអន្តរជាតិលើកទី ១០ ដែលត្រូវបានដាក់តាំងពិពណ៌នាពេលថ្មីៗនេះនៅសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រនៅក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ រូបគំនូរចំនួនកៅសិបប្រាំបីផ្ទាំងត្រូវបានជ្រើសរើសមកពីរូបគំនូរទាំង ៩៤៤ ដែលបានដាក់ប្រកួត មកពី ៤០ ប្រទេសនៅជុំវិញពិភពលោក ។ វិចិត្រករអាចជ្រើសរើសដំណើររឿងណាមួយអំពីជីវិតរបស់ព្រះអង្គសង្គ្រោះរបស់ពួកយើង គឺព្រះយេស៊ូវគ្រីស្ទធ្វើជាប្រធានបទក្នុងការគូរគំនូររបស់ពួកគេ ។ ការបកស្រាយអំពីរឿងទាំងនេះត្រូវបានដាក់តាំងបង្ហាញនៅក្នុងការផាត់ពណ៌ ការគូរគំនូរ ការឆ្លាក់ ការដេរប៉ាក់ រូបគំនូរលាបពណ៌លើកញ្ចក់ និង រូបឌីជីថល ។

អ្នកអាចមើលការតាំងពិពណ៌នេះតាមអ៊ិនធើរណែតនៅគេហទំព័រ lds.org/go/10art ។

*មេហ្គេន រ៉ុស ហ្គេត ពួកយើងមកថ្វាយបង្គំទ្រង់ ( សូមមើល ម៉ាថាយ ២:១-២ ) សហរដ្ឋអាមេរិក*



*ម៉ៃយល ម៉ាម នៅជាមួយព្រះ ( សូមមើល ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ ម៉ាថាយ ៤:១ [ នៅក្នុង ម៉ាថាយ ៤:១ ] ) សហរដ្ឋអាមេរិក ជាអ្នកទទួលបានពាន់រង្វាន់ជ័យលាភី*



*រ៉ូប៊ីន ប៊ើរ៉ែល នាងបានដុំនំប៉័ង និង ឆ្អើរត្រី ( សូមមើល យ៉ូហាន ៦:៩–១៤ ) សហរដ្ឋអាមេរិក*

*រ៉ុប អាដាមសុន ភ្នំប្រែរូប ( សូមមើល ម៉ាថាយ ១៧:២ ) សហរដ្ឋអាមេរិក*







អែលស្ពែស្ស យាំង ចៀមដទៃទៀតដែលយើងមាន ( សូមមើល យ៉ូហាន ១០:១៦ ) សហរដ្ឋអាមេរិក



ខាតលីន ម៉ាក្សហៀល ខុនណូលី ស្រ្តីដ៏មានជំនឿ ( សូមមើល ម៉ាថាយ ៩:២២ ) សហរដ្ឋអាមេរិក ជាអ្នកទទួលបានពានរង្វាន់ជ័យលាភី

អ៊ីរីន មៀតស៍ អ្វីៗទាំងអស់នៃជីវិតគាត់ ៖ ប្រាក់ស្លឹងរបស់ស្រ្តីមេម៉ាយ ( សូមមើល ម៉ាកុស ១២:៤៤ ) សហរដ្ឋអាមេរិក



ម៉ាធ្យូ ហៃរុម ឌែល ផែនការនៃសេចក្តីសង្គ្រោះ ( សូមមើល យ៉ូហាន ៣:១៦ ) ប្រទេសអូស្ត្រាលី



*មែយល ដាយអែន អនយ៉ុន អ្នកគង្វាលល្អ ( សូមមើល លូកា ១៥:៤ ) សហរដ្ឋអាមេរិក*



*ខាស្សលីន ភីធើរសុន ព្រះយេស៊ូវ និង ស្ត្រីដែលនាំមកកាត់ទោស ( សូមមើល យ៉ូហាន ៨:១១ ) សហរដ្ឋអាមេរិក*





ក្លាក ខេលី ប្រៃស៍ មនុស្សនេះប្រាកដជាព្រះរាជបុត្រានៃព្រះមែន ( សូមមើល ម៉ាកុស ១៥:៣៩ ) សហរដ្ឋអាមេរិក

ឡេស្ទើរ លី យូខុម នៅក្នុងសួនច្បារ ( សូមមើល ម៉ាថាយ ២៦:៣៦-៣៩ ) សហរដ្ឋអាមេរិក





កាស្សូកូ ខូរីងតុន ពិភពលោកដ៏ច្រើនឥតគណនា ( សូមមើល ម៉ូសេ ២ ) ប្រទេស ជប៉ុន



ដានីយ៉ែល អាលម៉ា វីលសុន ពន្លឺនៅក្នុងទីងងឹត ( សូមមើល យ៉ូហាន ៨:១២ ) សហរដ្ឋអាមេរិក



**ដោយអែលឌើរ អិម រ័សុល បាឡឹង**

ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ដោយការសិក្សា និង ដោយសេចក្ដីជំនឿ

*សូមឲ្យអ្នកមានអំណរ និងភាពសុខសាន្តដែលកើតមានមកពីការដឹងថា តាមរយៈការបង្រៀនរបស់អ្នក នោះអ្នកបានជះឥទ្ធិពលដល់ជីវិតរបស់បុគ្គលម្នាក់ ហើយបានជួយលើកស្ទួយដល់កូនម្នាក់របស់ព្រះវរបិតាសួគ៌ នៅលើដំណើររបស់ពួកគេ ត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់វិញ ។*

នៅក្នុងការប្រជុំបំពាក់បំប៉នអ្នកមានសិទ្ធិអំណាចទូទៅមួយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានមានប្រសាសន៍ទាក់ទងនឹងការបង្រៀនអំពីគោលលទ្ធិសាសនាចក្រដូចនេះ ៖ « យើងត្រូវតែមានការប្រុងប្រយ័ត្នជាខ្លាំង ។ យើងត្រូវតែមើលថា យើងមិនចាកចេញពី [ ផ្លូវ ] ឡើយ ។ នៅក្នុងការខិតខំរបស់យើងដើម្បីស្ថិតនៅក្នុងភាពដើម ស្រស់ស្រាយ និង ភាពខុសប្លែកពីគេ នោះយើងអាចនឹងមិនបង្រៀនរឿងដែលត្រូវគ្នាទាំងស្រុងនឹងគោលលទ្ធិគ្រឹះរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញនេះ ។ . . . យើងត្រូវតែយកចិត្តទុកដាក់បន្ថែមទៀត ។ . . . យើងត្រូវតែធ្វើជាអ្នកយាមនៅលើប៉ម » ។[១]

នៅពេលការអប់រំរបស់សាសនាចក្រឆ្ពោះទៅមុខនៅក្នុងសតវត្សរ៍ទី ២១ គ្រូបង្រៀនរបស់យើងចាំបាច់ត្រូវពិចារណាអំពីការផ្លាស់ប្ដូរនានា ដែលពួកគេគួរធ្វើក្នុងរបៀប ដែលពួកគេរៀបចំដើម្បីបង្រៀន របៀបដែលពួកគេបង្រៀន និងអ្វីដែលពួកគេបង្រៀន ប្រសិនបើពួកគេចង់ស្ថាបនាសេចក្ដីជំនឿដ៏ខ្ជាប់ខ្ជួន នៅក្នុងជីវិតរបស់យុវវ័យដ៏មានតម្លៃរបស់យើង ។

ពេលវេលាកន្លងផុតទៅហើយ ពេលសិស្សម្នាក់បានសួរសំណួរស្មោះត្រង់មួយ ហើយគ្រូបង្រៀនបានឆ្លើយតបថា « កុំបារម្ភអំពីវា ! » ពេលវេលាកន្លងផុតទៅហើយ ពេលសិស្សម្នាក់បានលើកចម្ងល់ដោយស្មោះឡើង រួចគ្រូបង្រៀនថ្លែងទីបន្ទាល់របស់គាត់ ជាចម្លើយមួយដើម្បីចៀសវាងពីបញ្ហា ។ ពេលវេលាកន្លងផុតទៅហើយ ពេលសិស្សត្រូវបានការពារពីមនុស្សដែលវាយប្រហារលើសាសនាចក្រ ។

---

*នៅក្នុងសុន្ទរកថាទាំងនេះ ដែលថ្លែងទៅកាន់គ្រូបង្រៀនសាសនា ក្នុងប្រព័ន្ធអប់រំរបស់សាសនាចក្រ អែលឌើរ បាឡឹដ បានចែកចាយគោលការណ៍ និង ការទូន្មានដែលអនុវត្តចំពោះអស់អ្នកដែលបង្រៀននៅក្នុងសាសនាចក្រ ។*



សំណាងល្អ ព្រះអម្ចាស់បានប្រទានការទូន្មាននេះដល់គ្រូបង្រៀនទាក់ទងនឹងគ្រានេះ និង គ្រាផ្សេងទៀត ៖ « ហើយដូចជាមនុស្សពុំមានសេចក្ដីជំនឿទាំងអស់គ្នា នោះចូរអ្នករាល់គ្នាព្យាយាមស្វែងរក ហើយបង្រៀនគ្នាទៅវិញទៅមក នូវពាក្យសម្ដីនៃប្រាជ្ញាវាងវៃ មែនហើយ ចូរអ្នករាល់គ្នាស្វែងរកពាក្យសម្ដីនៃប្រាជ្ញាវាងវៃចេញពីសៀវភៅដ៏ល្អៗបំផុត ចូរស្វែងរក ការរៀនសូត្រ ដោយសារការសិក្សា និង ដោយសារសេចក្ដីជំនឿផង » ( គ. និង ស. ៨៨:១១៨ ) ។

ជាពិសេស រឿងនេះអនុវត្តនាសព្វថ្ងៃនេះ ពីព្រោះមិនមែនគ្រប់សិស្សរបស់អ្នកមានសេចក្ដីជំនឿចាំបាច់ដើម្បីប្រឈមមុខនឹងឧបសគ្គដែលនៅខាងមុខនោះទេ ដោយសារមានពួកគេជាច្រើនបានជួបនឹងកម្លាំងបំផ្លាញកាន់តែខ្លាំងនៃលោកិយរួចទៅហើយ តាមអ៊ិនធើរណែតដែលវាជាសត្រូវនឹងសេចក្ដីជំនឿ គ្រួសារ និងបទដ្ឋានដំណឹងល្អ ។ អ៊ិនធើរណែតកំពុងតែពង្រីកឥទ្ធិពលរបស់វានៅទូទាំងពិភពលោកស្ទើរតែគ្រប់ផ្ទះ និង គ្រប់ដៃ គ្រប់គំនិតរបស់សិស្សយើង ។

អ្នកអាចជួយសិស្សដោយការបង្រៀនពួកគេអំពីអត្ថន័យនៃការបញ្ចូលរួមគ្នានូវការសិក្សាជាមួយនឹងសេចក្ដីជំនឿ នៅពេលពួកគេរៀន ។ បង្រៀនពួកគេតាមរយៈការបង្ហាញជាគំរូនូវជំនាញ និង មធ្យោបាយនេះក្នុងថ្នាក់រៀន ។

ប្រធាន ហារ៉ូល ប៊ី លី ( ឆ្នាំ ១៨៩៩–១៩៧៣ ) បានសង្កេតឃើញដូចនេះ ៖

« យើងនឹងរំឭកបងប្អូនថា តម្រូវការឲ្យមានចំណេះដឹងដោយសេចក្ដីជំនឿ គឺពុំមែនជាផ្លូវងាយស្រួលដើម្បីរៀនសូត្រនោះទេ ។ វាត្រូវការការខិតខំយ៉ាងខ្លាំង ហើយព្យាយាមជាបន្តបន្ទាប់ដោយសេចក្ដីជំនឿ ។ . . .

« ការរៀនសូត្រដោយសេចក្ដីជំនឿ គឺពុំមែនជាកិច្ចការសម្រាប់បុរស [ ឬ ស្ត្រី ] ខ្ជិលច្រអូសនោះទេ ។ មានមនុស្សម្នាក់បាននិយាយថា ដំណើរការដូច្នេះតម្រូវឲ្យមានការចុះចូលនៃព្រលឹងទាំងមូល ដែលតភ្ជាប់គំនិត និង អារម្មណ៍ក្នុងខ្លួនមនុស្សទៅនឹងព្រះ—ទំនាក់ទំនងត្រឹមត្រូវត្រូវតែបង្កើតឡើង ។ បន្ទាប់ពីនោះទើបកើតមាននូវ ‹ ចំណេះដឹងដោយសេចក្ដីជំនឿ › » ។[២]

ចំណេះដឹងដោយសេចក្ដីជំនឿនឹងបង្កើតជាទីបន្ទាល់បរិសុទ្ធ ហើយទីបន្ទាល់បរិសុទ្ធមានអំណាចផ្លាស់ប្ដូរជីវិតដូចបានបង្ហាញក្នុងរឿងសង្ខេបដូចតទៅនេះ ។

**រឿងបី**

ហ្វីប៊ី ខាធើរ បានចាកចេញពីផ្ទះរបស់នាងនៅក្នុងរដ្ឋ ម៉ែន ស.រ.អា. ដើម្បីទៅជួបជុំនឹងពួកបរិសុទ្ធនៅរដ្ឋ អូហៃអូក្នុងទសវត្សរ៍ឆ្នាំ ១៨៣០ ។ គាត់បានរំឭកថា « មិត្តរបស់ខ្ញុំស្ងើចចំពោះដំណើរជីវិតខ្ញុំ ហើយខ្ញុំក៏ស្ងើចខ្លួនឯងដែរ ប៉ុន្តែមានអ្វីមួយក្នុងខ្លួនខ្ញុំដែលជម្រុញឲ្យខ្ញុំធ្វើវា ។ ភាពសោកសៅរបស់ម្ដាយខ្ញុំ នៅពេលយើងចាកចេញពីផ្ទះ គឺជាភាពសោកសៅមួយដែលខ្ញុំស្ទើរតែមិនអាចទ្រាំទ្របាន ប៉ុន្តែបើមិនដោយសារវិញ្ញាណនៅខាងក្នុងនោះទេ ខ្ញុំនឹងមានភាពរអាក់រអួលជាពុំខានឡើយ » ។[៣]

ហ្វីប៊ី បានធ្វើតាមព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានជួបជុំនឹងពួកបរិសុទ្ធនៅរដ្ឋ

អូហៃអូ ហើយទីបំផុតនៅរដ្ឋយូថាហ៍ ជាកន្លែងដែលគាត់ទទួលមរណភាពក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយស្មោះត្រង់ ហើយបានទទួលនឹមស្មើគ្នាក្នុងនាមជាភរិយារបស់ប្រធានសាសនាចក្រ វិលហ្វូឌ វូឌរ៉ុហ្វ ( ឆ្នាំ ១៨០៧–៩៨ ) ។

ក្នុងនាមជានិសិត្សនៅមហាវិទ្យាល័យ ម៉ារ៉ុន ជី រ័មនី ( ឆ្នាំ ១៨៩៧–១៩៨៨ ) បានសម្រេចចិត្តថា លោកមិនអាចបម្រើបេសកកម្មបានទេ ដោយសារតែស្ថានភាពហិរញ្ញវត្ថុគ្រួសាររបស់លោក ។ មានគ្រាមួយ លោកបានស្ដាប់ព្ឋអែលឌើរ មែលវិន ជេ បាឡឺដ ( ឆ្នាំ ១៨៧៣–១៩៣៩ ) និយាយ ។ ជីវប្រវត្តិកត់ចំណាំថា « [ ម៉ារ៉ុន ] ពុំបានដឹងនៅពេលនោះថា ផ្លូវជីវិតរបស់លោកហៀបនឹងផ្លាស់ប្ដូរទាំងស្រុងក្នុងពេលមួយរំពេចភ្នែកនោះទេ » ។

រឿងនោះបានបន្តថា ៖ « នោះជាលើកដំបូងដែល ម៉ារ៉ុន . . . បានយល់ទាំងស្រុងថា [ ដូចជា ] ត្រូវបានស្ថិតនៅក្រោមឥទ្ធិពលនៃការបំផុសគំនិត ។ អារម្មណ៍ចាក់ដោត និង ឆេះឆួលក្នុងចិត្តបានបំពេញក្នុងព្រលឹងរបស់លោក ។ លោក . . . ពុំដែលរំជួលដួងចិត្តយ៉ាងខ្លាំងដូចពេលនេះទេ ពេលស្ដាប់ពាក្យសម្ដីរបស់សាវកថ្មីបំផុតរូបនេះ ។ . . .

ពន្លឺនៃទឹកមុខរបស់សាវក និង ភាពស្មោះត្រង់នៃទីបន្ទាល់របស់លោក បានធ្វើឲ្យខ្លួនលោកមានចិត្តពោរពេញដោយបំណងប្រាថ្នាដ៏ខ្លាំងមួយដើម្បីចេញទៅបំពេញបេសកកម្ម ។ . . . លោកបានដឹងថា ផែនការរបស់លោកដើម្បីបន្តការសិក្សាត្រូវតែផ្អាក » ។[៤]



*យុវវ័យរបស់យើងជាច្រើនស្គាល់ **Google** ច្រើនជាងដំណឹងល្អ ទទួលយកអ៊ិនធើណែតច្រើនជាងការបំផុសគំនិត ហើយកាន់តែចូលរួមក្នុង **Facebook** ច្រើនជាងសេចក្ដីជំនឿ ។*

មិនយូរប៉ុន្មាន ម៉ារ៉ុន បានធ្វើដំណើរទៅប្រទេស អូស្ត្រាលី ជាកន្លែងដែលគាត់បានបម្រើដោយស្មោះត្រង់ ។ ក្រោយមក លោកបានក្លាយជាសាវកដ៏អស្ចារ្យម្នាក់ និងជាសមាជិកនៃគណៈប្រធានទីមួយ ។

រឿងចុងក្រោយនេះបានមកពីប្រធាន បិយដ៏ ឃេ. ផាកកឺ ( ឆ្នាំ ១៩២៤–២០១៥ ) ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អំពីឥទ្ធិពលនៃគ្រូបង្រៀនវ័យចំណាស់ទៅលើ វិល្លាម អ៊ី បារ៉េត ។ គ្រូបង្រៀន ជាអ្នកប្រែចិត្តជឿម្នាក់មកពីប្រទេសណរវ៉េ មានជំនាញភាសាអង់គ្លេសពុំសូវល្អទេ ។ តែទោះជាយ៉ាងណាក៏ដោយ មិនថាគ្រូបង្រៀនមានកម្រិតត្រឹមណានោះទេ ប្រធាន ផាកកឺ បានរំឭកថា បងប្រុស បារ៉េត បានថ្លែងទីបន្ទាល់អំពីគ្រូបង្រៀនរបស់លោកថា « យើងអាចកម្ដៅដៃរបស់យើងដោយភ្លើងនៃសេចក្ដីជំនឿរបស់គាត់បាន » ។[៥]

ក្រោយមក វិល្លាម បានក្លាយទៅជាអ្នកគ្រប់គ្រងថ្នាក់សិក្ខាសាលា ថ្នាក់វិទ្យាស្ថាន និងសាលារបស់សាសនាចក្រ ។

ចំពោះ ហ៊ីប៊ី, ម៉ារ៉ុន, និង វិល្លាម ដែលបានស្ដាប់ឮទីបន្ទាល់ដ៏បរិសុទ្ធមួយ បានក្លាយទៅជាកាតាលីករដែលផ្លាស់ប្ដូរជីវិតរបស់ពួកគេជារៀងរហូត ។ វាក៏មានពិតដូចគ្នានេះចំពោះអស់អ្នក ដែលអ្នកបង្រៀនផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែភាពពិតនៃពិភពលោកសព្វថ្ងៃនេះ ទីបន្ទាល់បរិសុទ្ធអាចនឹងមិនមានល្មមគ្រប់គ្រាន់ជានិច្ចនោះទេ ។ ហ៊ីប៊ី, ម៉ារ៉ុន, និង វិល្លាម មានភាពស្អាតស្អំ និងបរិសុទ្ធ ហើយគ្មានជាប់ជំពាក់នឹងរឿងអាសគ្រាម និង ភាពស្មោគគ្រោកនៃលោកិយនោះទេ នៅពេលពួកគេអង្គុយនៅជិតអ្នកផ្សព្វផ្សាយសាសនា គ្រូបង្រៀន និងអ្នកដឹកនាំដ៏បំផុសគំនិតនោះ ។ ព្រះវិញ្ញាណងាយនឹងចាក់ចូលទៅក្នុងដួងចិត្តដ៏ទន់ភ្លន់ និង បរិសុទ្ធរបស់ពួកគេ ។

សព្វថ្ងៃនេះរឿងនោះគឺខុសគ្នាឆ្ងាយណាស់ ។ សិស្សរបស់អ្នកមួយចំនួនអាចនឹងត្រូវរងឥទ្ធិពលដោយរូបអាសគ្រាម និងរឿងស្មោគគ្រោកខាងលោកិយរួចទៅហើយពីមុនពួកគេមកដល់ថ្នាក់រៀនរបស់អ្នក ។

គ្រាន់តែមួយជំនាន់កន្លងទៅ ដែលមនុស្សវ័យក្មេងរបស់យើងអាចចូលទៅកាន់ព័ត៌មានអំពីប្រវត្តិ គោលលទ្ធិ និងការអនុវត្តរបស់យើង ត្រូវបានកំណត់ចំពោះតែឯកសារបោះពុម្ពដោយសាសនាចក្រប៉ុណ្ណោះ ។ សិស្សមួយចំនួនតូចជួបនឹងឯកសារដែលការបកស្រាយផ្ទុយពីសាសនាចក្រ ។ ភាគច្រើន យុវវ័យរបស់យើងបានរស់នៅក្នុងជីវិតដែលត្រូវបានការពារ ។

កម្មវិធីសិក្សារបស់យើងនៅពេលនោះ ទោះជាបង្កើតឡើងក្នុងបំណងល្អក្ដី ក៏ពុំបានរៀបចំសិស្សសម្រាប់ជំនាន់បច្ចុប្បន្ននេះដែរ—នេះជាជំនាន់មួយដែលពួកគេអាចចូលទៅកាន់អ្វីៗដែលប្រកបដោយគុណធម៌អំពីសាសនាចក្រមកពីគ្រប់ស្ថានភាពបានយ៉ាងងាយ ។ សព្វថ្ងៃនេះ អ្វីដែលពួកគេមើលឃើញនៅក្នុងឧបករណ៍ចល័តរបស់ពួកគេ ទំនងជាឧបសគ្គចំពោះសេចក្ដីជំនឿច្រើនដូចជាការជំរុញឲ្យមានសេចក្ដីជំនឿផងដែរ ។ យុវវ័យរបស់យើងជាច្រើនស្គាល់ Google ច្រើនជាងដំណឹងល្អ ទទួលយកអ៊ិនធើណែតច្រើនជាងការបំផុសគំនិត ហើយកាន់តែចូលរួមក្នុង Facebook ច្រើនជាងសេចក្ដីជំនឿ ។

**ចំណេះចំណានខាងគោលលទ្ធិ**

នៅក្នុងពន្លឺនៃឧបសគ្គទាំងនេះ គណៈកម្មការអប់រំសាសនាចក្រ ថ្មីៗនេះបានអនុមតិឲ្យមានកម្មវិធីមួយនៅក្នុងថ្នាក់សិក្ខាសាលាដែលហៅថា ចំណេះចំណានខាងគោលលទ្ធិ ។ ជាការស្ថាបនានៅលើអ្វីដែលមានរួចទៅហើយនៅក្នុងចំណេះចំណានបទគម្ពីរ នោះកម្មវិធីថ្មីនេះ នឹងផ្ដោតទៅលើការស្ថាបនា និងការពង្រឹងសេចក្ដីជំនឿរបស់សិស្សយើងទៅលើព្រះយេស៊ូវគ្រីស្ទ ហើយការពារពួកគេដោយសមត្ថភាពកាន់តែខ្លាំងដើម្បីរស់នៅ និង អនុវត្តដំណឹងល្អនៅក្នុងជីវិតពួកគេ ។ ពេលប្រើបទគម្ពីរ និង ពាក្យសម្ដីរបស់ពួកព្យាការី ពួកគេនឹងរៀនអំពីរបៀប ដើម្បីធ្វើសកម្មភាព

# ស្វែងរកការរៀនសូត្រ ដោយការសិក្សា

ដោយសេចក្ដីជំនឿទៅលើព្រះគ្រីស្ទ ដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ និងការយល់ដឹងអំពីដំណឹងល្អរបស់ទ្រង់ ។ ហើយពួកគេនឹងមានឱកាសដើម្បីរៀនអំពីរបៀបអនុវត្តគោលលទ្ធិនៃព្រះគ្រីស្ទ និងគោលការណ៍ដំណឹងល្អចំពោះសំណួរ និងឧបសគ្គនានាដែលពួកគេស្ដាប់ឮ និងមើលឃើញជារៀងរាល់ថ្ងៃនៅក្នុងចំណោមមិត្តភក្ដិ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ។

កម្មវិធីនេះគឺបំផុសគំនិត និងចំពេលវេលា ។ វានឹងមានឥទ្ធិពលដ៏អស្ចារ្យលើយុវវ័យរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ ភាពជោគជ័យនៃចំណេះចំណានខាងគោលលទ្ធិ និងកម្មវិធីសិក្សា នៅក្នុងប្រព័ន្ធអប់រំផ្សេងៗទៀតរបស់សាសនាចក្រទាំងអស់ នឹងពឹងផ្អែកទាំងស្រុងទៅលើគ្រូបង្រៀនរបស់យើង ។

នៅក្នុងការប្រឈមមុខនឹងឧបសគ្គទាំងនេះ តើឱកាស និងការទទួលខុសត្រូវអ្វីខ្លះ ដែលគ្រូបង្រៀនដំណឹងល្អមានក្នុងសតវត្សរ៍ទី ២១នេះ ? ពិតប្រាកដណាស់ អ្នកទាំងអស់គ្នាដែលជាគ្រូបង្រៀន ត្រូវតែស្រឡាញ់ព្រះអម្ចាស់ ស្រឡាញ់សាសនាចក្រទ្រង់ ហើយស្រឡាញ់សិស្សរបស់អ្នក ។ អ្នកត្រូវតែថ្លែងទីបន្ទាល់បរិសុទ្ធដោយស្មោះត្រង់ និងជាញឹកញាប់ផងដែរ ។ លើសពីនោះទៀត ច្រើនជាងពេលណាៗទាំងអស់ក្នុងប្រវត្តិសាស្ត្ររបស់យើង សិស្សរបស់អ្នកត្រូវការពរជ័យដោយការរៀនមាតិកា និងបរិបទខាងគោលលទ្ធិ និងប្រវត្តិសាស្ត្រដោយការសិក្សា និងដោយសេចក្ដីជំនឿ អមជាមួយនឹងទីបន្ទាល់បរិសុទ្ធ ដើម្បីពួកគេអាចមានបទពិសោធន៍ប្រែចិត្តជឿដែលមានភាពចាស់ទុំ និងយូរអង្វែងក្នុងដំណឹងល្អ និង មានការតាំងចិត្តចំពោះព្រះយេស៊ូវគ្រីស្ទពេញមួយជីវិត ។ ការប្រែចិត្តជឿដែលមានភាពចាស់ទុំ និងយូរអង្វែង មានន័យថា ពួកគេនឹង « ស្ថិតនៅលើទូក ហើយតោងជាប់នឹងទូក » ពេញមួយជីវិត របស់ពួកគេ ។[៦]

ដើម្បីឲ្យ *អ្នក* យល់អំពីមាតិកា និងបរិបទខាងគោលលទ្ធិនៃបទគម្ពីរ និងខាងប្រវត្តិសាស្ត្រនៃប្រវត្តិរបស់យើង នោះអ្នកនឹងចាំបាច់ត្រូវសិក្សាចេញពី « សៀវភៅល្អៗ » ដូចដែលព្រះអម្ចាស់បានដឹកនាំ (គ. និង ស. ៨៨:១១៨) ។ « សៀវភៅល្អៗ » រួមមានបទគម្ពីរ ការបង្រៀនរបស់ពួកព្យាការី និង ពួកសាវកបច្ចុប្បន្ន និង ការសិក្សារបស់ពួក អិល.ឌី.អេស ល្អៗបំផុតដែលមាន ។ តាមរយៈការខិតខំដោយឧស្សាហ៍របស់អ្នក ដើម្បីរៀនដោយការសិក្សា និងដោយសេចក្ដីជំនឿ នោះអ្នកនឹងអាចជួយសិស្សរបស់អ្នករៀនជំនាញ និងអាកប្បកិរិយាដែលចាំបាច់ដើម្បីញែកដឹងរវាងព័ត៌មានដែលអាចពឹងផ្អែកបាន ដែលនឹងជួយលើកពួកគេឡើងពីព័ត៌មានដែលមានសេចក្ដីពិតពាក់កណ្ដាល និងការបកស្រាយគោលលទ្ធិ ប្រវត្តិសាស្ត្រ និង ការអនុវត្តដោយពុំត្រឹមត្រូវ ដែលនឹងនាំពួកគេឲ្យធ្លាក់ចុះ ។

សូមបង្រៀនពួកគេអំពីឧបសគ្គនានាដែលពួកគេប្រឈមមុខ នៅពេលពួកគេពឹងផ្អែកទៅលើអ៊ិនធើរណែតដើម្បីឆ្លើយនឹងសំណួរអំពីសារៈសំខាន់ដ៏អស់កល្បជានិច្ច ។ សូមរំឭកពួកគេថា យ៉ាកុបពុំបាននិយាយថា « បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ Google នោះទេ ! » ( សូមមើល យ៉ាកុប ១:៥ ) ។

មនុស្សឈ្លាសវៃពុំពឹងផ្អែកទៅលើអ៊ិនធើរណែត ដើម្បីធ្វើការវិភាគ ហើយព្យាបាលបញ្ហាសុខភាពខាងសតិអារម្មណ៍ ខាងស្មារតី និង ខាងរូបកាយនោះទេ ជាពិសេសបញ្ហាដែលគំរាមគំហែងដល់អាយុជីវិត ។ ផ្ទុយទៅវិញ ពួកគេស្វែងរកអ្នកជំនាញខាងសុខភាព ជាអ្នកទាំងឡាយដែលបានបំពាក់បំប៉ន និងទទួលបានអាជ្ញាបណ្ណដោយបានទទួលស្គាល់មកពីគណៈកម្មការវេជ្ជសាស្ត្ររដ្ឋ ។ ទោះជាយ៉ាងនោះក្ដី មនុស្សដែលប្រុងប្រយ័ត្នស្វែងរកគំនិតទីពីរ ។

ប្រសិនបើនោះជាផ្លូវត្រូវដើម្បីស្វែងរកចម្លើយចំពោះបញ្ហាសុខភាពខាងសតិអារម្មណ៍ ខាងស្មារតី និង ខាងរូបកាយ ហើយវាគួរតែបែបដូច្នោះនៅពេលជីវិតអស់កល្បជានិច្ចស្ថិតក្នុងភាពហានិភ័យ ។ នៅពេលមានអ្វីមួយដែលគំរាមគំហែងខ្លាំងដល់ជីវិតខាងវិញ្ញាណរបស់យើង ដល់ទំនាក់ទំនងក្រុមគ្រួសារដ៏មានតម្លៃបំផុតរបស់យើង និងសមាជិកភាពនៅក្នុងនគររបស់យើង នោះយើងគួរតែស្វែងរកអ្នកដឹកនាំសាសនាចក្រដែលយល់ចិត្ត និង ស្មោះត្រង់ដើម្បីជួយយើង ។ ហើយបើចាំបាច់ យើងគួរតែសុំជំនួយពីអ្នកទាំងឡាយដែលមានការបំពាក់បំប៉នវិជ្ជាជីវៈត្រឹមត្រូវ មានបទពិសោធន៍ និងមានជំនាញ ។

នេះជាអ្វីដែលខ្ញុំធ្វើ នៅពេលខ្ញុំត្រូវការចម្លើយចំពោះសំណួរផ្ទាល់ខ្លួនដែលខ្ញុំពុំអាចឆ្លើយដោយខ្លួនឯងបាន ។ ខ្ញុំស្វែងរកជំនួយមកពីបងប្អូនប្រុសក្នុងកូរ៉ុមដប់ពីរនាក់របស់ខ្ញុំ និងមកពីអ្នកទាំងឡាយដែលមានជំនាញនៅក្នុងជំនាញប្រវត្តិសាស្ត្រ និងគោលលទ្ធិសាសនាចក្រ ។

គ្រូបង្រៀនដំណឹងល្អគួរតែស្ថិតក្នុងចំណោមមនុស្សដំបូងគេ—ក្រៅពីក្រុមគ្រួសារសិស្សរបស់អ្នកផ្ទាល់ ដែលត្រូវណែនាំអំពីប្រភពសិទ្ធិអំណាចចំពោះប្រធានបទដែលមិនសូវមានគេស្គាល់ ឬចម្រូងចម្រាស ដូច្នេះសិស្សរបស់អ្នកនឹងថ្លឹងថ្លែងតាមអ្វីដែល





# ដោយសេចក្ដីជំនឿ

ពួកគេស្ដាប់ឮ ឬអាននៅពេលក្រោយទៅនឹងអ្វីដែលពួកគេត្រូវបានបង្រៀនរួចទៅហើយនោះ ។

**ការចាក់ថ្នាំបង្ការខាងវិញ្ញាណ**

យើងផ្ដល់នូវការចាក់ថ្នាំបង្ការដល់អ្នកផ្សព្វផ្សាយសាសនាដ៏មានតម្លៃរបស់យើងពីមុនបញ្ជូនពួកគេឲ្យទៅតំបន់បេសកកម្ម ដូច្នេះពួកគេនឹងត្រូវបានការពារទប់ទល់នឹងជំងឺដែលអាចធ្វើឲ្យពួកគេគ្រោះថ្នាក់ ។ ស្រដៀងគ្នានេះដែរ ពីមុនអ្នកបញ្ជូនសិស្សទៅក្នុងលោកិយ សូមចាក់ថ្នាំបង្ការពួកគេដោយការផ្ដល់នូវការបកស្រាយគោលលទ្ធិដំណឹងល្អ បទគម្ពីរ ប្រវត្តិរបស់យើង និងប្រធានបទទាំងឡាយ ដោយស្មោះត្រង់ ចេះគិតគូរ និងត្រឹមត្រូវដែលពេលខ្លះមានការភាន់ច្រឡំ ។

ដើម្បីរៀបរាប់អំពីប្រធានបទមួយចំនួនដែលពុំសូវមានគេស្គាល់ ឬចម្រូងចម្រាស់ ខ្ញុំកំពុងនិយាយអំពីពហុពន្ធភាព ត្បូងអ្នកមើលឆុត ដំណើររឿងខុសគ្នាអំពីការនិមិត្តដំបូង ដំណើរការនៃការបកប្រែព្រះគម្ពីរមរមន ឬ គម្ពីរអ័ប្រាហាំ បញ្ហារឿងភេទពូជសាសន៍ និងបព្វជិតភាព និង ព្រះមាតាសួគ៌ ។

កិច្ចខិតខំដើម្បីចាក់ថ្នាំបង្ការដល់យុវវ័យរបស់យើងជាញឹកញាប់នឹងធ្លាក់ទៅលើគ្រូបង្រៀននៃប្រព័ន្ធអប់រំសាសនាចក្រ ។ ដោយមានគំនិតនោះក្នុងចិត្ត សូមរកពេលគិតអំពីឱកាស និង ការទទួលខុស ត្រូវរបស់អ្នក ។

សព្វថ្ងៃនេះដោយបានដឹងយ៉ាងពេញលេញ អំពីការចូលទៅកាន់ព័ត៌មាន ដោយគ្មានដែនកំណត់របស់យើង នោះយើងកំពុងធ្វើការខិតខំយ៉ាងខ្លាំងបំផុត ដើម្បីផ្ដល់នូវបរិបទ និងការយល់ដឹងត្រឹមត្រូវអំពីការបង្រៀនអំពីការស្ដារឡើងវិញ ។ ឧទាហរណ៍ដ៏សំខាន់មួយអំពីកិច្ចខិតខំនេះគឺ សំណេរប្រធានបទដំណឹងល្អចំនួន ១១ នៅលើគេហទំព័រ LDS.org[៧] ដែលផ្ដល់នូវការបកស្រាយដែលមានតុល្យភាព និងដែលអាចពឹងផ្អែកបានអំពីភាពពិតចំពោះប្រធានបទដែលទាក់ទងនឹងភាពចម្រូងចម្រាស់ និងការមិនស្គាល់សាសនាចក្រ ។

វាសំខាន់ដែលអ្នកត្រូវស្គាល់មាតិកានៅក្នុងសំណេរទាំងនេះ ។ ប្រសិនបើអ្នកមានសំណួរអំពីវា ចូរសួរដល់នរណាម្នាក់ដែលបានសិក្សាវា ហើយយល់អំពីវា ។ម៉្យាងទៀត « ចូរស្វែងរកការរៀនសូត្រ ដោយសារការសិក្សា និង ដោយសារសេចក្ដីជំនឿផង » ( គ. និង ស. ៨៨:១១៨ ) នៅពេលអ្នកចេះស្ទាត់អំពីមាតិកានៃសំណេរទាំងនេះ ។

អ្នកគួរតែស្គាល់គេហទំព័រអំពីឯកសាររបស់យ៉ូសែប ស៊្មីធ[៨] ផ្នែកប្រវត្តិសាសនាចក្រនៅលើ LDS.org និង ធនធានដទៃទៀតដោយអ្នកប្រាជ្ញ អិល.ឌី.អេស ស្មោះត្រង់ផងដែរ ។

កិច្ចខិតខំដើម្បីធ្វើឲ្យមានតម្លាភាពលើដំណឹងល្អ និងការចាក់ថ្នាំបង្ការខាងវិញ្ញាណ តាមរយៈការសិក្សាដោយគិតគូរអំពីគោលលទ្ធិ និងប្រវត្តិសាស្ត្រ គួបផ្សំនឹងទីបន្ទាល់ដែលឆេះសន្ធោរសន្ធៅ នោះគឺជាថ្នាំបន្សាបដ៏ល្អបំផុតដែលយើងមានដើម្បីជួយដល់សិស្សឲ្យចៀសវាង និង ដោះស្រាយសំណួរ ការសង្ស័យ ឬ វិបត្តិនៃសេចក្ដីជំនឿ ដែលពួកគេអាចប្រឈមមុខនៅក្នុងជំនាន់ដែលពោរពេញដោយព័ត៌មាននេះ ។

នៅពេលអ្នកជាគ្រូបង្រៀនបានលះបង់ដើម្បីទទួលបានការយល់ដឹងកាន់តែល្អប្រសើរ អំពីប្រវត្តិ គោលលទ្ធិ និងការអនុវត្តរបស់យើង—ច្រើនជាងដែលអ្នកដឹងនាពេលនេះ—នោះអ្នកនឹងត្រៀមខ្លួន ដើម្បីផ្ដល់នូវចម្លើយចំពោះសំណួររបស់សិស្សអ្នកដោយចេះគិតគូរ ប្រុងប្រយ័ត្ន និងដ៏បំផុសគំនិត ។

របៀបមួយដើម្បីដឹងថាសិស្សរបស់អ្នកមានសំណួរអ្វីខ្លះនោះគឺត្រូវស្ដាប់ពួកគេដោយយកចិត្តទុកដាក់ ។ គ្រប់គ្រូបង្រៀនល្អត្រូវធ្វើជាអ្នកពូកែស្ដាប់ ។ បន្ថែមពីលើការស្ដាប់សិស្សរបស់អ្នក សូមលើកទឹកចិត្តពួកគេម្នាក់ៗនៅក្នុងថ្នាក់ ឬ អញ្ជើញដោយផ្ទាល់ខ្លួនឲ្យសួរសំណួរអ្នកអំពីប្រធានបទ អ្វីក៏បាន ។ សំណួរសំខាន់បំផុតមួយដែលសិស្សរបស់អ្នកអាចសួរគឺ « ហេតុអ្វី ? » នៅពេលសួរដោយបំណងស្មោះដើម្បីយល់ពី « ហេតុអ្វី ? » គឺជាសំណួរដ៏អស្ចារ្យមួយ ។ វាគឺជាសំណួរដែលអ្នកផ្សព្វផ្សាយសាសនាចង់ឲ្យអ្នករៀនរបស់ពួកគេសួរ ។ ហេតុអ្វីយើងនៅទីនេះ ? ហេតុអ្វីក៏មានរឿងអាក្រក់កើតឡើងចំពោះមនុស្សល្អ ? ហេតុអ្វីយើងគួរតែអធិស្ឋាន ? ហេតុអ្វីយើងគួរតែធ្វើតាមព្រះគ្រីស្ទ ? ជាញឹកញាប់សំណួរ « ហេតុអ្វី » នាំទៅរកការបំផុសគំនិត និង វិវរណៈ ។ ការស្គាល់ផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌យើង នឹងជួយឆ្លើយសំណួរ « ហេតុអ្វី » បានច្រើនបំផុត ។

នេះគឺជាកំណត់ចំណាំចុងក្រោយមួយអំពីការឆ្លើយសំណួរ ។ វាសំខាន់ដើម្បីបង្រៀនសិស្សរបស់អ្នកថា ទោះបីជាដំណឹងល្អផ្ដល់ចម្លើយជាច្រើន ចំពោះសំណួរសំខាន់បំផុតនៃជីវិត ទោះជាមិនទាំងអស់ក្ដី ក៏សំណួរខ្លះមិនអាចត្រូវបានឆ្លើយនៅក្នុងជីវិតរមែងស្លាប់នេះដែរ ដោយសារយើងខ្វះព័ត៌មានដែលចាំបាច់ដើម្បីឆ្លើយឲ្យត្រឹមត្រូវ ។ ហើយយើងរៀននៅក្នុងគម្ពីរយ៉ាកុបដូចនេះ ៖ « មើលចុះ កិច្ចការទាំងឡាយនៃព្រះអម្ចាស់សុទ្ធតែធំ ហើយ

អស្ចារ្យមែន ។ ឯជម្រៅនៃសេចក្ដីអាថ៌កំបាំងទាំងឡាយរបស់ទ្រង់ ក៏ពុំអាចរកឃើញដែរ ហើយមនុស្សគ្មានលទ្ធភាពនឹងរកឃើញផ្លូវរបស់ទ្រង់បានអស់ឡើយ ។ ហើយគ្មានអ្នកណាម្នាក់ស្គាល់ផ្លូវទាំងឡាយរបស់ទ្រង់ទេ លើកលែងតែបានសម្ដែងដល់អ្នកនោះប៉ុណ្ណោះ » ( យ៉ាកុប ៤:៨ សូមមើលផងដែរ គ. និង ស. ១០១:៣២–៣៤ ) ។

**ពាក្យដាស់តឿន ៖**

ឥឡូវនេះខ្ញុំសូមផ្ដល់ការដាស់តឿនមួយ ៖ សូមទទួលស្គាល់ថា អ្នកអាចនឹងជឿ ដូចជាសិស្សជាច្រើនរបស់អ្នកដែរថា អ្នកគឺជាអ្នកជំនាញខាងបទគម្ពីរ ខាងគោលលទ្ធិ និងខាងប្រវត្តិសាស្ត្រ ។ ការសិក្សាថ្មីៗមួយបានបង្ហាញថា « កាលណាមនុស្សកាន់តែគិតថាគេស្គាល់ប្រធានបទមួយ នោះគេទំនងជាអះអាងថាគេយល់




*សំណេរប្រធានបទដំណឹងល្អចំនួន ១១ នៅលើគេហទំព័រ* ***LDS.org*** *ដែលផ្ដល់ការបកស្រាយមានគុណភាព និងដែលអាចពឹងផ្អែកបានអំពីភាពពិតចំពោះប្រធានបទដែលទាក់ទងនឹងភាពចម្រូងចម្រាស់ និងការមិនស្គាល់សាសនាចក្រ ។*

ច្រើនជាងអ្វីដែលគេចេះ ទាំងអះអាងថាមានចំណេះដឹង . . . និង ព័ត៌មានបំភ្លើសផង » ។[៩]

គ្រូបង្រៀនដំណឹងល្អរបស់យើង ត្រូវតែចៀសវាងពីការល្បួងនេះ ដែលត្រូវបានហៅថា *ការអះអាងហួសហេតុ* នោះ ។ វានឹងមិនអីទេដើម្បីនិយាយថា « ខ្ញុំមិនដឹងទេ » ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលនិយាយដូច្នោះ អ្នកមានការទទួលខុសត្រូវមួយដើម្បីស្វែងរកចម្លើយល្អបំផុតចំពោះសំណួរដែលសិស្សរបស់អ្នកសួរនោះ ( សូមមើល គ. និង ស. ១០១:៣២–៣៤ ) ។

នៅពេលអ្នកបង្រៀនសិស្សរបស់អ្នក ហើយឆ្លើយសំណួររបស់ពួកគេ ខ្ញុំសូមព្រមានថា អ្នកមិនត្រូវចែកចាយរឿង ឬ កត្តាដែលចង់បង្កើនសេចក្ដីជំនឿ ប៉ុន្តែមិនបញ្ជាក់អំពីសេចក្ដីពិត ឬការយល់ដឹង និង ការពន្យល់ដែលមិនត្រូវអំពីគោលលទ្ធិ និង ការអនុវត្តមកពីអតីតកាលរបស់យើងឡើយ ។ វាតែងតែឈ្លាសវៃជានិច្ចដើម្បីធ្វើឲ្យការសិក្សាពាក្យសម្ដីរបស់ពួកព្យាការី និង ពួកសាវក នៅរស់ក្លាយជាការអនុវត្តមួយ បន្តមានបច្ចុប្បន្នភាពចំពោះបញ្ហានានា គោលនយោបាយ និងសេចក្ដីថ្លែងរបស់សាសនាចក្រថ្មីៗតាមរយៈគេហទំព័រ mormonnewsroom.org និង LDS.org ហើយពិគ្រោះអំពីកិច្ចការរបស់ពួកអ្នកប្រាជ្ញ អិល.ឌី.អេស ដែលបានទទួលស្គាល់ គិតគូរ និង ស្មោះត្រង់ ដើម្បីប្រាកដថាអ្នកមិនបង្រៀនអ្វីដែលមិនពិត ហួសសម័យ ឬចម្លែក និង ខុសពីធម្មតា ។

អ្នកនិពន្ធអំពីការសិក្សាទៅលើការអះអាងហួសហេតុបានកត់ចំណាំថា « ទំនោរមួយដើម្បីអះអាងហួសហេតុ ជាពិសេសអ្នកដែលគិតថាខ្លួនជាអ្នកជំនាញ . . . អាចនឹងបំបាក់ទឹកចិត្តដល់បុគ្គលនោះពីការអប់រំខ្លួនគេនៅក្នុងផ្នែកជាក់លាក់ទាំងឡាយដែលពួកគេគិតថាខ្លួនគេចេះដឹងនោះ » ។[១០]

បន្ថែមពីលើការធ្វើជាអ្នករៀនពេញមួយជីវិត នោះអ្នកត្រូវតែធ្វើនូវរឿងទាំងនោះក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នកផងដែរ ដែលអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងខ្លួនអ្នក ។ រឿងដូច្នោះរួមមាន ការអធិស្ឋានប្រចាំថ្ងៃដោយស្មោះត្រង់ ការតមអាហារដោយស្មោះត្រង់ ការសិក្សា និង ការពិចារណាបទគម្ពីរ និងពាក្យសម្ដីរបស់ពួកព្យាការីនៅរស់ជាទៀងទាត់ ការធ្វើឲ្យថ្ងៃឈប់សម្រាកជាទីរីករាយចិត្ត ការទទួលទានសាក្រាម៉ង់ដោយរាបសា និងការចងចាំព្រះអង្គសង្គ្រោះជានិច្ច ការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ឲ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ហើយទីបញ្ចប់ ការឈោងទៅជួយដល់អ្នកខ្វះខាត អ្នកក្រីក្រ និង ឯកោ—ទាំងអ្នកដែលជិតស្និត និងនៅទូទាំងពិភពលោក ។

ដើម្បីបំពេញនូវឱកាស និង ការទទួលខុសត្រូវរបស់អ្នកដោយត្រឹមត្រូវ អ្នកត្រូវតែអនុវត្តនូវអ្វីដែលអ្នកផ្សាយ !

ចូរក្លាហានក្នុងការស្វែងរកការប្រឹក្សា និងការកែតម្រូវមកពីអ្នកទាំងឡាយដែលអ្នកទុកចិត្ត—ជាស្វាមី ឬ ភរិយា ជាអ្នកដឹកនាំបព្វជិតភាព ឬ អ្នកគ្រប់គ្រង ។ ចូរសួរពួកគេថាអ្នកអាចកែលម្អនៅត្រង់ចំណុចណាក្នុងភាពជាសិស្សផ្ទាល់ខ្លួនរបស់អ្នក ។ ចូរចៀសវាងពីអ្វីៗដែលបណ្ដេញព្រះវិញ្ញាណចេញ ។

បន្ថែមពីលើនោះ ខ្ញុំសូមផ្ដល់យោបល់ឲ្យអ្នកសម្អាតខ្លួនឯងម្ដងម្កាល ហើយរំឭកនីហ្វៃទី ២ ២៦:២៩–៣២, អាលម៉ា ៥:១៤–៣០ និង គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:៣៣–៤៦។ ការធ្វើបែបនោះនឹងជួយអ្នកឲ្យស្គាល់ប្រភេទនៃការល្បួង ដែលយើងទាំងអស់គ្នាអាចនឹងជួប ។ ប្រសិនបើមានអ្វីមួយចាំបាច់ត្រូវផ្លាស់ប្ដូរនៅក្នុងជីវិតអ្នក សូមដោះស្រាយដើម្បីជួសជុលវា ។

ចៀសវាងពីការល្បួងឲ្យឆ្ងល់អំពីអារម្មណ៍របស់អ្នករួមការងារអ្នក ។ ផ្ទុយទៅវិញ ចូរមើលឲ្យជ្រៅទៅក្នុងដួងចិត្តរបស់អ្នកផ្ទាល់ ហើយស្រាវជ្រាវរកបំណងប្រាថ្នា និង អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នក ។ មានតែពេលនោះហើយ ដែលព្រះអង្គសង្គ្រោះអាចផ្លាស់ប្ដូរដួងចិត្តអ្នក ហើយសម្រួលបំណងប្រាថ្នា និងអារម្មណ៍របស់អ្នកទៅនឹងព្រះទ័យរបស់ទ្រង់ ។

ជំនាន់កំពុងពេញវ័យ ចាំបាច់ត្រូវដឹង យល់ ឱបក្រសោបយក និងចូលរួមនៅក្នុងផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះ ។ ការយល់អំពីផែនការនឹងផ្ដល់ដល់ពួកគេនូវ

យោបល់ដ៏ទេវភាពមួយ ដែលបង្ហាញពីខ្លួនគេក្នុងនាមជាបុត្រា និង បុត្រីរបស់ព្រះ ដែលផ្ដល់ដល់ពួកគេនូវកែវភ្នែក ដើម្បីយល់ដឹងស្ទើរតែគ្រប់គោលលទ្ធិ ការអនុវត្ត និង គោលនយោបាយរបស់សាសនាចក្រ ។

ក្នុងនាមជាគ្រូបង្រៀនដំណឹងល្អសព្វថ្ងៃនេះ អ្នកចាំបាច់ត្រូវទទួលយកឱកាស និង ការទទួលខុសត្រូវ ដើម្បីបង្រៀនយុវវ័យសតវត្សរ៍ទី ២១ នេះនូវគោលការណ៍ត្រឹមត្រូវអំពីអាពាហ៍ពិពាហ៍ ដែលអនុមតិដោយព្រះ និង តួនាទីនៃគ្រួសារនៅក្នុងផែនការនៃសេចក្ដីសង្គ្រោះ ។[១១]

## គោលលទ្ធិនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច

គោលលទ្ធិនៃអាពាហ៍ពិពាហ៍អស់កល្បជានិច្ច និងគ្រួសារ គឺជាផ្នែកដ៏សំខាន់មួយក្នុងផែនការនៃសុភមង្គលរបស់ព្រះ ។ វារួមមានក្រុមគ្រួសារដែលបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធផ្ទាល់ខ្លួនរបស់យើង ជាចំណែកនៃគ្រួសារដ៏អស់កល្បជានិច្ចរបស់ព្រះវរបិតាសួគ៌ នៅក្នុងនគរសេឡេស្ទាល ។ ដោយសារគោលលទ្ធិនេះទាក់ទងដោយផ្ទាល់ទៅនឹងគ្រួសារ និងកូនចៅវិញ្ញាណរបស់ទ្រង់ នោះយើងត្រូវបានបង្រៀននៅក្នុងលោកុប្បត្តិថា « ក៏បង្កើតគេឡើងជាប្រុសជាស្រី » ហើយថាទ្រង់បានបញ្ជាឲ្យលោកឪពុកអ័ដាម និងអ្នកម្ដាយអេវ៉ាឲ្យ « បង្កើតកូនឲ្យចម្រើនជាច្រើនឡើង » ( សូមមើល លោកុប្បត្តិ ១:២៧–២៨ ) ។



*ចូរក្លាហានក្នុងការស្វែងរកការប្រឹក្សា និងការកែតម្រូវមកពីអ្នកទាំងឡាយដែលអ្នកទុកចិត្ត—ជាស្វាមី ឬ ភរិយា ជាអ្នកដឹកនាំបព្វជិតភាព ឬ អ្នកគ្រប់គ្រង ។ ចូរសួរពួកគេថាអ្នកអាចកែលម្អនៅត្រង់ចំណុចណាក្នុងភាពជាសិស្សផ្ទាល់ខ្លួនរបស់អ្នក ។*

ដូចបាននិយាយថា ផែនការនៃសុភមង្គលចាប់ផ្ដើម ហើយបញ្ចប់ជាមួយនឹងគ្រួសារ ។ ប្រាកដណាស់ គ្រួសារបានចាប់ផ្ដើមនៅក្នុងពិភពមុនជីវិតនេះ ដែលយើងបានរស់នៅក្នុងនាមជាសមាជិកនៃគ្រួសាររបស់ព្រះមាតាបិតាសួគ៌របស់យើង ។ ហើយនៅចុងបញ្ចប់ ការតាំងចិត្ត និង ទំនាក់ទំនងក្ដីស្រឡាញ់ជាគ្រួសារនឹងមិនគ្រាន់តែបន្តមានប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងចម្រើនឡើងនៅក្នុងដំណើរការនៃការបង្កើតកូនចៅផងដែរ ( សូមមើល គ. និង ស. ១៣១:១–៤, ១៣២:១៩ ) ។

ធាតុសំខាន់ដែលភ្ជាប់វាទាំងអស់ជាមួយគ្នា—ទៅនឹងផែនការរបស់ព្រះ និងជោគវាសនាដ៏អស់កល្បជានិច្ចរបស់យើង គឺវាអាស្រ័យ និងស្ថិតនៅលើ—ព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ ។ ពលិកម្មដ៏ធួនរបស់ទ្រង់ធ្វើឲ្យអ្វីៗគ្រប់យ៉ាងអាចកើតឡើងបាន ដោយគ្មានកំណត់រួមមានទាំងសេចក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ និងអាពាហ៍ពិពាហ៍ និង គ្រួសារអស់កល្បជានិច្ច ។

ព្រះអម្ចាស់បង្រៀនយើងថា គ្មានមនុស្សនៅលីវណាម្នាក់ អាចទទួលបាននូវអ្វីៗទាំងអស់ ដែលព្រះវរបិតាសួគ៌របស់យើងប្រទានដល់កូនចៅរបស់ទ្រង់ឡើយ មិនថាសេចក្ដីសុចរិតរបស់គាត់មានកម្រិតយ៉ាងណាទេ ។ បុគ្គលនៅលីវបំពេញតម្រូវការបានតែពាក់កណ្ដាលប៉ុណ្ណោះ ពុំអាចរស់នៅក្នុងកម្រិតដ៏ខ្ពស់បំផុតនៃនគរសេឡេស្ទាលឡើយ ( សូមមើល កូរិនថូសទី ១ ១១:១១, គ. និង ស. ១៣១:១–៤ ) ។

សិស្សរបស់អ្នកចាំបាច់ត្រូវយល់ថា គោលបំណងនៃជីវិតរមែងស្លាប់គឺដើម្បីប្រែក្លាយកាន់តែដូចជាព្រះ តាមរយៈការទទួលរូបកាយសាច់ឈាម ការអនុវត្តសិទ្ធិជ្រើសរើស និងការបំពេញតួនាទីដែលពីមុនគឺជារបស់ផងព្រះបិតាមាតាសួគ៌តែប៉ុណ្ណោះ—គឺតួនាទីជាស្វាមី ភរិយា និង ជាឪពុកម្ដាយ ។

ព្យាការីបានអះអាងថា អស់អ្នកទាំងឡាយណាដែលសក្ដិសម ហើយដែលពឹងផ្អែកទៅលើព្រះយេស៊ូវគ្រីស្ទ តែពុំអាចផ្សារភ្ជាប់នឹងដៃគូ ឬមានកូនចៅនៅក្នុងជីវិតនេះអាចនឹង មានឱកាសទាំងនោះនៅក្នុងជីវិតនាបរលោនាយ ។

សូមបង្រៀនយុវវ័យថា នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ គឺស្វាគមន៍ដល់មនុស្សទាំងអស់ មកថ្វាយបង្គំ បម្រើ និង រីកចម្រើនជាមួយគ្នាក្នុងនាមជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អ ។ សូមរំឭកពួកគេអំពីអ្វីដែលលីហៃបានបង្រៀន—ថាគោលបំណង និង សេចក្ដីសង្ឃឹមរបស់ព្រះ សម្រាប់កូនចៅទាំងអស់របស់ទ្រង់អាចត្រូវបានសង្ខេបដូចនេះថា ៖ « លោកអ័ដាមបានធ្លាក់ខ្លួន ដើម្បីឲ្យមានមនុស្សលោក ហើយមានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្ដីអំណរ » ( នីហ្វៃទី ២ ២:២៥ ) ។

ព្រះវរបិតាសួគ៌មានព្រះទ័យឲ្យយើងទទួលយកនិយមន័យនៃអាពាហ៍ពិពាហ៍របស់ទ្រង់ ហើយគោរពតាមបទបញ្ញត្តិទីមួយរបស់ទ្រង់ឲ្យ « បង្កើតកូនជាច្រើនឡើង ហើយមានពាសពេញ » ( លោកុប្បត្តិ ១:២៨ )—មិនគ្រាន់តែដើម្បីបំពេញតាមផែនការរបស់ទ្រង់ទេ ប៉ុន្តែក៏ដើម្បីរកអំណរដែលផែនការទ្រង់បានរៀបចំឡើងដើម្បីប្រទានឲ្យបុត្រា និង បុត្រីរបស់ទ្រង់ផងដែរ ។

ក្នុងនាមជាគ្រូបង្រៀនរបស់សាសនាចក្រ សូមជួយដល់យុវវ័យរបស់យើងឲ្យមានការយល់ដឹងច្បាស់លាស់អំពីផែនការនៃសុភមង្គលរបស់ព្រះថាពិតជាមានអំណរកើតមានដល់កូនចៅរបស់ទ្រង់ ។ សូមជួយពួកគេដឹងរឿងនេះ ឱបក្រសោបយកវាចូលរួមនឹងវា ហើយការពារវា ។ បទពិសោធន៍រយៈពេល ៤0 ឆ្នាំរបស់ខ្ញុំ ក្នុងនាមជាអ្នកដឹកនាំ ដែលមានសិទ្ធិអំណាចទូទៅខ្ញុំបារម្ភថា សមាជិកសាសនាចក្ររបស់យើងទាំងក្មេង ទាំងចាស់ដ៏ច្រើន ពុំយល់អំពីផែនការសម្រាប់ជោគវាសនាដ៏អស់កល្ប និងដ៏ទេវភាពរបស់ពួកគេឡើយ ។

ដូច្នេះគ្រូបង្រៀនរបស់ខ្ញុំអើយ យើងគួរតែស្វែងរក ហើយរីករាយនឹងឱកាសទាំងនេះ ដើម្បីពន្យល់អំពីខាងគោលលទ្ធិ និងខាងវិញ្ញាណថា ហេតុអ្វីយើងជឿថាចំណេះដឹងអំពីផែនការសុភមង្គលដ៏អស្ចារ្យរបស់ព្រះ នឹងឆ្លើយចំពោះសំណួរ

# ទីបន្ទាល់បរិសុទ្ធ

## មានអំណាចផ្លាស់ប្ដូរជីវិត



« ហេតុអ្វី » ភាគច្រើនដែលយើងត្រូវបានគេសួរ ។ ការបង្ហាញពីជំនឿរបស់យើងទៅលើជីវិតមុនជីវិតនេះ ដែលយើងបានរស់នៅជាកូនចៅវិញ្ញាណរបស់ព្រះវរបិតាសួគ៌ និង ព្រះមាតាសួគ៌ អនុញ្ញាតឲ្យយើងពន្យល់ថាហេតុអ្វីផែនដីនេះត្រូវបានបង្កើតឡើង ។ គោលបំណងសំខាន់មួយនៃជីវិតរមែងស្លាប់ គឺថាយើងអាចចម្លងបទពិសោធន៍គ្រួសារនោះមកខ្លួនយើង ក្នុងគ្រានេះក្នុងនាមជាឪពុកម្ដាយ ជាជាងក្នុងនាមជាកូន ។ សូមរក្សាទុកនូវការយល់ដឹងគ្រឹះរបស់អ្នកអំពីគោលលទ្ធិ និងគោលបំណងនៃផែនការរបស់ព្រះវរបិតាសួគ៌របស់យើងដើម្បីសុភមង្គលដ៏អស់កល្បជានិច្ចរបស់យើង ។ ហើយបន្តបង្រៀនអំពីវា ។

### សេចក្ដីបញ្ចប់

ដូច្នោះដើម្បីបញ្ចប់ និង សង្ខេបចំណុចទាំងឡាយដែលខ្ញុំបានចែកចាយជាមួយនឹងអ្នកគឺ ៖

- បង្រៀនសិស្សឲ្យដាក់បញ្ចូលការរៀនសូត្រដោយការសិក្សា និងសេចក្ដីជំនឿជាមួយនឹងទីបន្ទាល់បរិសុទ្ធ ។
- សូមបង្រៀនសិស្សឲ្យបន្តជិះនៅលើទូក ហើយតោងឲ្យជាប់ !
- បង្រៀនសិស្សឲ្យគ្រប់គ្រងលើឧបករណ៍ចល័តរបស់ពួកគេ ហើយផ្ដោតទៅលើទំនាក់ទំនងព្រះវិញ្ញាណបរិសុទ្ធឲ្យច្រើនជាងអ៊ិនធើណិត ។
- ចាក់ថ្នាំបង្ការដល់សិស្សជាមួយនឹងសេចក្ដីពិតនៃផែនការនៃសេចក្ដីសង្គ្រោះដែលរកបាននៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។
- សូមចងចាំថា « ហេតុអ្វី ? » អាចជាសំណួរដ៏អស្ចារ្យមួយ ដែលដឹកនាំទៅរកការយល់ដឹងអំពីដំណឹងល្អ ។
- រៀនឲ្យចេះស្ទាត់អំពីមាតិកានៃសំណេរប្រធានបទដំណឹងល្អ ។
- ចូរកុំអះអាងហួសហេតុ ហើយកុំខ្លាចនឹងនិយាយថា « ខ្ញុំមិនដឹង » ។
- ចូរធ្វើជាអ្នករៀនសូត្រពេញមួយជីវិត ។
- ស្វែងរកការប្រឹក្សា និងការកែលម្អមកពីអ្នកទាំងឡាយដែលអ្នកទុកចិត្ត ។
- ពិចារណាធ្វើការសម្ភាសខ្លួនឯងម្ដងម្កាលដើម្បីពិនិត្យមើលការរៀបចំខ្លួនខាងវិញ្ញាណ ភាពឧស្សាហ៍ព្យាយាម និងប្រសិទ្ធភាពរបស់អ្នក ។
- បង្រៀនថា ផែនការនៃសុភមង្គលចាប់ផ្ដើម ហើយបញ្ចប់ជាមួយនឹងគ្រួសារ ។ ចាំទុកក្នុងចិត្តអំពីផែនការនៃសេចក្ដីសង្គ្រោះគ្រប់ពេល ។
- បង្រៀនថា អាពាហ៍ពិពាហ៍ និងគ្រួសារនាំមកនូវអំណរដ៏យូរអង្វែង ។

សូមចងចាំ ការដាក់បញ្ចូលការរៀនសូត្រដោយការសិក្សា ដោយសេចក្ដីជំនឿ និង ដោយទីបន្ទាល់បរិសុទ្ធ នាំមកនូវការប្រែចិត្តជឿពិត និង យូរអង្វែង ។ លើសពីនោះទៀត សេចក្ដីជំនឿរឹងមាំទៅលើដង្វាយធួននៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺសំខាន់ចំពោះកម្លាំងខាងវិញ្ញាណ និង ការរីកចម្រើនរបស់យើង ។

សូមឲ្យអ្នកមានអំណរ និងភាពសុខសាន្តដែលកើតមានមកពីការដឹងថា តាមរយៈការបង្រៀនរបស់អ្នក នោះអ្នកបានជះឥទ្ធិពលដល់ជីវិតរបស់បុគ្គលម្នាក់ ហើយបានជួយលើកស្ទួយដល់កូនម្នាក់ៗរបស់ព្រះវរបិតាសួគ៌ នៅលើដំណើររបស់ពួកគេត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់វិញ ។ ■

កំណត់ចំណាំ


១. ការប្រជុំបំពាក់បំប៉នពួកអ្នកមានសិទ្ធិអំណាចទូទៅ ទីក្រុង សលត៍ លេក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩២ ។
២. ហារ៉ូល ប៊ី លី នៅក្នុង Clyde J. Williams *The Teachings of Harold B. Lee* ( ឆ្នាំ ១៩៩៦ ) ទំព័រ ៣៣១ ។
៣. សូមមើល Edward W. Tullidge *The Women of Mormondom* ( ឆ្នាំ ១៨៧៧ ) ទំព័រ ៤១១–១៤ ។
៤. សូមមើល F. Burton Howard *Marion G. Romney: His Life and Faith* ( ឆ្នាំ ១៩៨៨ ) ទំព័រ ៦២–៦៤ ។
៥. ប៊ិយដ៍ ឃេ ផាកកឺ « A Tribute to the Rank and File of the Church » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨០ ទំព័រ ៦២ ។
៦. សូមមើល អិម រ័សុល បាឡឺដ « Stay in the Boat and Hold On ! » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ៨៩–៩២ ។
៧. សូមមើលគេហទំព័រ lds.org/topics/essays ។
៨. សូមមើល josephsmithpapers.org ។
៩. Brent W. Webb « Quest for Perfection and Eternal Life » ( Brigham Young University annual university conference faculty session ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ ) ទំព័រ ១០ speeches.byu.edu សូមមើលផងដែរ Stav Atir, Emily Rosenzweig និង David Dunning « When Knowledge Knows No Bounds: Self-Perceived Expertise Predicts Claims of Impossible Knowledge » *Psychological Science* ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ១២៩៥–១៣០៣ ។
១០. នៅក្នុង Brent W. Webb « Quest for Perfection and Eternal Life » ទំព័រ ១០ ។
១១. សូមមើល « The Family: A Proclamation to the World » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ។

# ភៀសខ្លួនស្វែងរក សេចក្ដីជំនឿ និង សេរីភាព

ដោយ អ៊ីវ៉ា វ៉ៃលបើរហ្គើរ

បងប្អូនបង្កើតរបស់ខ្ញុំ និង រូបខ្ញុំបានធំឡើង ដោយឮរឿងនានាស្ដីអំពី របៀបដែលឪពុកម្ដាយរបស់យើងបានបូជា ដើម្បីរស់នៅតាមដំណឹងល្អ ហើយយើងមានពរដោយសារការខិតខំរបស់ពួកគាត់ ។ ខ្ញុំបានបង្កើនស្មារតីនៃការមានអំណរគុណកាន់តែច្រើនឡើង សម្រាប់អ្វីៗទាំងអស់ដែលពួកគាត់ និង ពួកបរិសុទ្ធថ្ងៃចុងក្រោយជនជាតិឆេកដទៃទៀតបានធ្វើ ប្រយោជន៍ឲ្យពូជពង្សរបស់ពួកគេ អាចទទួលបាននូវពរជ័យនៃដំណឹងល្អ ។

ម្ដាយរបស់ខ្ញុំបានកើតនៅក្នុងទីក្រុងប៉ូប្រាដនៃអតីតប្រទេសឆេកូស្លូវ៉ាគី ( ឥឡូវនេះជាប្រទេសស្លូវ៉ាគី ) ។ ឪពុករបស់គាត់បានបម្រើនៅក្នុងកងទ័ពឆេក អំឡុងសង្គ្រាមលោកលើកទី II ហើយគ្រួសាររបស់គាត់គឺជាគ្រួសារមួយ បានភៀសខ្លួនទៅក្នុងទីព្រៃនៅជិតខាងនោះ ដើម្បីមានសុវត្ថិភាពពីការកាន់កាប់របស់ពួកអាល្លឺម៉ង់ ។ អស់រយៈពេលប្រាំថ្ងៃ ជីដូនជីតារបស់ខ្ញុំត្រូវបានដាក់ប្រជ្រៀតគ្នានៅក្នុងភ្នួយ ជាមួយម្ដាយរបស់ខ្ញុំ និង បងស្រីរបស់គាត់ ដែលម្ដាយខ្ញុំមានអាយុមួយឆ្នាំ និង បងស្រីគាត់មានអាយុប្រាំឆ្នាំ ដោយបរិភោគស្កររាងបួនជ្រុងដែលជាចំណែករៀងៗខ្លួន ។

យាយតារបស់ខ្ញុំមិនមែនជាសមាជិកសាសនាចក្រឡើយកាលគ្រានោះ ហើយពួកគាត់ក៏មិនអធិស្ឋានញឹកញាប់ដែរ ។ ប៉ុន្តែ អំឡុងពេលដ៏លំបាកលំបិននោះ ចិត្តរបស់ពួកគាត់បានប្រែជាទន់ភ្លន់ ។ ជីដូនរបស់ខ្ញុំបានសរសេរនៅក្នុងសៀវភៅទិនានុប្បវត្តិរបស់គាត់ថា « នាយប់នេះខ្ញុំមានអារម្មណ៍ចង់លុតជង្គង់ចុះឲ្យយូរ ដើម្បីសុំជំនួយមកពីនរណាម្នាក់ ដែលមានសិទ្ធិអំណាចខ្លាំងជាងខ្ញុំ ។ ដូច្នោះខ្ញុំបានទៅក្នុងព្រៃ លុតជង្គង់ចុះ ហើយអធិស្ឋានដោយមានដួងចិត្តសង្រេង និងវិញ្ញាណទន់ទាប ។ ខ្ញុំបានទូលអង្វរសូមជំនួយ » ។

ការអធិស្ឋានរបស់គាត់បានទទួលចម្លើយ ។ គ្រួសារមួយចំនួននៅក្នុងព្រៃត្រូវបានគេសម្លាប់ពេលគេបានរកឃើញ ប៉ុន្តែយាយតារបស់ខ្ញុំ និង កូនស្រីពីរនាក់របស់ពួកគាត់ត្រូវបានការពារដោយអព្ភូតហេតុ ។ តាមរយៈបទពិសោធន៍ដ៏លំបាកនេះ ព្រះអម្ចាស់បានបណ្ដុះគ្រាប់ពូជនៃសេចក្ដីជំនឿ និង ការទុកចិត្តលើដួងចិត្តរបស់ជីដូនជីតារបស់ខ្ញុំ ។

*នៅពេលពួកគាត់ស្វែងរកសេរីភាពសាសនា នោះឪពុកម្ដាយរបស់ខ្ញុំមានពរ ដោយសារសេចក្ដីសប្បុរស និង ការទទួលយករបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយជុំវិញខ្លួនពួកគាត់ ដែលពួកគាត់ចេញពីប្រទេសឆេកូស្លូវ៉ាគីទៅប្រទេសកាណាដា ។*

## សេចក្ដីជំនឿ និង ការបៀតបៀន

បន្ទាប់ពីសង្គ្រាមលោកលើកទី II បានបញ្ចប់ពីរបីឆ្នាំក្រោយមក យាយតារបស់ខ្ញុំ បានបន្តរស់នៅក្នុងប្រទេស ឆេកូស្លូវ៉ាគី កាលអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងពីរនាក់បានគោះទ្វារផ្ទះរបស់ពួកគាត់ ។ បន្ទាប់ពីបានចូលរួមក្នុងសាខាតូចមួយ ហើយទទួលយកការពិភាក្សា នោះពួកគាត់បានទទួលសាក្សីនៃសេចក្ដីពិតដ៏ពោរពេញរបស់ដំណឹងល្អ ហើយបានសម្រេចចិត្តជ្រមុជទឹក ។ ប៉ុន្តែ នាល្ងាចថ្ងៃសម្ភាសសម្រាប់បុណ្យជ្រមុជទឹក អ្នកផ្សព្វផ្សាយសាសនា និង ថ្នាក់ដឹកនាំពុំបានមកឡើយ ។ នៅក្នុងការប្រជុំបន្ទាប់របស់សាខា យាយតារបស់ខ្ញុំបានដឹងថា ដោយសារភាពចលាចលខ្លាំងខាងនយោបាយ នោះអ្នកផ្សព្វផ្សាយសាសនាទាំងអស់បានតម្រូវឲ្យចាកចេញពីប្រទេសនោះ ។ ឥឡូវនេះការប្រតិបត្តិសាសនាក៏នឹងត្រូវហាមឃាត់ ។ ប៉ុន្តែ ពួកបរិសុទ្ធមួយក្រុមតូចនៅក្នុងតំបន់បានបន្តសេចក្ដីជំនឿរបស់ពួកគេ ដែល

*ក្នុងខែសីហា ឆ្នាំ ១៩៦៨ គ្រួសាររបស់ខ្ញុំបានលាផ្ទះរបស់ពួកគាត់នៅក្នុងទីក្រុង ប្រាហ្គ ហើយគេចខ្លួនចេញដោយស្ងាត់ៗ ធ្វើដំណើរទៅប្រទេសអូទ្រីស ។*

ចេញរូបភាពដោយ វ៉ែនឌ ប៉ូល



បានដឹកនាំដោយថ្នាក់ដឹកនាំ និង កូនសោបព្វជិតភាពក្នុងមូលដ្ឋាន ។ យាយតារបស់ខ្ញុំ និង ម្ដាយមីងខ្ញុំបានជ្រមុជទឹកដោយសម្ងាត់នៅក្នុងឆ្នាំ ១៩៥០ ។

ប្អូនប្រាំឆ្នាំក្រោយមក សមាជិកនៅសាខានោះរួមទាំងយាយ និង ម្ដាយរបស់ខ្ញុំ ( កាលនោះនៅវ័យជំទង់ ) មានជួនកាលត្រូវបានប៉ូលីសនាំខ្លួនទៅដោយសម្ងាត់ ដើម្បីសួរសំណួរអំពីការប្រតិបត្តិសាសនារបស់ពួកគាត់ ។ មានគ្រាមួយនោះ យាយរបស់ខ្ញុំត្រូវបានសួរយ៉ាងខ្លាំង អស់រយៈពេលប្រាំម៉ោង ។ ប្រសិនបើពួកគេដឹងថា គាត់កំពុងបង្រៀនសាសនាដល់កូនៗរបស់គាត់ នោះពួកគេនឹងដាក់គុកគាត់រយៈពេលប្រាំឆ្នាំ ។

គាត់បានកត់ត្រាថា « ខ្ញុំបាននៅស្ងៀម ហើយនិយាយថា ‹ ប្រសិនបើអ្នកគិតថា ខ្ញុំបង្រៀនអំពីសាសនាដល់កូនរបស់ខ្ញុំគឺជារឿងខុស នោះអ្នកអាចចាប់ខ្ញុំដាក់គុកចុះ › ។ ពួកគេមិនបានឆ្លើយឡើយ ។ ចាប់តាំងពីពេលនោះមក ពួកគេបាននាំខ្ញុំទៅសួរចម្លើយម្ដងហើយម្ដងទៀត ។ ពួកគេនិយាយប្រឆាំងទាស់នឹងសាសនាចក្រ ហើយពួកគេព្យាយាមទាញពួកយើងចេញពីជំនឿរបស់យើង ។ ដរាបណាពួកគេកាន់តែព្យាយាមធ្វើបែបនោះ ដរាបនោះខ្ញុំកាន់តែកាន់ខ្ជាប់នឹងសាសនាចក្រ [ ដ្បិត ] សាសនាចក្រដែលពិតត្រូវបានគេបៀតបៀនជានិច្ច » ។

ម្ដាយរបស់ខ្ញុំបានសរសេរនៅក្នុងទិនានុប្បវត្តិរបស់គាត់ថា « នៅអំឡុងពេលប៉ុន្មានឆ្នាំដ៏លំបាកនេះ សមាជិកបានជួបជុំគ្នានៅថ្ងៃអាទិត្យនៅក្នុងផ្ទះរបស់ប្រធានសាខាយើង ។ យើងពុំអាចច្រៀងឮបានឡើយ ដូច្នោះហើយយើងបានច្រៀងខ្សឹបៗ ។ ពួកយើងមិនចង់ឲ្យគេចាប់ប្រធានសាខារបស់យើងដាក់គុកឡើយ ។ អស់រយៈពេល ១៨ ឆ្នាំ ដែលយើងបានជួបជុំគ្នាបែបនោះ ហើយយើងសង្ឃឹមពីគ្រាដែលយើងទាំងអស់គ្នានឹងអាចទៅភ្នំរ៉កគី ហើយតាំងទីលំនៅនៅក្នុង [ ទីក្រុង សលត៍លេក ] » ។ ពួកគាត់មានសង្ឃឹម ទោះបីជានៅគ្រានោះ ក្រុមគ្រួសារជាច្រើនមិនត្រូវបានផ្ដល់ឯកសារ ដែលនឹងអនុញ្ញាតឲ្យពួកគេចាកចេញពីប្រទេសបានក៏ដោយ ។

នៅពេលម្ដាយរបស់ខ្ញុំបានធំឡើងអំឡុងអាយុខ្ទង់ម្ភៃឆ្នាំ គាត់បានអធិស្ឋានដោយបំណងយ៉ាងខ្លាំង ដើម្បីអាចរៀបការជាមួយសមាជិកសាសនាចក្រ ហើយអាចផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

**ការស្វែងរកជីវិតថ្មី**

ឪពុករបស់ខ្ញុំ បានធំពេញវ័យឡើងនៅក្នុងភូមិដែលមានស្រែចម្ការ បានរស់នៅក្នុងទីក្រុង ទៅសាលារៀន ជាកន្លែងដែលគាត់បានជួបម្ដាយរបស់ខ្ញុំ ។ ម្ដាយរបស់ខ្ញុំបានចាប់ផ្ដើមអាជីពរបស់គាត់ជាអ្នកចម្រៀងអូប៉េរ៉ាអាជីព ។ នៅពេលពួកគាត់ស្គាល់គ្នា ម្ដាយរបស់ខ្ញុំបានណែនាំគាត់ឲ្យចូលព្រះវិហារ ។ ទោះបីជាឪពុកខ្ញុំមិនទាន់បានជ្រមុជទឹកក្ដី ឪពុកម្ដាយរបស់ខ្ញុំបានរៀបការនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ ។

នៅចុងឆ្នាំនោះ ពួកគេមានពរដោយបង្កើតបានបងប្រុសរបស់ខ្ញុំ ។ ប្រាំខែបន្ទាប់ពីបងប្រុសរបស់ខ្ញុំកើតមក ប្រធានសាខាបានទទួលវិវរណៈថា សមាជិកគួរតែរៀបចំខ្លួន ដើម្បីត្រូវបាននាំចេញពីប្រទេសនោះ ទៅកន្លែងមួយ ដែលពួកគេអាចថ្វាយបង្គំដោយមានសេរីភាព ។ នៅក្នុងខែសីហា ឆ្នាំ ១៩៦៨ ពួករុស្ស៊ី បានឈ្លានពានប្រទេសឆេកូស្លូវ៉ាគី ដោយបង្កើតឲ្យមាន ភាពចលាចលនៅព្រំដែន និង ទូទាំងប្រទេស ។ សមាជិកសាខា ដែលបានរៀបចំខ្លួនដោយការគោរពប្រតិបត្តិបានរត់គេចខ្លួនទៅទីក្រុង វីយែន ប្រទេសអូទ្រីស ។

យាយរបស់ខ្ញុំ ដែលបានចាកចេញពីប្រទេសនោះជាមួយឪពុកម្ដាយរបស់ខ្ញុំបានសរសេរដូចនេះ ៖ « នាយប់នោះ នៅពេលមនុស្សគ្រប់គ្នានៅក្នុងផ្ទះបានដេក យើងបានលាផ្ទះរបស់យើង ហើយដើរលបៗស្ងាត់ៗ ដោយក្ដីភ័យខ្លាចថាកូនក្មេងអាចចាប់ផ្ដើមស្រែកយំ ។ យើងត្រូវចេញទៅដោយសម្ងាត់ ពីព្រោះមានគីញសម្ងាត់បីនាក់នៅក្នុងអគាររបស់យើង ដែលធ្វើការឲ្យប៉ូលីសសម្ងាត់ ។ ព្រះអម្ចាស់បានប្រទានពរដល់ពួកយើង ។ ពួកយើងបានគេចខ្លួនផុត ។ នៅពេលយើងបានចាកចេញ យើងបានដឹងថា យើង [ នឹង ] ពុំត្រឡប់ទៅវិញឡើយ ប៉ុន្តែយើងក៏ពុំដឹងថាយើងនឹងទៅទីណាទៀតដែរបន្ទាប់ពីចេញពីទីក្រុងវីយែន ។ កាលគ្រានោះយើងពុំអាចមិនបារម្ភ



*ឪពុកម្ដាយរបស់ខ្ញុំបានទៅដល់ទីក្រុង កាលហ្គារី ដោយមានតែវ៉ាលីមួយ រទេះរុញកូនមួយ និង ប្រាក់តែបន្តិចបន្តួចប៉ុណ្ណោះ ។ សមាជិកនៅប្រទេសកាណាដាបានចាប់ផ្ដើមជួយគ្រួសាររបស់ខ្ញុំភ្លាមៗផងដែរ ដោយផ្ដល់ជំនួយ ដូចជាមធ្យោបាយធ្វើដំណើរ ទិញទំនិញ និង រកផ្ទះ ។*

អំពីរឿងនោះឡើយ ។ ព្រះអម្ចាស់បានបង្ហាញដល់ប្រធានសាខានូវការសន្យារបស់ទ្រង់ចំពោះពួកយើង ប្រសិនបើយើងបន្តនៅស្មោះត្រង់ចំពោះទ្រង់ » ។

**ទឹកដីថ្មីសូមស្វាគមន៍**

យាយ ឪពុកម្ដាយរបស់ខ្ញុំ និង គ្រួសារពីរផ្សេងទៀត បានរស់នៅក្នុងបន្ទប់ជាន់ដីនៅ ប៉កឃ្លីនស្រ្តាស អគារសាសនាចក្រនៅទីក្រុងវីយែនអស់រយៈពេលមួយខែ ។ អំឡុងខែនោះ ឪពុករបស់ខ្ញុំបានរៀនជាមួយអ្នកផ្សព្វផ្សាយសាសនា ហើយបានជ្រមុជទឹក ។ សមាជិកជាច្រើននៃគ្រួសារទាំងបីរកការងារបានធ្វើ ហើយពួកគេបានដាក់ប្រាក់ដែលរកបានជាមួយគ្នា រហូតដល់ពួកគេទាំងអស់គ្នាអាចធ្វើអន្តោប្រវេស្តន៍ទៅទីក្រុង កាលហ្គារី អាល់បើរតា ប្រទេសកាណាដា ។ ដោយសារតែអាកាសធាតុមិនល្អនៅទីក្រុង កាលហ្គារី យន្តហោះរបស់ពួកគាត់បានចុះចតនៅទីក្រុង អែតមុនតុន នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ។

ដោយបានចាកចោលសាច់ញាតិ វប្បធម៌ និង ទឹកដីដែលពួកគាត់ស្រឡាញ់ នោះគឺជាការបូជាដ៏លើសលុបមួយ ប៉ុន្តែការលំបាកជាច្រើនវាគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ ពេលទៅដល់ទីក្រុង កាលហ្គារី ដោយមានតែវ៉ាលីមួយ រទះរុញកូនមួយ និង ប្រាក់ ៣២ ដុល្លារកាណាដា នោះឪពុកម្ដាយរបស់ខ្ញុំមានការខ្វះខាតខ្លាំងណាស់ ។

សមាជិកនៅប្រទេសកាណាដាបានចាប់ផ្ដើមបម្រើគ្រួសាររបស់ខ្ញុំភ្លាមៗផងដែរ ដោយផ្ដល់ជំនួយសប្បុរសដូចជាមធ្យោបាយធ្វើដំណើរ ទិញទំនិញ និង រកផ្ទះជួល ។ ក្នុងអំឡុងពេលមួយសប្ដាហ៍ ឪពុកម្ដាយ និង យាយរបស់ខ្ញុំរកបានផ្ទះដែលមានគ្រែ តុ និង កៅអី គ្រែទម្រេត កូនគ្រែ មុងភួយ ចានក្បាន និង មានអាហារមួយចំនួននៅក្នុងទូ ។ ម្ដាយរបស់ខ្ញុំបានសរសេរនៅក្នុងទិនានុប្បវត្តិរបស់គាត់ពីក្ដីរំភើប និង ក្ដីញាប់ញ័រចំពោះការឃើញគ្រឿងសង្ហារិមដ៏អស្ចារ្យទាំងនោះ ហើយមានអំណរគុណចំពោះការបម្រើដែលគាត់បានទទួល ។

ប៉ុន្តែជាមួយនឹងអារម្មណ៍នៃការដឹងគុណ ក៏មាននូវការរំជួលចិត្តផងដែរ ។ ការទម្លាប់នឹងវប្បធម៌ថ្មីនោះគឺមានការលំបាកណាស់ ។ ការរស់នៅក្នុងឆ្នាំដំបូងនៅក្នុងទីក្រុង កាលហ្គារី គឺមានតែការខំប្រឹងរៀនភាសាអង់គ្លេសប៉ុណ្ណោះ ហើយឪពុករបស់ខ្ញុំត្រូវដើរទៅធ្វើការក្នុងអាកាសធាតុដ៏ត្រជាក់ ។ ពួកគាត់បានធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីបង្កើតអារម្មណ៍មួយថាវាជាផ្ទះយើង ប៉ុន្តែវានៅតែជាគ្រាមួយនៃការសាកល្បង ជាមួយនឹងការផ្លាស់ប្ដូរយ៉ាងខ្លាំង ។ ពួកបរិសុទ្ធនៅវួដថ្មីរបស់ពួកគាត់នៅ កាលហ្គារី បានធ្វើការខិតខំយកជំនះលើរនាំងនៃភាសា ដើម្បីគាំទ្រដល់សមាជិកថ្មីដែលទើបនឹងមកដល់ ។ រៀងរាល់ថ្ងៃអាទិត្យគ្រួសាររបស់ខ្ញុំបានទទួលកម្លាំង នៅពេលពួកគាត់បានចូលរួមការប្រជុំសាក្រាម៉ង់ ដើម្បីរំឭកពីសេចក្ដីសញ្ញារបស់ពួកគាត់ ដោយផ្អែកលើព្រះវិញ្ញាណបង្រៀនភាសាអង់គ្លេសដល់ពួកគាត់ ។

**ពរជ័យនៃភាពអស់កល្បជានិច្ច**

គ្រួសាររបស់យើងដែលមានគ្នាប្រាំនាក់បានផ្សារភ្ជាប់ជាមួយគ្នានៅក្នុងព្រះវិហារបរិសុទ្ធ ខាតស្តុន អាល់បើរតានៅក្នុងខែតុលា ឆ្នាំ ១៩៧៦ ។ ម្ដាយរបស់ខ្ញុំបានដាក់ផែនការនៅថ្ងៃនេះកាលពី ២០ ឆ្នាំមុន ហើយទីបំផុត នៅក្នុងប្រទេសមួយ និង ក្នុងភាសាមួយដែលគាត់មិនធ្លាប់ស្រមៃកាលពីយុវវ័យ នោះគាត់បានទទួលចម្លើយចំពោះការអធិស្ឋានរបស់គាត់ ។ កាលនោះខ្ញុំមានអាយុជិតប្រាំបីឆ្នាំ ហើយខ្ញុំបានចាំច្បាស់ពីកែវភ្នែកដ៏ភ្លឺថ្លា និង ស្នាមញញឹមរបស់ឪពុកម្ដាយខ្ញុំ នៅពេលកូនៗបានចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់ ។

យាយរបស់ខ្ញុំក៏បានទៅព្រះវិហារបរិសុទ្ធនៅថ្ងៃនោះផងដែរ ។ ខ្ញុំបានចាំពីក្ដីរំភើបរបស់គាត់ ពេលឃើញពន្លឺភ្លើងព្រះវិហារបរិសុទ្ធនៅពេលយើងបានទៅដល់ទីក្រុង ខាតស្តុន ។ ជាច្រើនឆ្នាំក្រោយមក បន្ទាប់ពីចូលនិវត្តន៍ពីការងាររបស់គាត់នៅទីក្រុងកាលហ្គារី ម្ដាយរបស់ខ្ញុំបានប្ដូរទៅនៅទីក្រុងខាតស្តុន ហើយបានចំណាយពេលច្រើនក្នុងការបម្រើនៅព្រះវិហារបរិសុទ្ធ ។ គាត់ចូលចិត្តលេងព្យាណូខ្យល់ ហើយជួយឲ្យមានការបំផុសនូវគារវភាពនៅទីនោះ ។ ទីបន្ទាល់ និងសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះអង្គសង្គ្រោះ គឺបានបញ្ជាក់បង្ហាញតាមរយៈសេចក្ដីសប្បុរសរបស់គាត់ចំពោះមនុស្សនៅជុំវិញខ្លួនរបស់គាត់ ។ ចំពោះខ្ញុំគាត់គឺជាគំរូមួយដ៏រឹងមាំនៃស្ត្រីពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឪពុកម្ដាយរបស់ខ្ញុំ—ជាអ្នកត្រួសត្រាយក្នុងគ្រួសាររបស់ខ្ញុំ—ចំពោះការបូជាក្នុងការងារ សាច់ញាតិ ទឹកដីកំណើត និង ទ្រព្យសម្បត្តិរបស់ពួកគាត់ ។ ពួកគាត់បានលះបង់យ៉ាងច្រើន ប៉ុន្តែព្រះអម្ចាស់បានប្រទានពរដល់ពួកគាត់យ៉ាងលើសលុប—និងពូជពង្សរបស់ពួកគាត់—ដោយសារការរស់នៅតាមគោលការណ៍នៃដំណឹងល្អ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ អៃដាហូ ស.រ.អា*



**បម្រើដល់ជនភៀសខ្លួន**

យើងសង្ឃឹមថា បងប្អូននឹងតាំងចិត្តដោយការអធិស្ឋានថា បងប្អូនអាចធ្វើអ្វីខ្លះ—ទៅតាមពេលវេលា និង ស្ថានភាពផ្ទាល់ខ្លួនរបស់បងប្អូន—ដើម្បីបម្រើដល់ជនភៀសខ្លួន និងជនអន្តោប្រវេស្តន៍រស់នៅក្នុងសហគមន៍របស់បងប្អូន ។ នេះគឺជាឱកាសមួយ ដើម្បីបម្រើដោយផ្ទាល់ក្នុងក្រុមគ្រួសារ និង តាមអង្គការដើម្បីផ្ដល់មិត្តភាព ការប្រឹក្សា និងការបម្រើផ្សេងៗទៀតដូចព្រះគ្រីស្ទ » ។

**លីនដា ខេ បើតុន ប្រធានសមាគមសង្គ្រោះទូទៅ « I Was a Stranger » *Liahona* ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ១៤ ។**

# អំពូលភ្លើងពណ៌ខៀវមួយ

ម្ដាយ និង ឪពុកខ្ញុំពុំយល់ស្របគ្នានឹងរបៀបតុបតែងផ្ទះរបស់ពួកគាត់នៅពេលបុណ្យគ្រីស្ទម៉ាស់ឡើយ ។ ឪពុករបស់ខ្ញុំមានជំងឺងងឹតពណ៌ ដូច្នោះចំពោះគាត់ពណ៌ក្រហម បៃតង និង ពណ៌ត្នោត គឺគាត់មើលទៅវាស្រដៀងគ្នា ហើយស្រអាប់ ។ ប៉ុន្តែ គាត់មើលឃើញពណ៌ខៀវថាជាពណ៌ដែលភ្លឺ និង ស្រស់ស្អាត ។ គាត់ក៏ជាអ្នកគាំទ្រដ៏ខ្លាំងដល់ក្រុមបាល់ឱបនៃសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ដែលមានឯកសណ្ឋានពណ៌ខៀវដែរ ។

ដោយសារពណ៌ខៀវគឺជាពណ៌ដែលគាត់ចូលចិត្ត នោះគាត់ចង់ដាក់តាំងភ្លើងដែលមានពណ៌ខៀវ ។ ប៉ុន្តែម្ដាយរបស់ខ្ញុំបាននិយាយថា ពណ៌ខៀវមិនមែនជាពណ៌សម្រាប់បុណ្យគ្រីស្ទម៉ាស់ទេ ដូច្នោះរៀងរាល់ឆ្នាំ ប៉ាបានចងខ្សែភ្លើងបុណ្យគ្រីស្ទម៉ាស់ពណ៌ក្រហម បៃតង និង ពណ៌សនៅលើដំបូលផ្ទះរបស់ពួកគាត់ ។ ដើម្បីឪដងដាក់ម៉ាក់ គាត់ជំនួសអំពូលភ្លើងមួយដោយដាក់អំពូលនោះពណ៌ខៀវ ។ ប្រសិនបើអ្នកមើលវាឲ្យកៀក អ្នកនឹងឃើញអំពូលពណ៌ខៀវមួយក្នុងចំណោមអំពូលភ្លើងពណ៌ក្រហម បៃតង និង ស ។

រៀងរាល់ឆ្នាំអំពូលភ្លើងពណ៌ខៀវនោះបានភ្លឺនៅទីតាំងផ្សេងៗគ្នា ។ ជួលកាលវាភ្លឺនៅជុំវិញតំបន់កាច់ជ្រុងដែល គ្មាននរណាចាប់អារម្មណ៍នឹងឃើញវាឡើយ ប៉ុន្តែជួនកាលគាត់បានដាក់វានៅលើកន្លែងចតឡាន ឬនៅមុខហោណ៌ង ។ វាជាល្បែងកម្សាន្តដ៏សប្បាយរវាងម៉ាក់ និង ប៉ា ។

នាគ្រាមួយនោះ ប៉ាបានស្លាប់ដោយចៃដន្យពីរថ្ងៃពីមុនបុណ្យគ្រីស្ទម៉ាស់ ។ នៅក្នុងពិធីបុណ្យសពរបស់គាត់ មានអ្នកនិយាយប្រាប់រឿងមួយអំពីអំពូលភ្លើងពណ៌ខៀវ ដែលប៉ាបានដាក់វារៀងរាល់ឆ្នាំ ។ យប់ស្អែកឡើង ម្ដាយរបស់ខ្ញុំបានសម្លឹងមើលទៅក្រៅតាមបង្អួច ។ នៅផ្លូវម្ខាងទៀត ក្នុងចំណោមអំពូលភ្លើងពណ៌សមានអំពូលភ្លើងពណ៌ខៀវមួយ នៅខាងលើហោណ៌ងរបស់អ្នកជិតខាងរបស់ម៉ាក់ ។ ក្នុងអំឡុងពេលពីរបីថ្ងៃនោះ មានអ្នកជិតខាង និង មិត្តភក្តិជាច្រើនបានបន្ថែមអំពូលភ្លើងពណ៌ខៀវលើខ្សែអំពូលភ្លើងបុណ្យគ្រីស្ទម៉ាស់របស់ពួកគេ ។ មានអ្នកខ្លះបានតុបតែងដើមឈើរបស់ពួកគេជាពណ៌ខៀវសុទ្ធ ។

ខ្ញុំមានអំណរគុណដែលមិត្តភក្តិរបស់ម្ដាយខ្ញុំ បានបង្ហាញសេចក្ដីស្រឡាញ់ចំពោះគាត់ ដោយការតុបតែងផ្ទះជាមួយអំពូលភ្លើងពណ៌ខៀវ ។ ពួកគេបានជួយខ្ញុំឲ្យដឹងពីអត្ថន័យនៃការ « ទួញយំជាមួយនឹងអ្នកណាដែលទួញយំ . . . ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវកម្សាន្តទុក្ខ » ( ម៉ូសាយ ១៨:៩ ) ។ ខ្ញុំមានអំណរគុណដែលព្រះវរបិតាសួគ៌ពេញដោយក្ដីស្រឡាញ់ ប្រទានព្រះរាជបុត្រារបស់ទ្រង់ជាអំណោយដល់យើង ។ ដោយសារតែព្រះយេស៊ូវគ្រីស្ទ នោះខ្ញុំនឹងអាចជួបប៉ាខ្ញុំម្ដងទៀត ។ ■

អែមមី ប្រោន រដ្ឋ យូថាហ៍ ស.រ.អា.

ប្រសិនបើអ្នកមើលវាឲ្យកៀក អ្នកនឹងឃើញអំពូលភ្លើងពណ៌ខៀវមួយក្នុងចំណោមអំពូលភ្លើងពណ៌ក្រហម បៃតង និង ស ។



រចនារូបភាពដោយ អេលែន ហ្គានស៍



នៅពេលគាត់ដើរចេញទៅវិញ យើងបានឃើញគាត់យកគម្ពីរឱបនឹងដើមទ្រូងគាត់ ។

រចនារូបភាពដោយ ស្វេន ហ្វៃឡូ

# ចែកចាយក្ដីអំណរ

ស្វាមីខ្ញុំ និងខ្ញុំ គឺជាអ្នកផ្សព្វផ្សាយសាសនាបម្រើនៅ ថាបែស ប្រទេសបារាំង នៅភ្នំផៃរ៉ែនណេស ។ វាគឺជាយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ ហើយយើងបានសម្រេចចិត្តទៅទីក្រុងនៅ ពីរជុនផ្លាស្យា ដើម្បីចែកព្រះគម្ពីរមរមន ។ នៅតាមផ្លូវគ្មានមនុស្សទ្បើយ ហើយយើងបានចាប់ផ្ដើមសួរខ្លួនឯង ពីអ្វីដែលយើងនឹងធ្វើជាមួយនឹងព្រះគម្ពីរដ៏ច្រើននេះ ។ ភ្លាមនោះ យើងបានឃើញយុវជនម្នាក់ដែលទំនងជាមិនដឹងថាត្រូវទៅណា ។

យើងបានដើរទៅរកគាត់ ហើយឲ្យព្រះគម្ពីរមរមនមួយក្បាលដល់គាត់ ។ គាត់បានប្រែជាមានអំណរនៅពេលគាត់បានស្ដាប់ពួកយើងនិយាយអំពីដំណឹងល្អ ។ គាត់បានប្រាប់ថា គាត់នៅឯកោតែឯងនាយប់បុណ្យគ្រីស្ទម៉ាស់នោះ ហើយថាគាត់នឹងអានព្រះគម្ពីរមរមន ហើយគ្មានអារម្មណ៍ឯកោទៀតទ្បើយ ។

បន្ទាប់ពីគាត់បានចាកចេញទៅ យើងបានមើលទៅតាមដងផ្លូវម្ដងទៀត ហើយបានឃើញស្ត្រីម្នាក់ដើរយឺតៗ សំដៅមកយើងក្នុងរាត្រីដ៏ត្រជាក់នោះ ។ យើងអាចឃើញភាពរីករាយនៅលើផ្ទៃមុខរបស់គាត់នៅពេលយើងបានបង្ហាញព្រះគម្ពីរមរមន ដល់គាត់ ។ គាត់បានប្រាប់យើងថា គាត់ទើបតែក្លាយជាស្ត្រីមេម៉ាយ ហើយគាត់សប្បាយចិត្តដែលយើងខ្វាយខ្វល់ពីគាត់ ។ គាត់បាននិយាយថា គាត់មានអំណរគុណចំពោះពួកយើងខ្លាំងណាស់ ។ នៅពេលគាត់ដើរចេញទៅវិញ យើងបានឃើញគាត់យកគម្ពីរឱបនឹងដើមទ្រូងគាត់ ។

នារាត្រីនោះ យើងបានចែកព្រះគម្ពីរមរមនទាំងអស់ដែលយើងបានយកទៅជាមួយយើង ។ ភាគច្រើនមនុស្សដែលយើងបានចែកព្រះគម្ពីរឲ្យគឺជាអ្នកដែលនៅឯកោ បាក់ទឹកចិត្ត និង ត្រូវការក្ដីស្រឡាញ់ជាខ្លាំង ។ យើងបានត្រឡប់ទៅផ្ទះវិញនារាត្រីនោះ ដោយសេចក្ដីរំភើបថា យើងបានទទួលអំណោយបុណ្យគ្រីស្ទម៉ាស់ដ៏អស្ចារ្យបំផុត ដោយសារអំណរដែលយើងបានចែកឲ្យមនុស្សដទៃ ។ ■

ជិនណាញ ដៃននីស ហ្វាប្រេ សេន អនទ្រេ លេស ពីរហ្កើរ ប្រទេសបារាំង

# ស្វាគមន៍ដល់ព្រះយេស៊ូវ

បន្ទាប់ពីប៉ុន្មានសប្ដាហ៍នៃការត្រៀមទុកជាមុន នោះយប់មុនថ្ងៃបុណ្យគ្រីស្ទបានមកដល់ ។ គ្រួសារយើងទាំងអស់គ្នាបាននៅជាមួយពួកយើង—ជីដូន និង ជីតា ហ្វៃតឈើ កូនស្រីទាំងបីរបស់ពួកយើង និង ស្វាមី ព្រមទាំងកូនៗរបស់ពួកគេ ។ វាជិតយប់ទៅហើយ ហើយនៅតាមផ្លូវមានភ្លើងត្រូវបានបើកបំភ្លឺឡើង ។ ផ្ទះនានាមានពន្លឺភ្លើងព្រាកៗដោយការតុបតែងយ៉ាងស្រស់ស្អាត មានដើមគ្រីស្ទម៉ាស់ជះពន្លឺភ្លឹបភ្លែតៗនៅតាមបង្អួច ។

យើងបានត្រៀមខ្លួនរួចជាស្រេច ដើម្បីទៅកម្មវិធីសម្ដែងល្ខោនអំពីព្រះប្រសូតកម្ម ដែលសាសនាចក្របានធ្វើការសម្ដែងអស់រយៈពេលជាច្រើនឆ្នាំមក ហើយនៅក្នុងទីក្រុង កាលហ្គារី អាល់ប៊ើរតា ប្រទេសកាណាដា ។ រៀងរាល់យប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ យើងអន្ទះសារចង់ទៅកម្មវិធីសម្ដែងល្ខោននោះ ដែលមានសុទ្ធតែ សត្វលា ចៀម ពួកហោរា អ្នកគង្វាលចៀម ទាហានរ៉ូម ពួកទេវតា និង ប្រព័ន្ធសំឡេងដ៏ជាទីជាប់ចិត្ត ។ កម្មវិធីនេះបាននាំវិញ្ញាណនៃភាពសុខសាន្ត សេចក្ដីស្រឡាញ់ និង អត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស់មកកាន់ការប្រារព្ធពិធីដ៏រំភើបរបស់យើង ។

យើងបានមកដល់សួនឧស្សាហ ហើរីថេក ជាកន្លែងដែលមានការសម្ដែងល្ខោន ហើយបានរីករាយនឹងតន្ត្រីដ៏ពិរោះនៃក្រុមចម្រៀងរោងឧបោសថមរមន និងការសម្ដែងរឿងអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។ ឡូរ៉ែនចៅច្បងរបស់យើងមានអាយុបីឆ្នាំកាលគ្រានោះ ។ នាងជក់ចិត្តនឹងការសម្ដែង សំឡេង និង រឿងដែលបានសម្ដែងនៅចំពោះមុខយើង ។ ដង្ហើមយើងដកចេញមកដូចជាផ្សែង ដោយអាកាសធាតុត្រជាក់នៅក្រោមមេឃស្រឡះដែលមានផ្កាយរះព្រោងព្រាត ។ យើងមើលនៅពេលគេសម្ដែងតួយ៉ូសែប និង ម៉ារាបានធ្វើតាមព្រះរាជក្រឹត្យរបស់ស្ដេច សេសារ-អូគូស្ទឲ្យទៅ បេថ្លេហិមដើម្បីបង់ពន្ធ ។ ស្ដ្រីដើរតួជាម៉ារាជាស្ដ្រី « មានគភ៌ » ( សូមមើល លូកា ២:៥ ) ហើយមានកន្លែងតែមួយគត់ដែលពួកគេអាចរកបានដើម្បីស្នាក់នៅនោះគឺនៅក្រោលសត្វដ៏រាបទាប ។ នៅទីនោះ « នាងប្រសូតបានបុត្រាជាចម្បងមក រួចរុំនឹងសំពត់ផ្ដេកក្នុងស្នូក » ( សូមមើល លូកា ២:៧ ) ។ ពន្លឺបានបាញ់ចាំងទៅលើកូនភ្នំជាកន្លែងដែលយើងអាចឃើញមនុស្សដែលដើរតួជាអ្នកគង្វាលចៀមកំពុង « ចាំយាមរក្សាហ្វូងចៀមរបស់ខ្លួនក្នុងវេលាយប់ » ( សូមមើល លូកា ២:៨ ) ។ ស្រាប់តែ មានតួមួយដែលស្លៀកពាក់ជាទេវតាបានបង្ហាញខ្លួនភ្លាម នៅលើអាកាស ដោយមានពន្លឺភ្លើងបានបាញ់បញ្ចាំងចំគាត់ ។ ឡូរ៉ែនបានស្រែកឡើងភ្លាមដ៏គួរឲ្យស្រឡាញ់ថា « ព្រះយេស៊ូវគឺខ្ញុំម្ចាស់ឈ្មោះឡូរ៉ែន ! »

មនុស្សគ្រប់គ្នានៅជុំវិញយើងបានឮពាក្យស្វាគមន៍របស់នាង ហើយសើចតិចៗ ដោយរីករាយនឹងការភ្ញាក់ផ្អើលនោះ ។ នាងពុំបានដឹងថាទេវតានោះជានរណាទេ ប៉ុន្តែសម្រាប់ពួកយើងវាបានបង្កើននូវការចងចាំអំពីការសម្ដែងល្ខោននាឆ្នាំនោះ ។ ឡូរ៉ែនបានដឹងថាព្រះយេស៊ូវបានស្គាល់នាង ហើយយើងត្រូវបានរំឮក

គំនូរដោយ ដាន ប៊ើរ



អំពីការចេះដឹងរបស់យើងថា ទ្រង់ស្គាល់ពួកយើងម្នាក់ៗ ។ យើងឆ្ងល់ ប្រសិនបើឡូរ៉ែនមានការចងចាំខ្លះៗ អំពីព្រះអង្គសង្គ្រោះរបស់នាង ដែលនាងទើបតែបានចាកចេញពីទ្រង់បីឆ្នាំយ៉ាងខ្លីមុននេះប៉ុណ្ណោះ ។ ការស្វាគមន៍ដោយឯកឯងរបស់ឡូរ៉ែនបានផ្តល់ក្តីសង្ឃឹមដល់ពួកយើងថា យើងក៏នឹងទទួលស្គាល់ទ្រង់ដែរ នៅពេលយើងជួបទ្រង់ ។ សេចក្តីស្រឡាញ់របស់នាងចំពោះព្រះអង្គសង្គ្រោះ និង សេចក្តីស្រឡាញ់របស់ទ្រង់ចំពោះឡូរ៉ែនធ្វើឲ្យយើងមានចិត្តកក់ក្តៅ នៅយប់មុនថ្ងៃបុណ្យគ្រីស្ទដែលធ្លាក់ព្រិលនោះ ។ ■

ហ្គេច ព្រីនស៍ អាល់ប៊ឺតា ប្រទេសកាណាដា

# ការប្រជុំសាក្រាម៉ង់នៃពួកទេវតា

ពីរបីថ្ងៃបន្ទាប់ពីបុណ្យថ្លែងអំណរគុណ កូនប្រុសអាយុបីឆ្នាំរបស់ខ្ញុំ ឌ្រូ ចាប់ផ្តើមឈឺ ។ គាត់ភ្ញាក់ដឹងខ្លួនឡើងរៀងរាល់ព្រឹក ស្រស់ស្រូបអាហារពេលព្រឹក ស្លៀកសម្លៀកបំពាក់ ហើយទំនងដូចជាគ្មានអ្វីកើតឡើងឡើយ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃ គាត់ប្រែកាន់តែខ្សោយទៅៗ ហើយមិនបរិភោគអាហារ ។

ការណ៍នេះបន្តអស់រយៈពេលបួនប្រាំសប្តាហ៍ ។ ទីបំផុត នៅថ្ងៃសុក្រ ទី ១៨ ខែ ធ្នូ ខ្ញុំបានយកឌ្រូទៅការិយាល័យវេជ្ជបណ្ឌិតនៅអំឡុងម៉ោង ៣រសៀល ។ ឌ្រូ ពុំអាចឈរ ឬ ដើរបានឡើយ ហើយស្បែករបស់គាត់មានសភាពស្លេកស្លាំង ។

ខ្ញុំបានមើលទៅវេជ្ជបណ្ឌិត ហើយនិយាយថា « គាត់មានសភាពបែបនេះរៀងរាល់ពេលរសៀល និង ល្ងាចអស់រយៈពេលបីសប្តាហ៍មកហើយ » ។ វេជ្ជបណ្ឌិតបានក្រឡេកមើលទៅឌ្រូ ហើយបានដាក់ឲ្យគាត់សម្រាកពេទ្យភ្លាម ។ ពួកគាត់បានធ្វើតេស្តជាច្រើន ប៉ុន្តែពុំអាចរកឃើញថាគាត់ឈឺអ្វីឡើយ ។

ថ្ងៃស្អែកឡើងឌ្រូត្រូវបានបញ្ជូនទៅមន្ទីរពេទ្យផ្សេងមួយទៀត ។ នាព្រឹកថ្ងៃអាទិត្យនោះ ខ្ញុំមានអារម្មណ៍បាក់ទឹកចិត្តជាខ្លាំង ។ បន្ទាប់ពីធ្វើតេស្តជាច្រើនអស់រយៈពេលពីរថ្ងៃក្រោយមកពីមន្ទីរពេទ្យទាំងពីរនោះ គ្មានមន្ទីរពេទ្យណាដឹងថាកូនប្រុសរបស់ខ្ញុំឈឺអ្វីឡើយ ។ លើសពីនេះទៀត វាគឺជាថ្ងៃអាទិត្យមុនបុណ្យគ្រីស្ទម៉ាស់ ។ ការប្រជុំសាក្រាម៉ង់ដែលខ្ញុំពេញចិត្តពេញមួយឆ្នាំនោះ គឺជាកម្មវិធីបុណ្យគ្រីស្ទម៉ាស់ ហើយខ្ញុំនឹងនឹកបទចម្រៀងពិរោះៗទាំងអស់ និង ការឡើងនិយាយនៅក្នុងវួដរបស់យើង ។

នៅពេលស្វាមីរបស់ខ្ញុំ និង ខ្ញុំកំពុងដើរជាមួយឌ្រូទៅកាន់បន្ទប់នៅក្នុងមន្ទីរពេទ្យ ជាកន្លែងដែលការប្រជុំសាក្រាម៉ង់បានធ្វើឡើង ខ្ញុំពិបាកចិត្តណាស់ ។ ខ្ញុំបានទៅដល់តុដែលមានក្រដាសកម្មវិធីប្រជុំ បានយកក្រដាសនោះមួយសន្លឹកឡើង ហើយបន្តដើរទៅមុខ ហើយឱនមុខចុះ នៅពេលខ្ញុំជួបនឹងមនុស្សម្នាក់ ។

ខ្ញុំបានងើយមុខឡើង ហើយនិយាយថា « ខ្ញុំសុំទោស » ប៉ុន្តែគ្មាននរណាម្នាក់នៅទីនោះឡើយ ។ នៅពេលខ្ញុំបានមើលទៅក្នុងបន្ទប់ ជាកន្លែងដែលពិធីសាក្រាម៉ង់ត្រូវប្រារព្ធឡើង វាហាក់បីដូចជារោងភាពយន្ត ។ នៅលើវេទិកាមានកៅអីសម្រាប់អ្នកនិយាយ ព្យាណូ និង តុដែលបានរៀបចំសម្រាប់សាក្រាម៉ង់ ដោយមានកៅអីពីរបីនៅពីក្រោយតុនោះ ។ បន្ទប់នោះមានក្មេងៗដែលឈឺ និង ឪពុកម្តាយរបស់ពួកគេ មានក្មេងៗជាច្រើនព្យួរសារ៉ូមដែលអាចចល័តបាន ។

នៅពេលខ្ញុំសម្លឹងមើលក្នុងបន្ទប់នោះ ខ្ញុំទទួលអារម្មណ៍នៃវត្តមានរបស់ពួកទេវតា ។ យើងបានអង្គុយ ហើយបានយំ នៅពេលខ្ញុំទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ព្រះ ចំពោះកូនចៅរបស់ទ្រង់ដែលមានជំងឺ និង រងទុក្ខ ស្នាក់នៅមន្ទីរពេទ្យដោយមានជំងឺគ្រប់បែបយ៉ាង នៅក្នុងគ្រាដ៏អស្ចារ្យបំផុតនៃឆ្នាំនោះ ។

វាបានក្លាយជាការប្រជុំសាក្រាម៉ង់ដ៏អស្ចារ្យបំផុតក្នុងជីវិតខ្ញុំ ។

វេជ្ជបណ្ឌិតពុំបានរកឃើញថា ឌ្រូឈឺអ្វីឡើយ ។ គាត់ទទួលថ្នាំដើម្បីព្យាបាលរោគសញ្ញារបស់គាត់ ហើយគាត់បានចេញពីមន្ទីរពេទ្យនៅថ្ងៃបន្ទាប់ ។ គាត់គ្មានផលប៉ះពាល់អវិជ្ជមានអ្វីឡើយចាប់តាំងពីពេលនោះមក ប៉ុន្តែការប្រជុំសាក្រាម៉ង់នាបុណ្យគ្រីស្ទម៉ាស់នោះនឹងនៅដក់ជាប់ក្នុងចិត្តខ្ញុំជារៀងរហូត ។ ■

ឃែរី ខែតឈឹម ណេវ៉ាដា ស.រ.អា.

ស្រាប់តែ មានតួមួយដែលស្លៀកពាក់ជាទេវតាបានបង្ហាញខ្លួនភ្លាម នៅលើអាកាស ដោយមានពន្លឺភ្លើងបានបាញ់បញ្ចាំងចំគាត់ ។





ដោយអែលឌើរ ឈី ហុង
(សាំ) វ៉ុង
នៃពួកចិតសិបនាក់

## សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ៖

# គុណធម៌ដែលវេញត្របាញ់ចូលគ្នា

ប្រីដ្បិតតែគម្ពីរម៉ូរ៉ូណៃនៅក្នុងព្រះគម្ពីរមរមនបានសរសេរខ្លី ដូចជាមានតែ ១០ ជំពូកប៉ុណ្ណោះ ប៉ុន្តែវាផ្តល់នូវការទូន្មានដ៏អស្ចារ្យបំផុត ។ ទាំងម៉ូរ៉ូណៃ និង មរមនបង្រៀនគោលការណ៍ដ៏មានតម្លៃអំពីដំណឹងល្អ ។ នៅពេលម៉ូរ៉ូណៃកំពុងសរសេរបញ្ចប់នូវការសង្ខេបព្រះគម្ពីរមរមនរបស់ឪពុកលោក នោះលោកបានរំឭកម្តងហើយម្តងទៀតអំពីការបង្រៀនរបស់ឪពុកលោក អំពីទំនាក់ទំនងរវាងសេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីសប្បុរស ។ មរមន និង ម៉ូរ៉ូណៃ ចង់គូសបញ្ជាក់ឲ្យច្បាស់អំពីសារៈសំខាន់នៃគោលការណ៍ទាំងបីនេះ ។

កាលពីគ្រាដំបូងដែលខ្ញុំសិក្សាព្រះគម្ពីរមរមន ខ្ញុំតែងតែគិតថាគោលការណ៍ទាំងបីនេះហាក់បីដូចជាជុំតជ្ជុតម្រៀបតលើគ្នា ។ សេចក្តីជំនឿត្រូវកើតឡើងជាមុន បន្ទាប់មកសេចក្តីសង្ឃឹម ហើយបន្ទាប់ទៀតគឺសេចក្តីសប្បុរស ។ វាហាក់បីដូចជាដំណើរការជាចង្កោមជាប់គ្នា ។ នៅពេលសេចក្តីជំនឿរបស់យើងរីកចម្រើន នោះការសិក្សា និង ចំណេះដឹងរបស់យើងកើនឡើង ហើយយើងចាប់ផ្តើមអនុវត្តគោលការណ៍នៃសេចក្តីសង្ឃឹម ។ សេចក្តីជំនឿ និង សេចក្តីសង្ឃឹមរួមគ្នារៀបចំ ហើយ ដឹកនាំយើងនៅលើផ្លូវដែលព្រះអង្គសង្គ្រោះបានដើរ ហើយយើងចាប់ផ្តើមទទួលបានបុគ្គលិកលក្ខណៈនៃសេចក្តីសប្បុរស ។

ប៉ុន្តែនៅក្នុងការសិក្សាបន្ថែមទៀតក្នុងពេលថ្មីៗនេះ ខ្ញុំបានយល់អំពីសេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីសប្បុរសតាមរបៀបមួយផ្សេងទៀត ។ ឥឡូវនេះ ខ្ញុំគិតអំពីពាក្យទាំងបីនេះកាន់តែច្រើនថាជាគុណធម៌ដែលវេញត្របាញ់ចូលគ្នា គុណធម៌នីមួយៗដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើន និង ការចង្អុលបង្ហាញពីទីបន្ទាល់របស់យើង ។

ចយ កូនស្រីរបស់ពួកយើង ចូលចិត្តធ្វើរូបសត្វ និង វត្ថុផ្សេងៗដោយការកាច់បត់បែនប៉េងប៉ោងចូលគ្នា ។ ថ្ងៃមួយនៅពេលខ្ញុំបានមើលនាងធ្វើវា ខ្ញុំបានគិតអំពីរបៀបដែលខ្សែពួរមួយត្រូវបានបង្កើតឡើង ដោយការវេញត្របាញ់នៃខ្សែតូចឆ្មាៗជាច្រើនចូលគ្នា ។ ការណ៍នេះបានជួយខ្ញុំឲ្យគិតដល់ការយល់ដឹងថ្មីរបស់ខ្ញុំអំពីសេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីសប្បុរសថាជាខ្សែតូចឆ្មាៗដែលវេញត្រាបាញ់ជាមួយគ្នា ដើម្បីបង្កើតបានជាខ្សែពួរដ៏មាំមួយ ។

**នៅពេលយើងវេញភ្ជាប់សេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីសប្បុរសចូលទៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង នោះយើងប្រែក្លាយជាអ្នកដើរតាមដ៏ពិតរបស់ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ។**

### សេចក្តីជំនឿ ៖ « អ្នករាល់គ្នានឹងមានអំណាច »

សេចក្តីជំនឿលើព្រះវរបិតាសួគ៌ និង ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺមិនមែនគ្រាន់តែជាការចាប់ផ្តើមដំបូងដើម្បីទទួលបានជីវិតអស់កល្បជានិច្ចនោះឡើយ ប៉ុន្តែថែមទាំងជាការចាប់ផ្តើមជីវិតរបស់យើងនៅលើផែនដីនេះផងដែរ ។ « ហើយព្រះគ្រីស្ទទ្រង់មានព្រះបន្ទូលថា ៖ បើសិនជាអ្នករាល់គ្នាមានសេចក្តីជំនឿជឿដល់យើង នោះអ្នករាល់គ្នានឹងមានអំណាច ប្រយោជន៍នឹងធ្វើនូវអ្វីៗដែលជាការចាំបាច់ដល់យើង » ( ម៉ូរ៉ូណៃ ៧:៣៣ ) ។ ខ្ញុំបានអនុវត្តអំណាចនេះតាមរយៈសេចក្តីជំនឿជាច្រើនដងនៅក្នុងជីវិតរបស់ខ្ញុំ ។ ហើយខ្ញុំបានពឹងផ្អែកលើសេចក្តីជំនឿ ដើម្បីនាំខ្ញុំឆ្លងកាត់គ្រាដ៏លំបាកលំបិនជាច្រើន ។

រូបថតមកពី ISTOCK/THINKSTOCK



កាលកំពុងរៀននៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់–ហាវ៉ៃ ខ្ញុំបានស្ថិតនៅក្នុងបរិយាកាសមួយថ្មីស្រឡាង ហើយភាសាអង់គ្លេសមិនមែនជាភាសាកំណើតរបស់ខ្ញុំឡើយ ។ វាជាឧបសគ្គណាស់ ហើយខ្ញុំបានដឹងថាខ្ញុំត្រូវការជំនួយពីការសិក្សា ទើបខ្ញុំអាចទទួលបានអាហារូបករណ៍សិក្សាបន្តទៀត ។ បើគ្មានអាហារូបករណ៍នេះទេ ខ្ញុំនឹងមិនអាចស្នាក់នៅក្នុងសាលាបានទៀតឡើយ ។ លើសពីនេះទៅទៀត ខ្ញុំបានតាំងចិត្តថា ខ្ញុំនឹងមិនសិក្សានៅថ្ងៃអាទិត្យឡើយ ។

នាថ្ងៃមួយ ពេលខ្ញុំកំពុងអានគោលលទ្ធិ និងសេចក្ដីសញ្ញា មានខគម្ពីរពិសេសមួយបានទាក់ចិត្តខ្ញុំយ៉ាងខ្លាំង ។ នៅពេលខ្ញុំអាននៅក្នុងកណ្ឌទី ១០៩ ខទី ៧ ខ្ញុំបានជួបនឹងឃ្លាមួយ ៖ « ចូរស្វែងរកការរៀនគឺដោយការសិក្សា និងដោយសេចក្ដីជំនឿផង » ។ ខគម្ពីរនោះបានប្រែជាគន្លឹះសំខាន់ចំពោះភាពជោគជ័យនៃការសិក្សារបស់ខ្ញុំ ។ ដោយសេចក្ដីជំនឿ និង ការសិក្សាដោយឧស្សាហ៍ព្យាយាមរយៈពេលប្រាំមួយថ្ងៃក្នុងសប្ដាហ៍ នោះខ្ញុំមានពរនៅក្នុងការសិក្សារបស់ខ្ញុំ ។ មិត្តភក្ដិមួយចំនួននៅក្នុងថ្នាក់របស់ខ្ញុំបានឆ្ងល់ពីរបៀបដែលខ្ញុំបានរៀនពូកែ ដោយមិនចាំបាច់សិក្សានៅថ្ងៃអាទិត្យ ដូចពួកគេបានធ្វើ ។ អ្វីដែលខ្ញុំបានរៀននោះគឺថា ការរៀនដោយការសិក្សា និងដោយសេចក្ដីជំនឿ អាចយកឈ្នះលើឧបសគ្គជាច្រើន ។

មានបទពិសោធន៍ស្រដៀងគ្នានេះបានកើតឡើងនៅពេលខ្ញុំកំពុងអភិវឌ្ឍអាជីពរបស់ខ្ញុំនៅក្នុងផ្នែកជំនួញ ។ មានឱកាសការងារដ៏ល្អបំផុតមួយបានផ្ដល់ដល់ខ្ញុំ ប៉ុន្តែការងារនោះទំនងដូចជាតម្រូវឲ្យខ្ញុំធ្វើការនៅថ្ងៃអាទិត្យ ។ ខ្ញុំបានតាំងចិត្តមិនធ្វើការនៅថ្ងៃឈប់សម្រាកទេ ។ ទីបំផុត ខ្ញុំបានបដិសេធការផ្ដល់ឲ្យនោះ ។ ខ្ញុំពុំអាចបង្ខូចការតាំងចិត្តរបស់ខ្ញុំ ក្នុងការរក្សាថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធឡើយ ។ ដូចជាការតាំងចិត្តដែលខ្ញុំបានធ្វើនៅមហាវិទ្យាល័យដែរ ក្រោយមកនោះខ្ញុំបានទទួលពរឲ្យជួបឱកាសដទៃទៀតជាច្រើនក្នុងជំនួញ ដែលមិនតម្រូវឲ្យខ្ញុំបង្ខូចការតាំងចិត្តរបស់ខ្ញុំ ហើយដែលអនុញ្ញាតឲ្យខ្ញុំ ទុកថ្ងៃអាទិត្យដើម្បីថ្វាយបង្គំព្រះអម្ចាស់ ។

នៅពេលយើងបង្កើតខ្សែពួរដ៏មាំរបស់យើង ដែលចង់ភ្ជាប់យើងទៅនឹងពរជ័យមកពីព្រះ ចូរយើងចាប់ផ្ដើមជាមួយនឹងខ្សែតូចឆ្មារនៃសេចក្ដីជំនឿ ។

**សេចក្ដីសង្ឃឹម ៖ « ដើម្បីឲ្យបានប្រោសឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ច »**

យើងសង្ឃឹមចង់បានអ្វីៗជាច្រើន ៖ ថាយើងអាចបានរីកចម្រើនឈានមុខនៅក្នុងអាជីពរបស់យើង ថាកូនចៅរបស់យើងនឹងបានសមប្រកប ថាយើងនឹងបំពេញតាមការរំពឹងទុកចំពោះការបម្រើក្នុងសាសនាចក្ររបស់យើង ថាយើងនឹងបន្តមានសុខភាពល្អ ថាយើងនឹងមាននូវអ្វីៗដែលយើងត្រូវការដើម្បីទ្រទ្រង់ជីវិត និង ផ្គត់ផ្គង់ដល់គ្រួសាររបស់យើង ។ ប៉ុន្តែ តើសេចក្ដីសង្ឃឹមដ៏ខ្ពស់បំផុតនោះកើតឡើងមកពីណា ហើយតើវាអាចនាំយើងពីត្រង់ចំណុចណាទៅ ?



មរមនបានមានប្រសាសន៍ថា « ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នា ដែលនៅក្នុងសាសនាចក្រនេះ ដែលជាអ្នកដើរតាមព្រះគ្រីស្ទដោយសុខសាន្ត ហើយដែលបានទទួលសេចក្ដីសង្ឃឹមគ្រប់គ្រាន់ ដែលធ្វើឲ្យអ្នករាល់គ្នាអាចបានចូលទៅក្នុងសេចក្ដីសម្រាកនៃព្រះអម្ចាស់ » ( ម៉ូរ៉ូណៃ ៧:៣ ) ។

នៅពេលមរមនបន្តការអញ្ជើញរបស់លោក ឲ្យពួកយើងក្លាយជាអ្នកដើរតាមដ៏ពិតនៃព្រះគ្រីស្ទ នោះលោកបានត្រឡប់ទៅនិយាយម្ដងទៀតអំពីប្រធានបទនៃសេចក្ដីសង្ឃឹម នៅពេលលោកសួរថា « ហើយតើអ្វីទៅដែលអ្នករាល់គ្នាសង្ឃឹមចង់បាន ? » ក្រោយមកលោកឆ្លើយសំណួរដ៏សំខាន់នេះ ៖ « មើលចុះខ្ញុំសូមប្រាប់អ្នកថា អ្នករាល់គ្នានឹងមានសេចក្ដីសង្ឃឹម តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ និង អំណាចនៃដំណើររស់ឡើងវិញរបស់ទ្រង់ ដើម្បីឲ្យបានប្រោសឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយនេះក៏មកពីសេចក្ដីជំនឿអ្នកដល់ទ្រង់ ស្របតាមពាក្យសន្យា » ( ម៉ូរ៉ូណៃ ៧:៤១ ) ។

សេចក្ដីសង្ឃឹមបែបនេះគឺវាខុសពីសេចក្ដីសង្ឃឹមធម្មតា ។ សេចក្ដីសង្ឃឹមមកពីព្រះនេះនឹងកើតមានឡើង តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ វាគឺជាសេចក្ដីសង្ឃឹមដ៏អស់កល្បជានិច្ច ។ ប្រសិនបើគ្មានសេចក្ដីសង្ឃឹមបែបនេះទេ យើងនឹងមកព្រះវិហាររាល់សប្ដាហ៍ដោយពុំដឹងថា ពរជ័យដ៏អស្ចារ្យទាំងនេះគឺនៅក្នុងរង្វង់ដៃរបស់យើងឡើយ ។ តាមរយៈព្រះគ្រីស្ទ សេចក្ដីសង្ឃឹមរបស់យើង អាចនាំយើងត្រឡប់ទៅព្រះវរបិតាសួគ៌ និង ជីវិតដ៏នៅអស់កល្បជានិច្ច ។

នៅក្នុងសុន្ទរកថានៃសន្និសីទទូទៅថ្មីៗនេះ ប្រធានហិនរី ប៊ី អាយរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយបានថ្លែងថា « [ ព្រះវរបិតា ] អនុញ្ញាតឲ្យបុត្រាទ្រង់ប្រទានក្ដីសង្ឃឹមលួងលោមយើង តាមរយៈ

រូបថត © DJORJE_STOJILJKOVIC និង URFINGUSS/THINKSTOCK

ពលិកម្មធួន មិនថាការគ្រឡប់ទៅទ្រង់វិញលំបាកយ៉ាងណាឡើយ » ។[១] តាមរយៈសេចក្តីសង្ឃឹមយើងអាចមើលឃើញពរជ័យ និង ឱកាសនានាដែលរង់ចាំយើង នៅពេលយើងបន្តស្មោះត្រង់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយបម្រើទ្រង់ដោយអស់ពីដួងចិត្ត ពលំ គំនិត និងកម្លាំងរបស់យើងផងដែរ ។

ជាមួយនឹងការយល់ដឹងនោះ ចូរបន្ថែមនូវខ្សែតូចឆ្មាៗបន្ទាប់ទៅនឹងខ្សែពួររបស់យើងទៀត គឺជាសេចក្តីសង្ឃឹម ។



**សេចក្តីសប្បុរស ៖ ប្រទានដល់អ្នកដើរតាមដ៏ពិត**

គុណធម៌ទីបីដើម្បីពង្រឹងខ្សែពួររបស់យើងថែមទៀតនោះគឺសេចក្តីសប្បុរស ។ យើងចាប់ផ្តើមអភិវឌ្ឍអំណោយទាននៃសេចក្តីសប្បុរស តាមរយៈការខំខ្នះខ្នែងដោយស្មោះសររបស់យើង ដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ។ ប៉ុន្តែ ភាពពោរពេញនៃអំណោយទាននេះត្រូវបានប្រទានដល់ពួកយើងតាមរយៈព្រះ នៅពេលយើងព្យាយាមស្វែងរកអំណោយទាននេះក្នុងការអធិស្ឋាន ។ នៅពេលយើងធ្វើតាមទ្រង់ ដែលជាអង្គដែលប្រទានជីវិតដល់ពួកយើង នោះយើងចាប់ផ្តើមរៀនពីអត្ថន័យពិតនៃសេចក្តីសប្បុរស ដែលវាជា « សេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ » ( ម៉ូរ៉ូណៃ ៧:៤៧ ) ។

នៅពេលមរមនបង្រៀន ៖ « ចូរអធិស្ឋានដល់ព្រះវរបិតា ដោយអស់ពីកម្លាំងចិត្ត ដើម្បីឲ្យអ្នករាល់គ្នាបានពោរពេញដោយសេចក្តីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អស់អ្នកណា ដែលជាអ្នកដើរតាមដ៏ពិតនៃព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាអាចក្លាយទៅជាកូនព្រះ » ( ម៉ូរ៉ូណៃ ៧:៤៨ ) ។ ក្នុងនាមជាអ្នកដើរតាម *ដោយសុខសាន្ត* នោះយើងអាចទទួលបានសេចក្តីសង្ឃឹមគ្រប់គ្រាន់ ប៉ុន្តែដើម្បីត្រូវបានប្រទានឲ្យនូវសេចក្តីសប្បុរស នោះយើងត្រូវក្លាយជាអ្នកដើរតាមដ៏ *ពិត* ។ ប្រសិនបើយើងជាអ្នកដើរតាមដ៏ *ពិត* នោះយើងនឹងប្រែកាន់តែដូចទ្រង់ដែលនោះគឺជាគោលបំណងនៃជីវិតនេះ ។

តាមរយៈការបណ្តុះនៅក្នុងចិត្តរបស់យើងនូវសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ នោះយើងកាន់តែអភិវឌ្ឍបុគ្គលិកលក្ខណៈនៃសេចក្តីសប្បុរសដូចជាព្រះ—ដើម្បីបម្រើទាំងបងប្អូន និង ព្រះរបស់យើង ។ « បើសិនជាមនុស្សនោះស្លូតបូត ហើយសុភាពរាបសា ហើយទទួលស្គាល់ដោយនូវព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ អ្នកនោះត្រូវតែមានសេចក្តីសប្បុរស ដ្បិតបើសិនជាគេគ្មានសេចក្តីសប្បុរសទេ អ្នកនោះគ្មានជាអ្វីទាំងអស់ ហេតុដូច្នោះហើយ អ្នកនោះត្រូវតែមានសេចក្តីសប្បុរស » ( ម៉ូរ៉ូណៃ ៧:៤៤ ) ។

ឥឡូវនេះយើងមានខ្សែតូចឆ្មាៗចាំបាច់ចំនួនបីនៅក្នុងខ្សែពួររបស់យើង ។ ចូរមើលពីរបៀបវាធ្វើការរួមគ្នា ។

**គុណធម៌ទាំងបីនេះធ្វើការរួមគ្នា**

« ហេតុដូច្នោះហើយ ត្រូវតែមានសេចក្តីជំនឿ ហើយបើសិនជាមានសេចក្តីជំនឿ នោះត្រូវតែមានសេចក្តីសង្ឃឹមផង ហើយបើសិនជាមានសេចក្តីសង្ឃឹម នោះត្រូវតែមានសេចក្តីសប្បុរសផងដែរ ។

ហើយលើកលែងអ្នករាល់គ្នាមានសេចក្តីសប្បុរសបើពុំនោះសោតទេ អ្នករាល់គ្នានឹងពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះឡើយ ហើយអ្នករាល់គ្នាក៏ពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នករាល់គ្នាគ្មានសេចក្តីជំនឿ ហើយអ្នកក៏ពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នកគ្មានសេចក្តីសង្ឃឹម » ( ម៉ូរ៉ូណៃ ១០:២០–២១ ) ។

នៅពេលសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរសរួមបញ្ចូលគ្នា វាលែងជាដុំឥដ្ឋតម្រៀបតលើគ្នាដូចខ្ញុំយល់កាលពីមុនទៀតហើយ ផ្ទុយទៅវិញ វាមានទំនាក់ទំនងជាមួយគ្នាយ៉ាងស្អិតរមួត ។ យើងមិនបញ្ឈប់ការស្ថាបនាសេចក្តីជំនឿ ហើយបន្ទាប់មកទើបមានសេចក្តីសង្ឃឹម ឬ បន្ទាប់ពីមានសង្ឃឹម ហើយជាចុងក្រោយអភិវឌ្ឍសេចក្តីសប្បុរសនោះទេ ។ គុណធម៌ទាំងបីនេះធ្វើការរួមគ្នា ។ ហើយនៅពេលវាវេញគ្របាញ់បញ្ចូលគ្នា នោះគុណធម៌ទាំងអស់នេះជួយបង្កើតបុគ្គលិកលក្ខណៈ និង ទីបន្ទាល់របស់យើង ។ ■

កំណត់ចំណាំ

១. ហិនរី បី. អាវរីង « The Comforter » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ២០ ។

# ការបង្កើតឲ្យមានជីវិតដ៏រីករាយដែលគ្មានទីបញ្ចប់

**ដោយ យូរី ខូតេពូវ**

ខ្ញុំបានក្លាយជាសមាជិកសាសនាចក្រ អស់រយៈពេល ១០ ឆ្នាំហើយកាលខ្ញុំបានទទួលការបញ្ជាក់ថា ខ្ញុំត្រូវតែចាប់ផ្ដើមរកមើលដៃគូ ។ ខ្ញុំបានយល់ពីគោលលទ្ធិនៃអាពាហ៍ពិពាហ៍សេឡេស្ទាល ហើយខ្ញុំបានអធិស្ឋានដោយស្មោះត្រង់ដើម្បីមានអាពាហ៍ពិពាហ៍បែបនោះ និង អាចមានគ្រួសារមួយ ។ ខ្ញុំមិនដឹងថា តើខ្ញុំអាចស្វែងរកស្ត្រីពួកបរិសុទ្ធថ្ងៃចុងក្រោយនៅក្នុងទីក្រុង សាម៉ារ៉ា ប្រទេសរុស្ស៊ី ជាកន្លែងដែលខ្ញុំរស់នៅដោយរបៀបណាឡើយ ប៉ុន្តែខ្ញុំបានទុកចិត្តថាព្រះអម្ចាស់នឹងជួយខ្ញុំ ( សូមមើល នីហ្វៃទី ១ ៣:៧ ) ។

កាលពីឆ្នាំ ២០០៩ ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសន្និសីទយុវមជ្ឈិមវ័យជាបន្តបន្ទាប់ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងទីក្រុង ១០ ទូទាំងបេសកកម្ម សាម៉ារ៉ារុស្ស៊ី ។ ខ្ញុំរំពឹងទុកថា សកម្មភាពទាំងនេះអាចជាមធ្យោបាយដែលខ្ញុំអាចជួបដៃគូអស់កល្បជានិច្ចរបស់ខ្ញុំ ។

ខ្ញុំមានចិត្តរីករាយចូលរួមសន្និសីទទាំងនោះ ការអធិស្ឋានបានឆ្លើយតបតាមរបៀបជាច្រើន ប៉ុន្តែអស់ពេលជាច្រើនខែហើយ ខ្ញុំនៅតែគ្មានការរីកចម្រើនអ្វីសោះក្នុងទំនាក់ទំនងការដើរលេងជាគូ ។

ខ្ញុំបានចាប់ផ្ដើមបារម្ភ ហើយបានទូលសូមព្រះអម្ចាស់ឲ្យជួយខ្ញុំ ។ ជាចម្លើយ គំនិតនានាបានផុសឡើងក្នុងគំនិតខ្ញុំ ដោយព្រមានខ្ញុំថា ខ្ញុំអាចត្រូវបានល្បួងឲ្យមានទំនាក់ទំនងជាមួយអ្នកដែលមិនមែនជាសមាជិកសាសនាចក្រ ។

ខ្ញុំបានដឹងថាព្យាការី បានបង្រៀនថា យើងគប្បីព្យាយាមរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយខ្ញុំបានដឹងថា វាមិនអាចមានសេចក្ដីរីករាយដ៏ពេញលេញឡើយ ប្រសិនបើភរិយារបស់ខ្ញុំ និង ខ្ញុំពុំបានរួមសាមគ្គីគ្នានៅក្នុងការព្យាយាមធ្វើតាមព្រះអង្គសង្គ្រោះ ។ ខ្ញុំបានបន្តអធិស្ឋានឲ្យទទួលបានកម្លាំងខាងវិញ្ញាណដើម្បីទប់ទល់នឹងការល្បួងបែបនោះ ហើយមានជំនួយពីព្រះអម្ចាស់ក្នុងការធ្វើតាមផែនការដែលទ្រង់មានសម្រាប់ខ្ញុំ ។

នៅក្នុងអំឡុងពេលនោះ ខ្ញុំបានចាប់ផ្ដើមរៀបចំខ្លួនរបស់ខ្ញុំ សម្រាប់ការធ្វើដំណើរជាទៀងទាត់ទៅព្រះវិហារបរិសុទ្ធ ហេលស៊ីនគី ហ្វាំងឡង់ ជាកន្លែងដែលខ្ញុំនឹងសម្រាកនៅទីនោះមួយសប្ដាហ៍ ។

នៅពេលធ្វើដំណើរតាមរថភ្លើង ខ្ញុំបានជួបនឹងអ្នកដំណើរបីនាក់ផ្សេងទៀត រួមទាំងស្ត្រីម្នាក់ឈ្មោះ ម៉ារីយ៉ា ដែលខ្ញុំបានដឹងថានាងនៅលីវ ។ នាងមានភាពទាក់ទាញចំពោះខ្ញុំទាំងខាងរូបសម្ផស្ស និង ខាងវិញ្ញាណ ហើយខ្ញុំឆ្ងល់ពីមូលហេតុដែលខ្ញុំពុំធ្លាប់បានជួបមនុស្សស្រីណាម្នាក់ដូចនាងកាលពីមុនឡើយ ។

> **ខ្ញុំបានអធិស្ឋានដើម្បីជួបនឹងដៃគូអស់កល្បជានិច្ចរបស់ខ្ញុំ ប៉ុន្តែខ្ញុំពុំរំពឹងថាជួបនាងអង្គុយក្បែរខ្ញុំ នៅលើរថភ្លើងដើម្បីទៅព្រះវិហារបរិសុទ្ធឡើយ !**

ខ្ញុំបានគិតពីការព្រមានពីមុនដែលមានចំពោះខ្ញុំ អំពីការល្បួងដែលខ្ញុំនឹងអាចមានទំនាក់ទំនងជាមួយអ្នកដែលមិនមែនជាសមាជិកសាសនាចក្រ ។

ខ្ញុំបានគិតថា « ចូររឹងប៉ឹងឡើង » ។ « ចូរស្មោះត្រង់ចំពោះគោលការណ៍របស់អ្នក ។ អ្នកនឹងជួបបងប្អូនស្រីដែលសក្ដិសម និង អស្ចារ្យនៅក្នុងសាសនាចក្រ ។

ដោយគិតថា យ៉ាងហោចណាស់ខ្ញុំអាចធ្វើជាសមាជិកល្អម្នាក់ដែលធ្វើកិច្ចការផ្សព្វផ្សាយសាសនា ហើយអាចចែកចាយដំណឹងល្អជាមួយនាង និង ត្រូវការការបំផុសគំនិត នោះខ្ញុំបានលូកយកព្រះគម្ពីរ

រចនារូបភាពដោយ យ៉ូស្វេ ដែននីស

មរមនមកអាន ដោយចាំមើលថា តើនាងនឹងចាប់អារម្មណ៍ដែរឬទេ ។ ខ្ញុំមានការភ្ញាក់ផ្អើល ពេលម៉ារីយ៉ាបាននិយាយថា « ខ្ញុំដឹងថាអ្នកកំពុងទៅណាហើយ ! »

ខ្ញុំបានងើយមើលទៅ ឃើញនាងកំពុងកាន់ព្រះគម្ពីរមរមនរបស់នាង ។ នាងជាសមាជិកនៃសាសនាចក្រ ហើយនាងក៏កំពុងធ្វើដំណើរទៅព្រះវិហារបរិសុទ្ធផងដែរ ។

នាព្រឹកស្អែកឡើង យើងបានបន្តដំណើររបស់យើងទៅទីក្រុងហែលសិនគី ដោយជិះឡានក្រុង ។ ខ្ញុំបានដឹងថា ម៉ារីយ៉ាមកពីទីក្រុង វ៉្យូនណេស្ស ជាទីក្រុងមួយនៅក្នុងបេសកកម្មរុស្ស៊ីភាគខាងលិចរុស្ស៊ី ។ ខ្ញុំចូលចិត្តនាងភ្លាម ហើយបានអធិស្ឋានដោយស្មោះសរសម្រាប់ការណែនាំ ។ ជាចម្លើយ ខ្ញុំបានមានអារម្មណ៍ល្អនៅក្នុងដួងចិត្តខ្ញុំ ។

ខ្ញុំបានអធិស្ឋានថា « ព្រះអម្ចាស់អើយ ពួកយើងមានពេលតែមួយសប្ដាហ៍ប៉ុណ្ណោះនៅព្រះវិហារបរិសុទ្ធ ។ សូមជួយពួកទូលបង្គំឲ្យស្គាល់គ្នាបានកាន់តែច្បាស់ឡើងនៅក្នុងអំឡុងពេលនេះ » ។

ហើយយើងពិតជាស្គាល់គ្នាបានច្បាស់មែន ។ នៅពេលសម្រាកពីការធ្វើពិធីនានានៅព្រះវិហារបរិសុទ្ធ យើងបានដើរកម្សាន្ត ចែកអាហារគ្នាបរិភោគ បានទៅហាងទំនិញ និង បាននិយាយគ្នាលេង ។ នៅចុងសប្ដាហ៍នោះ យើងទាំងពីរនាក់បានទៅផ្ទះវិញ—ម៉ារីយ៉ាទៅទីក្រុងវ៉្យូនណេស្ស ហើយខ្ញុំទៅទីក្រុងសាម៉ារ៉ា ។ ប៉ុន្តែយើងបានធ្វើដំណើរទៅទីក្រុងរបស់គ្នាទៅវិញទៅមក ដើម្បីស្គាល់គ្នាបានកាន់តែច្បាស់ ហើយនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ នោះយើងបានរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ឃីវ អ៊ុយក្រែន ដែលទើបតែបានឧទ្ទិសឆ្លង ។

ឥឡូវនេះម៉ារីយ៉ា និង ខ្ញុំរស់នៅក្នុងទីក្រុងវ៉្យូនណេស្ស ហើយមានភាពរីករាយ ។ យើងយល់ថាវាជារឿងនិទានរបស់កូនក្មេងមួយដែលបញ្ចប់ដោយឃ្លាថា « ហើយពួកគេបានរស់នៅយ៉ាងរីករាយជារៀងតទៅ » ។ នៅក្នុងជីវិតពិត យើងបង្កើតជីវិតដ៏រីករាយដែលគ្មានទីបញ្ចប់របស់យើងផ្ទាល់ តាមរយៈការបន្តផ្តល់នូវភាពស្មោះត្រង់របស់យើងចំពោះព្រះអម្ចាស់ ដោយការគោរពសេចក្ដីសញ្ញាក្នុងព្រះវិហារបរិសុទ្ធរបស់យើង ដោយបន្តធ្វើការពង្រឹងអាពាហ៍ពិពាហ៍របស់យើង ហើយព្យាយាមដើម្បីក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ។

យើងមានអំណរគុណចំពោះការជួបជុំគ្នារបស់យើង និង សេចក្ដីសង្ឃឹមដ៏មានអព្ភូតហេតុ ថារឿងរបស់យើងនឹងនាំសេចក្ដីសង្ឃឹម និង ផ្ដល់កម្លាំងដល់មនុស្សដទៃ ដែលកំពុងស្វែងរកដៃគូរស់កល្បជានិច្ចរបស់ពួកគេ ។ រឿងរបស់អ្នកដទៃផ្សេងៗទៀតអាចពុំកើតឡើងដូចជារឿងរបស់យើងនោះទេ ប៉ុន្តែម៉ារីយ៉ា និង រូបខ្ញុំដឹងថា ទោះបីជាមានឧបសគ្គយ៉ាងណាក្ដី ព្រះអម្ចាស់ស្ដាប់ការអធិស្ឋានដ៏ស្មោះសររបស់យើង ។ ទ្រង់ស្រឡាញ់យើងគ្រប់គ្នា ហើយមានព្រះទ័យខ្វល់ខ្វាយចំពោះយើងម្នាក់ៗ ។ ប្រសិនបើយើងអនុញ្ញាតដល់ទ្រង់ នោះទ្រង់នឹងដឹកនាំផ្លូវរបស់យើង ហើយចូរឲ្យគ្រប់ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្ដីល្អដល់អ្នក ( សូមមើល គ. និង ស. ៩០:២៤ ) ។ ■

*អ្នកនិពន្ធរស់នៅ វ៉្យូនណេស្ស ប្រទេសរុស្ស៊ី ។*





**ផែនទីរបស់ព្រះទៅរកសុភមង្គល**

« យើងទាំងអស់គ្នាស្វែងរកសុភមង្គល ហើយយើងទាំងអស់គ្នាព្យាយាមស្វែងរក ‹ ភាពរីករាយជារៀងរហូតតទៅ › ផ្ទាល់ខ្លួនរបស់យើង ។ ការពិតនោះគឺថា ព្រះដឹងពីរបៀបដើម្បីទៅដល់ទីនោះ ! ហើយទ្រង់បានបង្កើតផែនទីសម្រាប់អ្នក ទ្រង់ស្គាល់ផ្លូវនោះ ។ ទ្រង់គឺជាព្រះវបិតាសួគ៌ដែលពេញដោយក្ដីស្រឡាញ់របស់អ្នក ដែលស្វែងរកសេចក្ដីល្អ សុភមង្គលរបស់អ្នក ។ ទ្រង់មានព្រះទ័យនៃសេចក្ដីស្រឡាញ់ទាំងអស់របស់ព្រះវរបិតាដ៏ល្អឥតខ្ចោះ និង បរិសុទ្ធ ដែលអ្នកឈានដល់គោលដៅដ៏ខ្ពស់បំផុតរបស់អ្នក ។ ផែនទីនេះគឺមានសម្រាប់មនុស្សទាំងអស់គ្នា » ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានទីមួយ « **Your Happily Ever After** » *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ១២៦–១២៧ ។



រចនារូបភាព ដោយ អ័រដាម ហៅលីង

# ភាពរឹងមាំដើម្បីជ្រើសរើស

ដោយ ម៉ែខល ភីកខែត

ខ្ញុំមានក្តីរំភើប នៅពេលបុរសម្នាក់បានទូរសព្ទមកខ្ញុំនាថ្ងៃមួយ ហើយនិយាយថា គាត់បានឃើញកម្មវិធីកាយវប្បកម្មរបស់ខ្ញុំ ហើយគាត់ចង់ឧបត្ថម្ភដល់ខ្ញុំ ។ គាត់នឹងបង់ថ្លៃសម្លៀកបំពាក់ និង អាហារប្រូតេអ៊ីន និង ថ្លៃសំបុត្រយន្តហោះទៅទីបអើរ៉ុបដើម្បីធ្វើកម្មវិធីបង្ហាញនៅទីនោះ ។ គាត់ថែមទាំងបាននិយាយថា ខ្ញុំនឹងអាចត្រូវបានបង្ហាញមុខនៅក្នុងទស្សនាវដ្តី ។ កាយវប្បកម្មគឺជាចំណង់ចំណូលចិត្ត ហើយវាគឺជាក្តីសុបិនរបស់ខ្ញុំ ! បញ្ហាតែមួយគត់នោះគឺថា ខ្ញុំបានផ្ញើទម្រង់បែបបទបេសកកម្មរបស់ខ្ញុំកាលពីពីរបីថ្ងៃមុន ។ ខ្ញុំបានប្រាប់បុរសនោះវិញថា ខ្ញុំនឹងគិតអំពីការផ្តល់ជូនរបស់គាត់ ហើយនឹងទូរសព្ទប្រាប់គាត់នៅពេលក្រោយ ។

ខ្ញុំបានប្រឈមនឹងការសម្រេចចិត្តដ៏លំបាកបំផុតនៅក្នុងជីវិតខ្ញុំ ។ ចំពោះឪពុកម្តាយខ្ញុំ ការទទួលយកអ្នកឧបត្ថម្ភគឺជារឿងដែលមិនត្រូវទទួលយកឡើយ ។ ពួកគាត់បាននិយាយថា « ប្រហែលជាកូននឹងមានឱកាសនេះបន្ទាប់កូនចប់បេសកកម្ម » ។ ប៉ុន្តែខ្ញុំមិនអាចឈប់គិតពីវាឡើយ ។ ខ្ញុំដឹងថា ខ្ញុំគប្បីទៅបម្រើបេសកកម្ម ហើយបម្រើព្រះអម្ចាស់ ប៉ុន្តែក្តីសុបិនរបស់ខ្ញុំកំពុងនៅនឹងមុខរបស់ខ្ញុំហើយ ។

*តើត្រូវបម្រើបេសកកម្ម ឬ ក្លាយជាកីឡាករកាយវប្បកម្មអាជីព ? ខគម្ពីរមួយ និង ការដកស្រង់ដែលមិត្តភក្តិរបស់ខ្ញុំបានចែកចាយវាជាមួយខ្ញុំបានជួយខ្ញុំធ្វើការសម្រេចចិត្ត ។*

ខ្ញុំបានសួរមិត្តភក្តិរបស់ខ្ញុំជាច្រើន នូវអ្វីដែលពួកគេគិតថាតើខ្ញុំគួរធ្វើដូចម្តេច ។ មានអ្នកខ្លះបាននិយាយថា ខ្ញុំគួរតែទទួលយកអ្នកឧបត្ថម្ភនោះ ហើយអ្នកខ្លះទៀតបាននិយាយថា វាគឺជាកិច្ចការរបស់សាតាំងប្រឆាំងនឹងរូបខ្ញុំ ដោយសារវាមិនចង់ឲ្យខ្ញុំទៅបម្រើបេសកកម្មឡើយ ។

ថ្ងៃមួយ មិត្តភក្តិដ៏អស្ចារ្យរបស់ខ្ញុំម្នាក់បានចែកចាយការដកស្រង់មួយមកពីប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ឆ្នាំ ១៨៩៩–១៩៩៤ ) ជាមួយខ្ញុំដូចនេះ ៖ « បុរស និង ស្ត្រីដែលបង្វែរជីវិតខ្លួនមករកព្រះនឹងរកឃើញថា ទ្រង់អាចធ្វើឲ្យជីវិតរបស់ពួកគេបានប្រសើរជាង ។ ទ្រង់នឹងធ្វើឲ្យសេចក្តីអំណរចាក់ចូលយ៉ាងជ្រៅក្នុងចិត្តពួកគេ ពង្រីកទស្សនវិស័យរបស់ពួកគេ ពន្លឿនគំនិតពួកគេ *ពង្រឹងកម្លាំងពួកគេ* លើកវិញ្ញាណពួកគេឡើង ចម្រើនពរជ័យពួកគេ បង្កើនឱកាសពួកគេ លួងលោមព្រលឹងពួកគេ បង្កើតមិត្តភាព ហើយចាក់ស្រោចនូវសេចក្តីសុខសាន្ត » ។[1]

ការដកស្រង់នេះបានទាក់ចិត្តខ្ញុំយ៉ាងខ្លាំង ។ ដូចជាខគម្ពីរមួយដែលខ្ញុំបានអាននៅក្នុងព្រះគម្ពីរមរមនថា ៖ « ហើយបើសិនជាកូនចៅមនុស្សកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទ្រង់នឹងចិញ្ចឹមគេ ហើយផ្តល់កម្លាំងដល់គេ ព្រមទាំងផ្តល់ផ្លូវឲ្យ ដើម្បីគេអាចសម្រេចនូវអ្វីដែលទ្រង់ បានបញ្ជាពួកគេ » ( នីហ្វៃទី ១ ១៧:៣ ) ។

ដោយមានជំនួយមកពីការដកស្រង់ និង ខគម្ពីរនេះ ព្រមទាំងការគាំទ្រពីមិត្តភក្តិ និង គ្រួសាររបស់ខ្ញុំ នោះខ្ញុំបានសម្រេចចិត្តបម្រើបេសកកម្ម ហើយខ្ញុំត្រូវបានហៅឲ្យបម្រើនៅក្នុងបេសកកម្មបូលីវី កូឆាបាមបា ។ ការបម្រើបេសកកម្មគឺជាជម្រើសដ៏ល្អបំផុតដែលខ្ញុំបានរើសយក ។ ខ្ញុំបានឃើញពរជ័យជាច្រើន ខណៈកំពុងបម្រើ រួមទាំងពរជ័យដែលបានរៀនភាសាអេស្ប៉ាញឆាប់ចេះ ។

ព្រះអម្ចាស់បានប្រទានពរដល់គ្រួសារខ្ញុំផងដែរ ។ អំឡុងពេលក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានទទួលអ៊ីម៉ែលមួយពីឪពុកម្តាយរបស់ខ្ញុំ ដោយប្រាប់ខ្ញុំថា បងប្រុសរបស់ខ្ញុំបានទៅព្រះវិហារវិញជាលើកទីមួយក្រោយពីអសកម្មអស់ ១២ ឆ្នាំ ។ ក្រោយមកគាត់បានប្តូរកាលវិភាគធ្វើការរបស់គាត់ ប្រយោជន៍ឲ្យគាត់អាចទៅព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ ហើយគាត់ដាក់គោលដៅមួយអានព្រះគម្ពីរមរមន ។ ហើយប្អូនប្រុសរបស់ខ្ញុំក៏បានពុះពារធ្វើការផ្លាស់ប្តូរមួយចំនួននៅក្នុងជីវិតរបស់គាត់ ហើយពង្រឹងសេចក្តីជំនឿរបស់គាត់ផងដែរ ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានត្រឡប់មកជាសកម្មវិញ ហើយចាប់ផ្តើមទៅព្រះវិហារបរិសុទ្ធរៀងរាល់សប្តាហ៍ ដើម្បីធ្វើបុណ្យជ្រមុជទឹកដល់មរណជន ។ យើងពិតជាបានទទួលពរ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*

កំណត់ចំណាំ

១. *Teachings of Presidents of the Church: Ezra Taft Benson* ( ឆ្នាំ ២០១៤ ) ទំព័រ ៤២–៤៣ ការគូសបញ្ជាក់បានបន្ថែម ។





# ចូរធ្វើជាវីរបុរសដ៏ ***ពិត***

**ដោយ ឆាឡុត ឡាកាបាល**
ទស្សនាវដ្ដីសាសនាចក្រ

សូមគិតអំពីទង្វើរបស់វីរបុរសដែលអ្នកចូលចិត្ត ។ ឥឡូវនេះ ! តើអ្នកបានគិតអំពីការផ្សងព្រេងរបស់វីរបុរសមួយចំនួនដែលព្យាយាមយកឈ្នះលើការជំទាស់ដ៏ខ្លាំងលើសលុបដែរឬទេ ? ឬ ប្រហែលជាគិតពីអ្នកផ្សងព្រេងដ៏មានមន្តស្នេហ៍ដែលមានម៉ូដសក់ដ៏ស្រស់ស្អាតដែរឬទេ ? តើអ្នកបានគិតអំពីនរណាម្នាក់មកពីបទគម្ពីរឬទេ ?

នីហ្វៃ, ណូអេ, អ័ប៊ីស ឬ ពេត្រុស ? ពួកលោកមិនគ្រាន់តែវាយប្រឆាំងនឹងសត្រូវរបស់ខ្លួនដោយកណ្ដាប់ដៃ និង ដោយពាក្យសម្ដីដ៏ឈ្លាសវៃនោះទេ ប៉ុន្តែពួកគាត់គឺមនុស្សដែលអ្នកអាចហៅបានថាជាវីរបុរសដ៏ *ពិត* ។ ពួកលោកអនុវត្តសេចក្ដីជំនឿ ទុកចិត្តលើព្រះ និង ឈានទៅមុខ ។ ពួកលោកមានការប្រព្រឹត្ត ។

តើអ្នកធ្លាប់ពុំបានចាប់ផ្ដើមធ្វើកិច្ចការ ដោយសារអ្នកពុំបានទទួលការណែនាំច្បាស់លាស់ ពីមួយជំហានទៅមួយជំហានដែរឬទេ ? ប្រហែលជាមានអ្នកខ្លះនៅក្នុងថ្នាក់រៀន ឬ កូរ៉ុមរបស់អ្នក ដែលពុំមកព្រះវិហារ ។ តើអ្នកមានចិត្តស្ទាក់ស្ទើរទៅរកពួកគេ ដោយសារអ្នកពុំដឹងប្រាកដពីរបៀបធ្វើវាឬ ? ការបំផុសគំនិតគឺមានសារៈសំខាន់ ហើយយើងគប្បីស្វែងរក

រចនារូបភាពដោយ ដៃ ហារី ស៊ីម រូបថតតាមរយៈ ISTOCK/THINKSTOCK

***ការឈានទៅមុខគឺ មិនមែនដូចជាការអង្គុយមើលកីឡាឡើយ ។ ត្រូវក្រោកឡើង ហើយធ្វើសកម្មភាព ។***

ការបំផុសគំនិតជានិច្ច ។ ប៉ុន្តែនោះពុំមែនមានន័យថា អង្គុយហើយរង់ចាំសារលិខិតមកពីទេវតាមួយអង្គ ពីមុនយើងទៅចុះឡើងធ្វើការល្អឡើយ ។ ព្រះវរបិតាសួគ៌មានព្រះទ័យឲ្យអ្នកធ្វើជាមិត្តជាមួយនឹងបុគ្គលម្នាក់នោះ ។ ទ្រង់មានព្រះទ័យឲ្យយើងមានចិត្តក្លាហាន ហើយប្រព្រឹត្តវា !

ចុះប្រសិនបើនីហ្វៃ, ណូអេ, អ័ប៊ីស ឬ ពេត្រុស បានរង់ចាំដោយមិនធ្វើអ្វីសោះនោះ ? ពួកលោកទាំងអស់គ្នា មានកិច្ចការលំបាកៗដែលត្រូវធ្វើ ។ ឧបមាថាពួកលោកបានជ្រើសយកការអង្គុយស្ងៀមផឹកភេសជ្ជៈ និង បរិភោគនំយុកឃី លុះត្រាពួកគេទទួលបានការណែនាំបន្តទៀតដើម្បីធ្វើកិច្ចការផ្សេងៗ ។ នោះអ្វីៗគ្រប់យ៉ាងនឹងមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង . . .

## រង់ចាំ ហើយមើលឬ ?

« *ខ្ញុំនឹង* រង់ចាំ *ហើយធ្វើនូវអ្វីៗដែលព្រះអម្ចាស់ទ្រង់បានបញ្ជា ដ្បិតខ្ញុំដឹងថា ព្រះអម្ចាស់ទ្រង់មិនចេញបញ្ជាដល់កូនចៅមនុស្សណាឡើយ លើកលែងតែទ្រង់នឹងរៀបចំផ្លូវ* ដូច្នោះខ្ញុំនឹងមិនធ្វើអ្វីឡើយ រហូតដល់ខ្ញុំដឹងប្រាកដច្បាស់ពីផ្លូវនោះសិន» ( *គ្មានខគម្ពីរ នីហ្វៃទី ១ ៣:៧បែបនេះឡើយ* ) ។

មិនយូរប៉ុន្មានក្រោយពីគ្រួសារលីហៃបានចាកចេញពីផ្ទះសម្បែងរបស់ពួកលោកដែលនៅក្រុងយេរូសាឡិម នោះព្រះអម្ចាស់បានបញ្ជាឲ្យកូនប្រុសរបស់លីហៃត្រឡប់ទៅយកផ្ទាំងមកពីឡាបាន់ ។ ប៉ុន្តែយើងដឹងថា លោកពុំបានផ្ដល់យោបល់ដល់ពួកគេអំពីរបៀបដើម្បីទៅយកផ្ទាំងនោះឡើយ ។ អ្វីដែលនីហ្វៃ និងពួកបងប្រុសរបស់លោកបានដឹងគឺថា ព្រះបានបញ្ជាឲ្យពួកគេត្រឡប់ផ្ទាំងនោះ ។ តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកគ្មានគំនិតដើម្បីធ្វើអ្វីមួយដែលអ្នកគួរតែធ្វើដែរឬទេ ? ( ប្រហែលនោះហើយជាហេតុផលមួយដែល លេមិន និង លេមយួល បានរអ៊ូរទាំ ! ) វាអាស្រ័យលើគំនិតរបស់នីហ្វៃ ហើយអនុវត្តសេចក្ដីជំនឿដើម្បីទៅ ហើយធ្វើវា ។ ប៉ុន្តែតើមានអ្វីកើតឡើងប្រសិនបើលោកនៅស្ងៀម ហើយចំណាយពេលវេលាខ្លះខ្វាយនោះ ? ចុះប្រសិនបើ នីហ្វៃបានបដិសេធធ្វើកិច្ចការនោះ ដោយរង់ចាំឲ្យព្រះប្រទានផែនការដល់លោកនោះ ? ការទៅយកផ្ទាំងគឺជារឿងលំបាកណាស់ ! លោក និងបងប្អូនរបស់លោកបានព្យាយាមពីរដង ហើយបរាជ័យ ! ចុះមានអ្វីកើតឡើងប្រសិនបើនីហ្វៃគ្រាន់តែអង្គុយផ្អែកនឹងជញ្ជាំងក្រុងយេរូសាឡិម ហើយរង់ចាំឲ្យព្រះប្រាប់លោកពីអ្វីដែលលោកត្រូវធ្វើនោះ ?

ផ្ទាំងទាំងនោះគឺបន្តនៅតែក្នុងឃ្លាំងរបស់ឡាបាន់ដដែល ។ សំណាងណាស់ នីហ្វៃពុំបានអង្គុយរង់ចាំនោះទេ ។

ផ្ទុយទៅវិញ លោកបានធ្វើតាមព្រះវិញ្ញាណ « ដោយមិនបានដឹងជាមុនសោះឡើយថា តើខ្ញុំនឹងត្រូវធ្វើអ្វីខ្លះ ។ *ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ* » ( នីហ្វៃទី ១ ៤:៦–៧ ការគូសបញ្ជាក់បានបន្ថែម ) ។ លោកពុំបានអង្គុយរង់ចាំនោះទេ លោកពុំបានបណ្ដោយឲ្យរឿងដែលលោកមិនដឹងបញ្ឈប់លោកឡើយ ។ លោកបានដឹងថា ព្រះនឹងប្រទានមធ្យោបាយមួយ ហើយលោកពិតជាគិតត្រឹមត្រូវមែន ។ នៅពេលនីហ្វៃបន្តទៅមុខធ្វើកិច្ចការនោះ ហើយឈានទៅមុខ នោះព្រះអម្ចាស់បានណែនាំ និង ជួយដល់លោក ។

## ប៉ុន្តែតើដោយសារមូលហេតុអ្វី ?

« *នោះណូអេ* បានសួរ *គ្រប់ទាំងសេចក្ដីដែលព្រះយេហូវ៉ាបានបញ្ជាដល់លោក* » ( *គ្មានខគម្ពីរ លោកុប្បត្តិ ៧:៥បែបនេះឡើយ* ) ។



ជួនកាលព្រះប្រទាននូវការណែនាំជាក់លាក់ ។ ចូរមើលណូអេជាគំរូអំពីរឿងនេះ ។ នៅពេលព្រះបានបញ្ជាណូអេឲ្យសង់ទូក ព្រះបានប្រទាននូវទំហំខ្នាត ដោយពន្យល់ពីវត្ថុធាតុនានាដើម្បីប្រើ ហើយថែមទាំងបានផ្ដល់បញ្ជីនៃអ្នកដែលត្រូវធ្វើដំណើរដល់ណូអេផងដែរ ។ អ្នកប្រហែលជាបានទទួលការបំផុសជាក់លាក់បែបនោះ ហើយយើងទាំងអស់គ្នាបានទទួលបទបញ្ញត្តិជាក់លាក់ ដូចជាគោលការណ៍នានានៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ ប៉ុន្តែទោះបីជាអ្នកដឹង





ច្បាស់លាស់ពីអ្វីដែលអ្នកគប្បីធ្វើក្តី តើអ្នកធ្លាប់ *នៅតែ* មានចិត្តស្ទាក់ស្ទើរដើម្បីធ្វើវាដែរឬទេ ? តើអ្នកធ្លាប់មានការល្បួងឲ្យសួរព្រះអម្ចាស់ ជាជាងធ្វើតាមទ្រង់ដែរឬទេ ?

ចុះមានអ្វីកើតឡើង ប្រសិនបើណូអេបានស្តាប់ឮព្រះអម្ចាស់ ហើយនិយាយថា « ប៉ុន្តែតើដោយសារមូលហេតុអ្វី ? ខ្ញុំមិនយល់វាឡើយ » ។ ចុះមានអ្វីកើតឡើង ប្រសិនបើ លោកដេកទម្រេតលើគ្រែ ហើយបដិសេធមិនធ្វើអ្វីសោះ រហូតដល់លោកបានយល់ច្បាស់ពី *មូលហេតុ* ដែលព្រះអម្ចាស់បានធ្វើឲ្យមានទឹកជំនន់ ដោយឆ្ងល់គ្រប់ពេលវេលាទាំងអស់ថា តើការណែនាំនោះពិតជាមកព្រះមែនឬ ?

នឹងមានទឹកជំនន់ ប៉ុន្តែតើនឹងមានទូកដែរឬទេ ? ចុះពូជមនុស្សវិញ ? វា *ពិតជា* សំណាងណាស់ ដែលណូអេមិនអង្គុយ ហើយសួរគ្រប់សំណួរនោះ ។

ផ្ទុយទៅវិញលោកបាន « ធ្វើសម្រេចតាមគ្រប់ទាំងសេចក្តី ដែលព្រះយេហូវ៉ាបានបង្គាប់មក » ( លោកុប្បត្តិ ៧:៥ ) ។ លោកគ្មានសំណួរឡើយ លោកបានប្រព្រឹត្តតាមដោយជំនឿ ។ ប្រសិនបើសួរក្នុងស្មារតីមួយត្រឹមត្រូវ ការមានសំណួរគឺជារឿងល្អ ។ សំណួរនោះអាចជួយយើងឲ្យរីកចម្រើន ហើយនាំយើងទទួលសេចក្តីពិតកាន់តែច្រើនឡើង ។ ប៉ុន្តែនៅពេលយើងបដិសេធមិនធ្វើអ្វីសោះ លុះត្រាយើងទទួលបានចម្លើយដែលចង់បានសិននោះ ការសួរសំណួរនោះអាចរារាំងយើងមិនឲ្យរីកចម្រើនឡើយ ។ ណូអេអាចមានសំណួរ ប៉ុន្តែលោកពុំបានបណ្តោយឲ្យសំណួរទាំងនោះបញ្ឈប់លោកឡើយ ។ វារៀងចម្លែកបន្តិច ដែលលោកបានសង់ទូកនៅលើដីគោក ហើយប្រមូលហ្វូងសត្វទាំងអស់ ព្រមទាំងបាននាំគ្រួសារលោកចូលក្នុងទូកនោះដោយបិទជិតឈឹង ។ ហើយនៅពេលវាចាប់ផ្តើមភ្លៀង នោះលោកប្រហែលជាសប្បាយចិត្តណាស់ ដែលលោកបានធ្វើការនោះ ។ ណូអេបានប្រព្រឹត្តដោយជំនឿ ហើយព្រះបានប្រទានពរដល់លោក និង គ្រួសារលោកទាំងមូល ។

## តើដកខ្លួនថយក្រោយ ហើយចាំមើលឬ ?

« *កាលដែលនាងឃើញថា ពួកអ្នកបម្រើទាំងអស់របស់ឡាម៉ូណៃ បានដួលទៅលើដី . . . នោះនាងដឹងថា នេះហើយជាព្រះចេស្តានៃព្រះ ហើយនាងបានគិតថា. . .ដោយឃើញឥទ្ធិពលនេះ . . . នឹងបណ្តាលឲ្យ [ មនុស្សដទៃ ] ជឿដល់ព្រះចេស្តានៃព្រះ ហេតុដូច្នេះហើយនាងបាន* ដកខ្លួនថយក្រោយ *ហើយរំពឹងថាមាននរណាម្នាក់នឹងប្រមូលមនុស្សទាំងនោះមក* » ( *គ្មានខគម្ពីរ អាលម៉ា ១៩:១៧បែបនេះឡើយ* ) ។

អ័ប៊ីសជាស្ត្រីសាសន៍លេមិន ។ គាត់បានប្រែចិត្តជឿទៅលើព្រះអម្ចាស់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្តែដោយសារគាត់បានរស់នៅក្នុងចំណោមសាសន៍លេមិនដែលគ្មានជំនឿ នោះគាត់បានរក្សាសេចក្តីជំនឿរបស់ខ្លួនជាសម្ងាត់ ។ នៅពេលអាំម៉ូនបានបង្រៀនដំណឹងល្អដល់ស្តេចឡាម៉ូណៃ ព្រះរាជានឹងសាច់សានុវង្សរបស់ទ្រង់ត្រូវបានគ្របសន្ធប់ដោយព្រះចេស្តានៃព្រះអម្ចាស់ ។ អ័ប៊ីសបានទទួលស្គាល់ថា នេះជាឱកាសមួយសម្រាប់ឲ្យមិត្តភក្តិ និង អ្នកជិតខាងរបស់គាត់មើលឃើញ ហើយជឿលើព្រះចេស្តារបស់ព្រះ ។ វាអាស្រ័យលើគាត់ ដើម្បីទៅប្រមូលប្រជាជនឲ្យមកមើលអព្ភូតហេតុនោះ ។

ចុះមានអ្វីកើតឡើងប្រសិនបើគាត់មិនបានធ្វើរឿងនេះនោះ ? បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំដែលគាត់បានលាក់បាំងសេចក្តីជំនឿរបស់ខ្លួន ដោយរត់ពីផ្ទះមួយទៅផ្ទះមួយដើម្បីប្រាប់មនុស្សគ្រប់គ្នា វាប្រហែលជារឿងមួយដែលភិតភ័យបន្តិច ! តើអ្នកធ្លាប់ត្រូវបានបំផុសគំនិត ឲ្យហ៊ាននិយាយ ប៉ុន្តែក្រោយមកមានអារម្មណ៍ភិតភ័យអំពីរឿងនោះដែរឬទេ ? ការចែកចាយជំនឿរបស់អ្នកអាចជារឿងលំបាក ! តើមានអ្វីកើតឡើង ប្រសិនបើអ័ប៊ីសគ្រាន់តែដកខ្លួនថយក្រោយ ហើយសង្ឃឹមថាប្រជាជននឹងឃើញអព្ភូតហេតុនោះដោយខ្លួនពួកគេផ្ទាល់នោះ ? ឬ ថាមាននរណាម្នាក់ដែលនឹងនិយាយរឿងនោះ ?

ប្រាកដណាស់ គ្មាននរណាម្នាក់នឹងជួបជុំគ្នា ដើម្បីមើលស្តេចឡាម៉ូណៃ និងសាច់សានុវង្សរបស់ទ្រង់ផ្ទុំស្តូកស្តឹងដូចជាសុគត ឬ ឃើញពីការភ្ញាក់ដឹងខ្លួនឡើងវិញដោយអព្ភូតហេតុនោះឡើយ ។ ពួកគេនឹងពុំមានវត្តមាននៅទីនោះ ដើម្បីស្តាប់ស្តេចឡាម៉ូណៃ ម្ចាស់ក្សត្រី និង អាំម៉ូនបង្រៀនដំណឹងល្អឡើយ ។

សំណាងណាស់ គាត់ពុំបានដកខ្លួនថយក្រោយឡើយ ។ ផ្ទុយទៅវិញគាត់ « *បានរត់* ពីផ្ទះមួយទៅផ្ទះមួយ ទៅប្រាប់ឲ្យប្រជាជនបានដឹង » ( អាលម៉ា ១៩:១៧ ការគូសបញ្ជាក់បានបន្ថែម ) ។ គាត់មានទីបន្ទាល់អំពីព្រះអម្ចាស់ ហើយគាត់ពុំបណ្តាលឲ្យភាពភ័យខ្លាចបញ្ឈប់គាត់ឡើយ ។ គាត់ពុំបានរង់ចាំឲ្យនរណាម្នាក់ទៀតនិយាយអ្វីឡើយ ។ នៅពេលគាត់មានឱកាសនោះហើយ គាត់គ្មានចិត្តស្ទាក់ស្ទើរឡើយ—គាត់បានរត់ ! អ័ប៊ីសបានប្រព្រឹត្តតាម ហើយព្រះអម្ចាស់បានប្រទានពរដល់គាត់ ឲ្យឃើញពីប្រជាជនរបស់គាត់បានប្រែចិត្តជឿលើដំណឹងល្អ ( សូមមើល អាលម៉ា ១៩ ) ។

## តើស្តាប់ពិភពលោកនេះឬ ?

« *ហើយ [ ព្រះយេស៊ូវ ] មានព្រះបន្ទូលថា ចូលមកចុះ ។ ពេត្រុសក៏* អង្គុយនៅក្នុង *ទូក លោក* ពុំដើរ *លើទឹកទៅដើម្បីទៅឯព្រះយេស៊ូវឡើយ* » ( *គ្មានខគម្ពីរម៉ាថាយ ១៤:២៩បែបនេះឡើយ* ) ។

ក្នុងនាមជាអ្នកនេសាទត្រី ពេត្រុសដឹងច្រើនអំពីទូក ។ ឧទាហរណ៍ ពេត្រុសបានដឹងថា នៅពេលមានព្យុះបោកបក់នៅលើសមុទ្រ នោះអ្នកត្រូវនៅក្នុងទូក ។ លោកបានដឹងថា អ្នកដែលឈានជើងដើរលើទឹកនឹងលិចចូលទៅក្នុងទឹកភ្លាម ។ តើអ្នកអាចស្រមៃថា តើលោកបានគិតអ្វីខ្លះ កាលលោកបានឃើញព្រះគ្រីស្ទយាងលើទឹកនោះ ?

ប៉ុន្តែមានអ្វីកើតឡើងប្រសិនបើលោកបន្តនៅលើទូកនោះ ? មនុស្សគ្រប់គ្នាដឹងថាមនុស្សទូទៅពុំអាចដើរលើទឹកបានឡើយ ។ តើមានអ្វីកើតឡើងប្រសិនបើពេត្រុសគ្រាន់តែផ្តោតលើអ្វីដែលពិភពលោកនេះ « បានដឹង » នោះ ? ជួនកាលការបង្រៀនរបស់ព្រះគ្រីស្ទ និង ព្យាការីរបស់ទ្រង់ទំនងជាជំទាស់ប្រឆាំងនឹងអ្វីដែលពិភពលោកកំពុងបង្រៀន ។ ហើយមនុស្សលោកគឺងាយបញ្ចុះបញ្ចូល និង ងាយស្តាប់តាម ។ តើមានអ្វីកើតឡើងប្រសិនបើ ពេត្រុសបានប្រាប់ព្រះគ្រីស្ទថា ការដើរលើទឹកគឺជារឿង

ខុសនឹងគោលការណ៍វិទ្យាសាស្ត្រ ឬ មិនសមហេតុផលនោះ ? តើមានអ្វីកើតឡើងប្រសិនបើពេត្រុសមានការភ័យខ្លាចខ្លាំងដើម្បីឈានជើងចេញពីទូក ហើយដើរទៅរកព្រះគ្រីស្ទនោះ ?

លោកនឹងខកខានមាននូវបទពិសោធន៍ដ៏អស្ចារ្យរួមគ្នាជាមួយនឹងលោកចៅហ្វាយ ។ លោកនឹងខកខានមានឱកាសពង្រឹងសេចក្ដីជំនឿរបស់លោក ហើយលោកអាចមានមន្ទិលសង្ស័យពីសេចក្ដីជំនឿរបស់លោកនាពេលអនាគត កាលលោកត្រូវការដំណោះស្រាយ ។ សំណាងណាស់ ដែលពេត្រុសពុំបន្តនៅក្នុងទូកឡើយ ។ ទោះជាមានរលក ព្យុះ ហើយលោកមានបទពិសោធន៍នៅសមុទ្រក្ដី ពេត្រុសចង់ចេញពីទូក ហើយដើរទៅរកព្រះគ្រីស្ទ ។ ទោះជាអ្វីៗគ្រប់យ៉ាងដែលពិភពលោកនេះ « បានដឹង » ក្ដី ពេត្រុសបានដើរលើទឹក ។ ទោះបីជាលោកបានចាប់ផ្ដើមលិចចុះទៅក្នុងទឹកក្ដី ព្រះគ្រីស្ទបានគង់នៅទីនោះចាប់លោកឡើង ( សូមមើល ម៉ាថាយ ១៤:២៨–៣១ ) ។

## តើខ្ញុំឬ ? ជាវីរបុរសដ៏ពិតនោះ ?

អ្នកត្រូវបានបញ្ជូនមកកាន់តែផែនដីនេះ ដើម្បីធ្វើជាវីរបុរសនៃជីវិតដ៏រំភើបរបស់អ្នកផ្ទាល់ ! នោះពុំមែនមានន័យថា ជាការលោតផ្លោះចេញពីអគារដែលឆេះផ្ទុះ ឬ បើករថយន្តគេចពីការតាមចាប់ខ្លួនជារៀងរាល់ថ្ងៃឡើយ ។ វាគឺមានន័យថាជាការជ្រើសរើស ប្រព្រឹត្តតាម ហើយឈានទៅមុខ ។

ព្រះអម្ចាស់បង្រៀនថាយើង « ត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ » ។ ទ្រង់ពុំមានព្រះបន្ទូលជាក់ច្បាស់ថា អ្វីខ្លះជាប្រយោជន៍ល្អ ដែលគួរធ្វើនោះឡើយ ផ្ទុយទៅវិញទ្រង់មានព្រះទ័យឲ្យយើង « ប្រព្រឹត្តអ្វីៗជាច្រើនតាមបំណងចិត្ត [ របស់យើង ] ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន » ( គ. និង ស. ៥៨:២៧ ) ។ នេះមានន័យថា ទ្រង់ទុកព្រះទ័យលើអ្នក ឲ្យធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន ហើយសម្រេចចិត្តពីរបៀបដែលអ្នកនឹងនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន ។ ជាញឹកញាប់ ជំនួយកើតឡើងបន្ទាប់ពីយើងអនុវត្តសេចក្ដីជំនឿ ហើយឈានដើរចាប់ពីជំហានដំបូងៗទាំងនោះ ។

ព្រះអម្ចាស់គង់នៅទីនោះជានិច្ចដើម្បីនាំផ្លូវយើង នៅពេលយើងត្រូវការ ប៉ុន្តែប្រសិនបើយើងបដិសេធដើម្បីប្រព្រឹត្តតាម ហើយឈានទៅមុនដោយខ្លួនឯង ហើយរំពឹងថាព្រះប្រាប់អ្នកឲ្យធ្វើនូវគ្រប់អ្វីៗទាំងអស់ដែលតូចតាច នោះអ្នកនឹងក្លាយជា « បាវខ្ជិលច្រអូស ហើយមិនមានប្រាជ្ញាទៅវិញ » ( សូមមើល គ. និង ស. ៥៨:២៦ ) ។ ហើយតើនរណាដែលចង់ក្លាយជាបាវខ្ជិលច្រអូស កាលអ្នកអាចក្លាយជាវីរបុរសនោះ ? ■



# ខ្ញុំមានការលំបាកក្នុងការសិក្សាព្រះគម្ពីរ ។ ហេតុអ្វីវាសំខាន់ដើម្បីសិក្សាព្រះគម្ពីរ ?

ចេញពីបាវចនាម៉ូឆលឆ្នាំនេះ យើងបានរៀនអំពីរបៀបដើម្បី « ឈានទៅ មុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ » ( នីហ្វៃទី ២ ៣១:២០ ) ។ ខគម្ពីរនេះបង្រៀនថា ការឈានទៅមុខរួមមានទាំងការ « ទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ » ។ ហេតុអ្វីវាសំខាន់ ? នេះគឺជាវិធីមួយចំនួន ដែលការសិក្សាព្រះគម្ពីរជួយយើងឲ្យឈានទៅមុខ ៖

- ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនថា « ប្រសិនបើអ្នកសិក្សាព្រះគម្ពីរដោយចិត្តឧស្សាហ៍ព្យាយាម នោះអំណាចរបស់អ្នកដើម្បីចៀសវាងពីការល្បួង និង ដើម្បីទទួលការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងកិច្ចការដែលអ្នកធ្វើនឹងរីកចម្រើនឡើង » ( « Be Your Best Self » *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៦៨ ) ។
- អ្នកអាចទទួលបានទីបន្ទាល់ និង ពង្រឹងសេចក្ដីជំនឿរបស់អ្នក ពេលអ្នកសិក្សាព្រះគម្ពីរប្រកបដោយការអធិស្ឋាន ។ ជាពិសេសការសិក្សាព្រះគម្ពីរមរមន និង ការទទួលបានទីបន្ទាល់នៃសេចក្ដីពិតដ៏ពោរពេញរបស់វា នឹងជួយអ្នកឲ្យដឹងថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការី ហើយថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាសាសនាចក្រពិត ។ ( អ្នកអាចរៀនបន្ថែមទៀតអំពីការសន្យាទាំងនេះនៅក្នុងបុព្វកថានៃព្រះគម្ពីរមរមន ) ។
- អ្នកអាចទទួលបានការបំផុសគំនិត និង ចម្លើយផ្ទាល់ខ្លួនចំពោះសំណួររបស់អ្នកតាមរយៈព្រះគម្ពីរ ។ នៅពេលព្រះទាក់ទងជាមួយអ្នកតាមរយៈព្រះគម្ពីរ និង ព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកអាចមានទំនុកចិត្ត និង កម្លាំងដើម្បីឈានទៅមុខទោះបីជាអ្នកជួបឧបសគ្គអ្វីក៏ដោយ ។
- ប្រហែលជាហេតុផលសំខាន់បំផុតដើម្បីសិក្សាព្រះគម្ពីរនោះគឺថា ព្រះគម្ពីរបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ និង របៀបដែលអ្នកអាចធ្វើតាមគំរូ និង ការបង្រៀនរបស់ទ្រង់ ។ ការរស់នៅតាមគោលការណ៍ដែលអ្នករៀន នឹងជួយអ្នកឲ្យប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ ។

### ជាចម្លើយចំពោះសំណួររបស់ខ្ញុំ

ប្រសិនបើខ្ញុំមានសំណួរ ខ្ញុំដឹងថា ខ្ញុំអាចបើកព្រះគម្ពីរ ហើយស្វែងរកចម្លើយ ។ ព្រះគម្ពីរមានព្រះបន្ទូលរបស់ព្រះអម្ចាស់ និង គោលលទ្ធិរបស់ទ្រង់ដែលគ្មានការផ្លាស់ប្ដូរ ។ ខ្ញុំដឹងថា ទោះខ្ញុំជួបឧបសគ្គធំប៉ុណ្ណាក្ដី ព្រះគម្ពីរជួយផ្ដល់ចម្លើយដល់ខ្ញុំជានិច្ច ។ ព្រះគម្ពីរក៏ឆ្លើយសំណួរអំពីគោលជំហររបស់សាសនាចក្រលើប្រធានបទជាច្រើន ។ ខ្ញុំដឹងថា ប្រសិនបើខ្ញុំអានព្រះគម្ពីរដោយយកចិត្តទុកដាក់ នោះវានឹងជួយខ្ញុំឲ្យមានព្រះវិញ្ញាណគង់នៅជាមួយខ្ញុំ ដែលជួយខ្ញុំឲ្យដឹងខុស និង ត្រូវ ។

*អេមីលី អាយុ ១៧ ឆ្នាំ រដ្ឋ វ៉ាស៊ីងតោន ស.រ.អា.*



### បន្ទុករបស់ខ្ញុំបានស្រាល

មានគ្រាមួយក្នុងឆ្នាំសិក្សា ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ថាមានបន្ទុកដ៏ធ្ងន់ ដែលកើតមកពីភាពតានតឹងក្នុងជីវិត ។ អំឡុងពេលនៃគ្រាដ៏តានតឹងនោះ ខ្ញុំបានអធិស្ឋាន ហើយសិក្សាព្រះគម្ពីរមរមនអស់រយៈពេល ១០ នាទី ។ ពេលខ្ញុំបានអាន ខ្ញុំបានមានអារម្មណ៍យ៉ាងកក់ក្ដៅក្នុងដួងចិត្តខ្ញុំ ។ ខ្ញុំបានមានអារម្មណ៍នៃក្ដីស្រឡាញ់លើកស្ទួយចិត្តឡើង ហើយមានភាពរីករាយទោះបីខ្ញុំមានការសាកល្បងក្ដី ។ ខ្ញុំមានអារម្មណ៍សុខសាន្តជាខ្លាំង ជាអារម្មណ៍ដែលខ្ញុំមិនធ្លាប់មានពីមុន ។ ចេញពីបទពិសោធន៍នេះ ទីបំផុតខ្ញុំយល់ថា អ្វីដែលព្រះអង្គសង្គ្រោះមានបន្ទូល នៅពេលទ្រង់មានបន្ទូលថា « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា » ( យ៉ូហាន ១៤:២៧ ) ។ ពីរបីសប្ដាហ៍បន្ទាប់មកទៀត ខ្ញុំបានមានបទពិសោធន៍នេះជាច្រើនដង ហើយវាបំផុសគំនិតខ្ញុំឲ្យឈានទៅមុខតាមរយៈការពុះពាររបស់ខ្ញុំ ។

*ក្លូអេ ខេ អាយុ ១៨ ឆ្នាំ វីស្កុនស៊ិន ស.រ.អា.*

### អំណាចដើម្បីផ្លាស់ប្ដូរ

ពីមុនខ្ញុំពិតជាគ្មានទីបន្ទាល់អំពីព្រះគម្ពីរមរមនឡើយ ប៉ុន្តែនៅពេលខ្ញុំបានអធិស្ឋានដោយស្មោះសរ

*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និង ទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

សម្រាប់ការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ នោះខ្ញុំមានអារម្មណ៍អស្ចារ្យយ៉ាងខ្លាំងអំពីព្រះគម្ពីរមរមន ។ ខ្ញុំមានគោលបំណងរួចជាស្រេច ដើម្បីដឹងថាព្រះគម្ពីរនោះពិត ដូច្នោះខ្ញុំបានចាប់ផ្ដើមអាន និង សិក្សាដោយគិតគូរពីវា ។ មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ នោះខ្ញុំបានទទួលវិវរណៈផ្ទាល់ខ្លួនថា ព្រះគម្ពីរនោះគឺជាព្រះគម្ពីរពិត ( សូមមើល នីហ្វៃទី ២ ២៨:៣០ ) ។ ខ្ញុំស្រឡាញ់ព្រះគម្ពីរមរមន ។ ខ្ញុំរក្សាការបង្រៀននានាដែលខ្ញុំទទួលបានអំឡុងពេលសិក្សាព្រះគម្ពីរ ។ ព្រះគម្ពីរមរមនមានអំណាចមួយដែលអាចនាំយើងឲ្យផ្លាស់ប្ដូរកាន់តែប្រសើរឡើង ។

*អារៀល ខានដាវ៉ាន់ ធី អាយុ ១៨ ឆ្នាំ ប្រទេសហ្វីលីពីន*



## សេចក្ដីស្រឡាញ់របស់ព្រះ

ឧទាហរណ៍តាមរយៈព្រះចេស្ដា និង ការបង្រៀននៅក្នុងព្រះគម្ពីរ ខ្ញុំអាចងាយនឹងទទួលឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះគម្ពីរមានព្រះចេស្ដាមកពីព្រះ ក្នុងរបៀបមួយដែលព្រះអាចណែនាំ និង បង្រៀនពួកយើង ។ ដូច្នេះនៅពេលអ្នកមានអារម្មណ៍ឯកោ ឬ គេបោះបង់ចោល សូមអានព្រះគម្ពីរ ។ បន្ទាប់មកសូមចងចាំថា ព្រះវរបិតាគង់នៅស្ថានសួគ៌បានរក្សាទុកនូវអ្វីៗទាំងនោះជាពិសេសសម្រាប់អ្នក ប្រយោជន៍ឲ្យអ្នកអាចដឹងថា ទ្រង់ស្រឡាញ់អ្នក ។

*ស្កត អេច អាយុ ១៩ ឆ្នាំ វីស្កុនសិន ស.រ.អា.*

## ភាពល្អ និង ពន្លឺ

ខ្ញុំបានចាប់ផ្ដើមអានព្រះគម្ពីរមរមនជាលើកដំបូងនៅពេលខ្ញុំគ្រប់អាយុចូលក្នុងក្រុមប៊ីហៃ ។ ខ្ញុំបានអានវាតាំងពីដើមរហូតដល់ចប់ ហើយបានគិតថាវាចប់ហើយ ។ ប៉ុន្តែខ្ញុំគិតខុសទាំងស្រុង ។ ជីវិតរបស់ខ្ញុំហាក់ដូចជាខ្វះអ្វីម៉្យាង ។ ដូច្នោះខ្ញុំបានសម្រេចចិត្តចាប់ផ្ដើមអានព្រះគម្ពីរម្ដងទៀត ម្ដងនេះខ្ញុំបានផ្ដោតចិត្តទុកដាក់កាន់តែខ្លាំង ។ នៅពេលខ្ញុំធ្វើបែបនេះ ជីវិតរបស់ខ្ញុំបានពោរពេញដោយពន្លឺដែលបំភ្លឺភាពស្រអាប់ដែលខ្ញុំមានតាំងពីខ្ញុំបានឈប់អានវាមក ។ ខ្ញុំបានយល់កាន់តែច្រើនថែមទៀត ហើយកាន់តែចូលចិត្តវាឡើង ។ សូមអានវាគ្រប់ពេលវេលា នោះអ្នកកំពុងធ្វើឲ្យប្រាកដថាខ្លួនអ្នកមានជីវិតមួយដែលមានភាពល្អ និង ពន្លឺ ។

*ខេលី អិម អាយុ ១៥ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.*



## យកឈ្នះលើសេចក្ដីល្បួង

ការសិក្សាព្រះគម្ពីរជួយខ្ញុំឲ្យរស់នៅតាមដំណឹងល្អនៅសាលារៀន ។ ខ្ញុំទើបតែចាប់ផ្ដើមចូលរៀននៅអនុវិទ្យាល័យ ហើយមានរឿងអាក្រក់ៗ និង ការល្បួងជាច្រើន ។ នៅពេលខ្ញុំមានគ្រាដ៏លំបាកក្នុងការទប់ទល់នឹងការល្បួង នោះខ្ញុំព្យាយាមអានរឿងក្នុងព្រះគម្ពីរ ដើម្បីស្វែងរកចម្លើយចំពោះបញ្ហាខ្ញុំ ។ វាជួយបណ្ដេញការល្បួង ហើយងាកបែរទៅរកដំណឹងល្អ ។

*ប្លែក ស៊ី អាយុ ១២ ឆ្នាំ រដ្ឋ អៃដាហូ ស. រ. អា.*

## ព្រះចេស្ដានៃព្រះគម្ពីរ

នេះជាលើកដំបូងដែលខ្ញុំព្យាយាមអានព្រះគម្ពីរមរមន ។ ជំពូកដែលខ្ញុំពេញចិត្តនោះគឺ នីហ្វៃទី ២ ២៥–៣៣ ។ មកទល់នឹងពេលនេះ ព្រះគម្ពីរបានពង្រឹងខ្ញុំខ្លាំងបំផុត ។ ចម្រៀងថ្នាក់កុមារបទ « អំណាចនៃព្រះគម្ពីរ » ពុំដែលមានភាពច្បាស់លាស់ចំពោះខ្ញុំជាងពេលនេះឡើយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីភាពពិតពេញលេញនៃព្រះគម្ពីរមរមន ហើយផ្ដល់យោបល់យ៉ាងខ្លាំងដល់អ្នក ឲ្យសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ។

*សារ៉ាយ ជេ អាយុ ១៣ ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា.*



### ប្រភពនៃចំណេះដឹង

« យើងគួរតែស្រេកឃ្លានស្វែងរកចំណេះដឹងខាងវិញ្ញាណរៀងរាល់ថ្ងៃ ។ ការអនុវត្តផ្ទាល់ខ្លួននេះធ្វើឡើងតាមរយៈការសិក្សា ការសម្មាធិ និង ការអធិស្ឋាន ។ ជួនកាលយើងអាចទទួលការល្បួងឲ្យគិតថា ‹ ខ្ញុំមិនត្រូវការសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃទេ ខ្ញុំអានអស់ហើយ › ។ . . .

ប៉ុន្តែដំណឹងល្អគឺជាប្រភពនៃចំណេះដឹងដែលមិនចេះរីងស្ងួតទេ ។ មានអ្វីដែលត្រូវរៀន និង ទទួលអារម្មណ៍ថ្មីៗជានិច្ច . . . នៅក្នុងគ្រប់ខគម្ពីរទាំងអស់ » ។

**ប៊ីស្សព ហ្គេរ៉ល កូសសៃ ប៊ីស្សពជាអធិបតី « Is It Still Wonderful to You ? » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ទំព័រ ៩៩–១០០ ។**

## សំណួរបន្ទាប់

« ខ្ញុំបានអធិស្ឋានទូលសុំអ្វីមួយដែលសំខាន់ ប៉ុន្តែខ្ញុំពុំដឹងឡើយថា ខ្ញុំបានទទួលចម្លើយឬអត់នោះ ។ តើខ្ញុំនឹងដឹងរឿងនេះយ៉ាងដូចម្ដេច ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៧ នៅគេហទំព័រ liahona.lds.org ( សូមចុច « Submit an Article » ) ឬ អ៊ីម៉ែលទៅកាន់ liahona@ldschurch.org ។

សូមផ្ញើព័ត៌មានដូចតទៅនេះ ៖ (១) នាម និង គោត្តនាម (២) ថ្ងៃ ខែ ឆ្នាំ កំណើត (៣) វួដ ឬ សាខា (៤) ស្តេក ឬ មណ្ឌល (៥) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយប្រសិនបើអ្នកអាយុក្រោម ១៨ ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយអ្នក ជាលាយលក្ខណ៍អក្សរ ( អ៊ីមែលអាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬ មិនសូវច្បាស់លាស់ ។



# ការផ្ដល់ឲ្យដែលលើស ពីអំណោយទៅទៀត

*តើអ្នកចង់ធ្វើជាអ្នកបរិច្ចាគបែបណា ?*

ដោយ អែមម៉ាលីន អ៉ រ វីលសុន

រដូវបុណ្យគ្រីស្ទម៉ាស់គឺជាអ្វីៗទាំងអស់អំពីព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ និង វិញ្ញាណនៃការផ្ដល់ឲ្យ ។ ដោយសារវាជារឿងអស្ចារ្យដើម្បីផ្ដល់ និង ទទួលអំណោយ សូមចាំថាយើងអាចផ្ដល់អំណោយដែលវាលើសពីអំណោយទៅទៀត ។ រៀងរាល់ថ្ងៃយើងអាចលះបង់ពេលវេលា ទេពកោសល្យ និង សេចក្ដីសប្បុរសរបស់យើង—ហើយអ្វីៗទាំងនោះគឺជាមធ្យោបាយដ៏មានខ្លឹមសារមួយចំនួនដែលយើងអាចបម្រើបាន ។

ដូច្នេះតើអ្នកធ្វើបានល្អកម្រិតណា លើការផ្ដោតទៅលើការផ្ដល់អំណោយដោយមិនគិតពីខ្លួនឯងនោះ ? សូមធ្វើលំហាត់នេះដើម្បីស្វែងយល់ពីរឿងនេះ ។

១

អ្នកកំពុងរៀបចំខ្លួនទៅសាលារៀន ។ ម៉ាក់របស់អ្នកសុំអ្នកឲ្យមកស្រស់ស្រូបអាហារពេលព្រឹក ហើយគាត់បានឆ្លៀតពេលរៀបចំអាហារដែលអ្នកចូលចិត្ត ។ តើអ្នកធ្វើយ៉ាងដូចម្ដេច ?

ក. ស្រែកថាចាំសិន « កូនមិនទាន់រៀបចំខ្លួនហើយទេ ! » ហើយបន្ទាប់មកចំណាយពេលរៀបចំខ្លួនឲ្យបានរួច ស្រស់ស្រូបអាហារពេលព្រឹកយឺត ហើយខកជើងឡានក្រុង ដូច្នោះគាត់ត្រូវជូនអ្នកទៅសាលារៀន ។

ខ. ស្រស់ស្រូបអាហារពេលព្រឹកយ៉ាងលឿន ហើយរត់ចេញទៅយ៉ាងរហ័ស គាត់ធ្វើកិច្ចការទាំងនេះជានិច្ច—វាជាកិច្ចការដែលម្ដាយត្រូវធ្វើ ។

គ. អរគុណម៉ាក់ រៀបចំខ្លួនឲ្យរួចយ៉ាងរហ័ស ហើយចំណាយពេលស្រស់ស្រូបអាហារជាមួយគ្រួសាររបស់អ្នក ។

រូបថត © ISTOCK/THINKSTOCK

## ២

ម៉ោង ១០ ព្រឹកហើយ គ្រូបង្រៀនរបស់អ្នកហៀបនឹងចែកក្រដាសកិច្ចការហើយ ។ អ្នកពុំស្គាល់មនុស្សដែលអង្គុយជាប់អ្នកច្បាស់ទេ ប៉ុន្តែអ្នកឃើញថា នាងអន្ទះសាររកមើលអ្វីមួយពីកាបូបរបស់នាង ។ តើអ្នកធ្វើយ៉ាងដូចម្ដេច ?

**ក.** មិនខ្វល់នឹងនាង ។ អ្នកក៏មានភាពតានតឹងផងដែរ ហើយបង្ខំរៀនសម្រាប់ការប្រលង ។

**ខ.** ជូនពរនាងឲ្យមានសំណាងល្អ ។

**គ.** សួរនាងប្រសិនបើនាងកំពុងរកមើលអ្វីមួយ ។ នៅពេលអ្នកឮថានាងត្រូវការខ្មៅដៃ នោះអ្នកឲ្យខ្មៅដៃអ្នកទៅនាង ។ អ្នកប្រាប់នាងដោយញញឹមថា « ទុកវាប្រើចុះ » ។

## ៣

បន្ទាប់ពីម៉ោងរៀន មានម្នាក់នៅក្នុងក្រុមបាល់ឱបរបស់អ្នក មានការលំបាកក្នុងការបញ្ជូនបាល់បានត្រឹមត្រូវ—តែអ្នកជំនាញខាងបញ្ជូនបាល់នេះ ។ គាត់បានមកបន្ទាប់ពីហាត់សម ហើយសួរប្រសិនបើអ្នកអាចជួយគាត់ ។ តើអ្នកនិយាយដូចម្ដេច ?

**ក.** ប្រាប់គាត់ថាអ្នករវល់ណាស់ ។ ប្រហែលជាចាំថ្ងៃក្រោយ ។

**ខ.** យល់ព្រមទាំងស្ទាក់ស្ទើរចិត្ត ហើយបញ្ជូនបាល់ឲ្យគាត់បានពីរបីដង បង្រៀនគាត់ពីរបីស្នៀតយ៉ាងលឿន ពីមុនប្រញាប់ចេញទៅដើរលេងជាមួយមិត្តភក្ដិរបស់អ្នក ។

**គ.** ចំណាយពេលច្រើនជាមួយគាត់ដោយបង្រៀនគាត់ជាច្រើនស្នៀត ហើយណាត់ម៉ោងពេលក្រោយទៀតដើម្បីហាត់សមជាមួយគ្នា ។

## ៤

នៅម៉ោង ៥:៣០ ល្ងាចហើយ ម៉ាក់របស់អ្នកបានដាក់អ្នកចុះនៅហាងទំនិញ ដើម្បីទិញអំណោយសម្រាប់បុណ្យគ្រីស្ទម៉ាស់សម្រាប់ប្អូនស្រីរបស់អ្នក ។ តើអ្នកទិញអ្វីខ្លះ ?

**ក.** វាកិច្ចការងាយណាស់ ។ អ្នកបានទៅទិញបាល់បោះថ្មីដែលអ្នកបានចាប់អារម្មណ៍ជាច្រើនខែមុនមកហើយ ។ . . . នាងប្រហែលជាចូលចិត្តបាល់នេះផងដែរ មែនទេ ?

**ខ.** ជ្រើសរើសវត្ថុដែលថោកបំផុតដែលមាននៅក្នុងបញ្ជីរបស់នាង—នាងនឹងមិនអាក់អន់ចិត្តឡើយ ហើយអ្នកមិនអស់លុយច្រើនឡើយ ។

**គ.** ស្វែងរកសៀវភៅថ្មីបំផុតមួយដែលមានអ្នកនិពន្ធ ដែលនាងពេញចិត្ត ។ អ្នកទន្ទឹងរង់ចាំឃើញពីក្ដីរំភើបនៅលើទឹកមុខរបស់ប្អូនស្រីរបស់អ្នក នៅពេលនាងបើកកញ្ចប់អំណោយនោះ !

៥

វាដល់ម៉ោងដេក ហើយអ្នកអស់កម្លាំងជាខ្លាំង ។ អ្នកពុំទាន់បានអានព្រះគម្ពីរនៅឡើយ ។ តើអ្នកធ្វើយ៉ាងដូចម្ដេច ?

**ក.** រាប់ខគម្ពីរដែលអ្នកបានអានកាលពីថ្ងៃអាទិត្យជំនួសវិញ ។

**ខ.** អំឡុងពេលស្រាវជ្រាវព្រះគម្ពីរ អ្នកបានឃើញរឿងប្រលោមលោកដែលអ្នកចូលចិត្ត ។ សាមសិបនាទីក្រោយមក អ្នកបានចាំថាត្រូវអានព្រះគម្ពីរ ហើយអ្នកបានអានវគ្គបទគម្ពីរមួយយ៉ាងលឿន ពីមុនបិទភ្លើងចូលដេក ។

**គ.** អានទាំងព្រះគម្ពីរ និង រឿងប្រលោមលោកដែលអ្នកពេញចិត្តនោះ ប៉ុន្តែសម្រេចចិត្តផ្តល់អាទិភាពដំបូងដល់ព្រះវរបិតាសួគ៌ ហើយអធិស្ឋានមួយខ្លី ពីមុនអ្នកចាប់ផ្តើមអាន ។ អ្នកកត់គំនិតមួយចំនួនរបស់អ្នក នៅពេលអ្នកសិក្សា ហើយអ្នកថ្លែងអំណរគុណទ្រង់ម្តងទៀតពេលអធិស្ឋានពីមុនអ្នកចូលដេក ។

### លទ្ធផល !

ប្រសិនបើអ្នកបានឆ្លើយចម្លើយ **(ក)** ភាគច្រើន នោះអ្នកអាចបង្វែរការផ្តោតចិត្តរបស់អ្នកថែមបន្តិចទៀតចំពោះមនុស្សដទៃ ។ សូមចងចាំថា ការផ្តល់ និង ការបម្រើមនុស្សដទៃនឹងនាំមកនូវសុភមង្គលដ៏អស្ចារ្យដល់មនុស្សគ្រប់គ្នាដែលពាក់ព័ន្ធ ( សូមមើល ម៉ាថាយ ២៥:៣៤–៤៦ ) ។

ប្រសិនបើអ្នកបានឆ្លើយចម្លើយ **(ខ)** ភាគច្រើន នោះសូមពិចារណាថា « អ្នករាល់គ្នាបានទទួលទទេ ត្រូវឲ្យទទេដែរ » ( ម៉ាថាយ ១០:៨ ) ។ សូមគិតអំពីរបៀបដែលការផ្តល់ឲ្យកាន់តែច្រើនដោយមានឆន្ទៈអាចជួយអ្នកស្វែងរកអំណរកាន់តែច្រើនឡើង ។

ប្រសិនបើអ្នកបានឆ្លើយចម្លើយ **(គ)** ភាគច្រើន សូមបន្តធ្វើវាទៀតចុះ ! ទង្វើរបស់អ្នកបង្ហាញពីវិញ្ញាណដ៏ពិតនៃបុណ្យគ្រីស្ទម៉ាស់ដ៏ពិត ។

សូមពិចារណាអំពីរបៀបដែលអ្នកអាចផ្តល់អំណោយទានដោយចិត្តសប្បុរស ដល់អស់អ្នកដែលនៅជុំវិញខ្លួនអ្នកនារដូវបុណ្យគ្រីស្ទម៉ាស់នេះ ។ មិនថាអ្នកមានទេពកោសល្យបែបណានោះទេ អ្នកអាចស្វែងរករបៀបមួយដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់អ្នក និង អំណរគុណចំពោះអ្នកដទៃ តាមរយៈទាំងអំណោយដែលអ្នកផ្តល់ និង របៀបដែលអ្នកផ្តល់អំណោយនោះរៀងរាល់ថ្ងៃ ។ ការផ្តល់ឲ្យក្លាយជាពរជ័យ ហើយមិនមែនជាការសាកល្បងដ៏លំបាកឡើយ នៅពេលយើងយល់ថា តាមរយៈការបម្រើមនុស្សដទៃនោះយើងពិតជាបម្រើដល់ព្រះវរបិតាសួគ៌របស់យើង ( សូមមើល ម៉ូសាយ ២:១៧ ) ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



### ចូរផ្តល់ឲ្យដោយសេរី

« ខ្ញុំសូមអធិស្ឋានថា មនុស្សដទៃនឹងធ្វើឲ្យយើងរំជួលចិត្ត ថាយើងនឹងផ្តល់ឲ្យដោយគ្មានអារម្មណ៍នៃការបង្ខិតបង្ខំ ឬ រំពឹងចង់បានប្រយោជន៍ ហើយថាយើងនឹងដឹងថា ការបូជាត្រូវបានធ្វើឡើងយ៉ាងមានន័យចំពោះយើងនៅពេលយើងមានអំណរដែលបានកើតឡើងនៅក្នុងចិត្តរបស់មនុស្សដទៃទៀត » ។

ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ
« Preparing Gifts for Your Future Family »
*Liahona* ខែ មករា ឆ្នាំ ២០១៤ ទំព័រ ៤៩ ។

# ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនាដែលខ្ញុំត្រូវការ

*ខ្ញុំជាសមាជិកសាសនាចក្រ ប៉ុន្តែខ្ញុំក៏ត្រូវការអ្នកផ្សព្វផ្សាយសាសនាដែរ ។*

ដោយ កាព្រីយ៉េល ខុស្តា ស៊ីលវ៉ា

នៅពេលខ្ញុំឈានដល់អាយុ ១៧ ឆ្នាំ មិត្តភក្តិរបស់ខ្ញុំទាំងអស់បានចេញពីខ្ញុំ ។ ពួកគេបានប្ដូរទៅរស់នៅកន្លែងឆ្ងាយ ទៅបម្រើបេសកកម្ម ឬ ឈប់ធ្វើជាមិត្តភក្តិរបស់ខ្ញុំទៀត ។ ទោះបីជាខ្ញុំមានគ្រួសារក្ដី ខ្ញុំនៅតែមានអារម្មណ៍ថាឯកោ ។ ខ្ញុំមានអារម្មណ៍ថាគ្មាននរណាគាំទ្រខ្ញុំឡើយក្រៅពីអ្នកផ្ទះរបស់ខ្ញុំ ហើយខ្ញុំមិនត្រូវនឹងមនុស្សដទៃឡើយ ទោះបីជាខ្ញុំបានព្យាយាមក៏ដោយ ។

ថ្ងៃមួយអ្នកផ្សព្វផ្សាយសាសនាថ្មីដែលបានចាត់ឲ្យមកវួដរបស់យើង បានមកផ្ទះយើងដើម្បីណែនាំខ្លួនពួកគេឲ្យយើងស្គាល់ ។ ពួកគេបានសួរថាតើពួកយើងមានអ្វីខ្លះឲ្យពួកគេជួយ ។ ខ្ញុំពុំបានខ្វល់នឹងអ្វីដែលពួកគេបាននិយាយឡើយ ដោយសារខ្ញុំកំពុងតែគិតពីទុក្ខព្រួយ និង ភាពឯកោដែលខ្ញុំមានតែប៉ុណ្ណោះ ។ ក្រោយមកអ្នកផ្សព្វផ្សាយសាសនាបាននិយាយថា ពួកគេចង់ឲ្យខ្ញុំជួយបង្រៀនមេរៀនមួយចំនួន ។ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ។ ហេតុអ្វីពួកគេសុំជំនួយពីមនុស្សម្នាក់ដែលបង្ហាញយ៉ាងច្បាស់ពីស្ថានភាពដែលគ្មានអារម្មណ៍ល្អសោះនោះ ?

ខ្ញុំបានយល់ព្រម ហើយខ្ញុំបានទៅបង្រៀនជាមួយពួកគេ ។ អ្នកផ្សព្វផ្សាយសាសនាមិនគ្រាន់តែជួយមនុស្សដែលពួកគេបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏មានឥទ្ធិពលយ៉ាងល្អលើខ្ញុំផងដែរ ។

នៅពេលអែលឌើរម្នាក់បានប្ដូរតំបន់ ខ្ញុំបានដឹងថាជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរកាន់តែប្រសើរឡើង ចាប់តាំងពីខ្ញុំបានចំណាយពេលជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំមានចំណុចជាច្រើនដែលដូចទៅនឹងអែលឌើរថ្មីនេះ ដែលបានប្ដូរមកតំបន់យើង ហើយខ្ញុំបានបន្តចំណាយពេលជាមួយអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានលើកទឹកចិត្ត បង្រៀន និង គាំទ្រដល់ខ្ញុំ ។ ពួកគេបានជួយខ្ញុំឲ្យមានអារម្មណ៍ប្រសើរឡើងនាថ្ងៃដែលខ្ញុំមានការលំបាក ។ ទោះបីមានភាសាជារនាំង ហើយមានកាលវិភាគដ៏មមាញឹកក្តី អ្នកផ្សព្វផ្សាយសាសនាបានខិតខំជួយខ្ញុំ ។ អ្នកផ្សព្វផ្សាយសាសនាបានជួយខ្ញុំឲ្យដឹងថា ខ្ញុំមិនឯកោឡើយ ។ ព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ កំពុងទតមើលយើង ហើយជួយយើងតាមរយៈមនុស្សដទៃ ។



នៅពេលអែលឌើរថ្មីនោះបានប្ដូរតំបន់ ខ្ញុំបានអរគុណគាត់ចំពោះ ការធ្វើជាឧបករណ៍ក្នុងព្រះហស្តរបស់ព្រះអម្ចាស់ដើម្បីសង្គ្រោះខ្ញុំ ។ ខ្ញុំមានអំណរគុណដែលគាត់បានមកបេសកកម្មដ៏ពិសេសនេះ ដោយសារគាត់ជាពរជ័យមួយសម្រាប់ខ្ញុំ ។

កាលពីមុន ខ្ញុំគ្មានបំណងបម្រើបេសកកម្មទាល់តែសោះ ប៉ុន្តែនៅពេលខ្ញុំបានមើលអ្នកផ្សព្វផ្សាយសាសនាទាំងនេះ នោះបំណងប្រាថ្នារបស់ខ្ញុំដើម្បីបម្រើបានកើនឡើង ។ ខ្ញុំនឹងទៅបម្រើបេសកកម្មក្នុងពេលឆាប់ៗនេះ ហើយខ្ញុំរីករាយដើម្បីថ្វាយអ្វីៗ ដែលខ្ញុំមានចំពោះព្រះអម្ចាស់ដូចអ្នកផ្សព្វផ្សាយសាសនាទាំងនោះបានធ្វើ ។

នាយប់មួយ មុនពេលអ្នកផ្សព្វផ្សាយសាសនាមួយគូនោះមកផ្ទះរបស់ខ្ញុំ ខ្ញុំចាំពីអារម្មណ៍ឯកោ ហើយខ្ញុំបានអធិស្ឋាន ។ ខ្ញុំបានទូលសុំព្រះដោយអស់ពីចិត្តរបស់ខ្ញុំ សូមឲ្យទ្រង់គ្រាន់តែបញ្ជូនមិត្តភក្តិម្នាក់ជួយ ហើយគាំទ្រខ្ញុំ ។ ព្រះអម្ចាស់បានឆ្លើយតបចំពោះការអធិស្ឋានរបស់ខ្ញុំតាមរបៀបមួយដ៏អស្ចារ្យ—ដោយបញ្ជូនអ្នកផ្សព្វផ្សាយសាសនាមក ។ ខ្ញុំដឹងថាព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយថាពួកអ្នកផ្សព្វផ្សាយសាសនាគឺជាអ្នកបម្រើរបស់ទ្រង់ ។ ■

*អ្នកនិពន្ធរស់នៅសៅ ប៉ូឡូ ប្រេស៊ីល ។*

រចនារូបភាពដោយ ប៉ាប្លូ លីបឹត

# ចូរកុំពន្យារពេល

ពួកអ្នកគង្វាលបានស្ដាប់ឮសារលិខិត ហើយបាន « ទៅជាប្រញាប់ » រកព្រះយេស៊ូវ ។ អ្នកក៏អាចធ្វើដូចនេះផងដែរ ។

( សូមមើល លូកា ២:១៥–១៦ ) ។



ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ



ដោយ ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ



# របៀប អត់ធ្មត់

ការរង់ចាំអាចជាការលំបាក ។ កុមារដឹងថា វាលំបាក ហើយមនុស្សពេញវ័យក៏ដឹងដូច្នោះដែរ ។ យើងរស់នៅក្នុងពិភពលោកមួយ ដែលមានភោជនីយដ្ឋានលក់អាហារលឿនទាន់ចិត្ត ការផ្ញើសារបន្ទាន់ ខ្សែភាពយន្តដែលអាចរើសបានតាមចិត្ត និង ឆ្លើយតបភ្លាមៗលើសំណួរជ្រៅៗ ឬ សំណួររាក់កំផែល ។ យើងមិនចូលចិត្តរង់ចាំនោះទេ ។ មានអ្នកខ្លះមានអារម្មណ៍ថា សម្ពាធឈាមរបស់ពួកគេបានឡើង នៅពេលពួកគេឈរតម្រង់ជួរទិញអីវ៉ាន់នៅហាងលក់គ្រឿងទេស ដោយរំកិលទៅមុខយឺតជាងអ្នកដែលនៅជុំវិញពួកគេ ។

ភាពអត់ធ្មត់—ជាលទ្ធភាពដើម្បីដាក់ចំណង់របស់យើងឲ្យនៅស្ងៀមក្នុងរយៈពេលមួយ—គឺជាគុណធម៌ដ៏មានតម្លៃ និង កម្ររកបាន ។ យើងចង់បានអ្វីដែលយើងចង់បាន ហើយយើងចង់បានវាឥឡូវនេះ ។ ហេតុដូច្នោះហើយ គំនិតនៃភាពអត់ធ្មត់នោះឯង ដែលវាហាក់ដូចជាមិនទទួលបានការពេញចិត្ត ហើយមានរសជាតិល្វីងជូរចត់ ។

យ៉ាងណាក្ដី គ្មានការអត់ធ្មត់ យើងមិនអាចធ្វើឲ្យព្រះសព្វព្រះហឫទ័យឡើយ យើងមិនអាចទទួលបានភាពគ្រប់លក្ខណ៍ឡើយ ។ ប្រាដកណាស់ការអត់ធ្មត់ គឺជារបៀបធ្វើឱ្យមានបរិសុទ្ធភាព ដែលដុសខាតឲ្យមានការយល់ដឹង បង្កើនសុភមង្គល ផ្ដោតលើទង្វើ ហើយនិងផ្ដល់សេចក្ដីសង្ឃឹមសម្រាប់ភាពសុខសាន្ត ។

ភាពអត់ធ្មត់មិនមែនគ្រាន់តែជាការរង់ចាំនោះទេ។ ការអត់ធ្មត់ពុំមែនជាការចាំរងតែអំពើ ឬក៏ពុំមែនជាការពុំធ្វើអ្វីសោះ ដោយសារតែការភ័យខ្លាចរបស់យើងនោះឡើយ ។ ការអត់ធ្មត់មានន័យថាជា ការរង់ចាំ និង ការកាន់ខ្ជាប់យ៉ាងសកម្ម ។ វាមានន័យថា ទ្រាំទ្រនឹងអ្វីមួយ ហើយធ្វើឲ្យអស់ពីសមត្ថភាព—ដោយខិតខំសង្ឃឹម ហើយអនុវត្តសេចក្ដីជំនឿ ទទួលបន្ទុកដោយអត់ធន់ ទោះជាបំណងក្នុងចិត្តយើងត្រូវបានពន្យារពេលក៏ដោយ ។ ការអត់ធ្មត់ពុំគ្រាន់ តែជាការប្រកាន់ខ្ជាប់ដោយធម្មតានោះទេ វាគឺជា ការប្រកាន់ខ្ជាប់បានយ៉ាងល្អ ! ការអត់ធ្មត់មានន័យថា បន្តស៊ូទ្រាំជាមួយអ្វីមួយ រហូតដល់ទីបញ្ចប់ ។ វាមានន័យថាជាការពន្យារនូវការចង់បានភ្លាមៗ ដើម្បីបានពរជ័យនាពេលអនាគត ។ វាមានន័យថាជាការទប់កំហឹង និង មិនពោលពាក្យអសុរស ។ វាមានន័យថាជាការតទល់នឹងសេចក្ដីអាក្រក់ ទោះបីវាទំនងមើលទៅដូចជាល្អក្ដី ។

ការអត់ធ្មត់មានន័យថា ការទទួលយកអ្វីដែលពុំអាចផ្លាស់ប្ដូរបាន ហើយប្រឈមមុខនឹងវាដោយចិត្តក្លាហាន ព្រះគុណ និងសេចក្ដីជំនឿ ។ វាមានន័យថា « ព្រមទទួលនូវអ្វីៗទាំងអស់ ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អចំពោះ [ យើង ] ដូចជាកូនក្មេងព្រមធ្វើតាមឪពុកខ្លួនដូច្នោះ » (ម៉ូសាយ ៣:១៩) ។ នៅទីបញ្ចប់ ការអត់ធ្មត់មានន័យថា « រឹងប៉ឹង និង ខ្ជាប់ខ្ជួន ហើយឥតបែរចេញក្នុងការកាន់តាមបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ » ( នីហ្វៃទី ១ ២:១០ ) រៀងរាល់ពេល រៀងរាល់ថ្ងៃ ទោះជាវាលំបាកក្នុងការធ្វើយ៉ាងណាក៏ដោយ ។

កិច្ចការនៃការអត់ធ្មត់គឺមានន័យខ្លឹមសារជាកិច្ចការទាំងអស់នេះថា ៖ រក្សាព្រះបញ្ញត្តិ ទុកចិត្តលើព្រះជាព្រះវរបិតាសួគ៌របស់យើង បម្រើទ្រង់ដោយភាពទន់ភ្លន់ និងដោយសេចក្ដីស្រឡាញ់ដូចជាព្រះគ្រីស្ទ អនុវត្តសេចក្ដីជំនឿ និង សង្ឃឹមលើព្រះអង្គសង្គ្រោះ ហើយសូមកុំចុះចាញ់ឡើយ ។ មេរៀនដែលយើងរៀនពីសេចក្ដីអត់ធ្មត់នឹងបណ្ដុះបុគ្គលិកលក្ខណៈរបស់យើង លើកស្ទួយជីវិតយើងឡើង ហើយលើកកម្ពស់សុភមង្គលរបស់យើង ។ វានឹងជួយយើងឲ្យប្រែក្លាយជាសិស្សស្មោះត្រង់របស់លោកចៅហ្វាយយើងគឺព្រះយេស៊ូវគ្រីស្ទ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០១០ ។*

# បុណ្យគ្រីស្ទម៉ាស់ដ៏ប្លែកមួយ

*វាមានការលំបាកណាស់ដែលពុំឃើញម៉ាក់ ប៉ុន្តែបុណ្យគ្រីស្ទម៉ាស់នៅតែសប្បាយ ។*

« *ចូរចាំពីទ្រង់ នៅពេលអ្នកស្រមៃពីបុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៥០ ភាសាអង់គ្លេស* ) ។

វាជិតដល់បុណ្យគ្រីស្ទម៉ាស់ហើយ ប៉ុន្តែ ឪអាហ្គោគ្មានចិត្តរំភើបអ្វីឡើយ ។ នេះគឺជាបុណ្យគ្រីស្ទម៉ាស់ឆ្នាំដំបូង ចាប់តាំងពីឪពុកម្ដាយរបស់គាត់បានលែងលះគ្នាមក ។ ហើយគាត់គ្មានអារម្មណ៍ដូចមុនទេ ។ គាត់ និង ប្អូនប្រុសគាត់សាំយូអែល នឹងមិនឃើញម៉ាក់ទៀតឡើយនៅបុណ្យគ្រីស្ទម៉ាក់នេះ ។

ឪអាហ្គោបាននិយាយទៅប៉ាថា « អ្វីៗគ្រប់យ៉ាងវាផ្លាស់ប្ដូរហើយ » ។

« ប៉ាដឹង » ។ ប៉ាមានទឹកមុខសោកសៅ ។ « ជួលកាលរឿងរ៉ាវនានាផ្លាស់ប្ដូរមុនវាបានប្រសើរឡើង » ។ គាត់ស្ងាត់មួយសន្ទុះ ហើយបានញញឹម ។ « បុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ *នឹង* ប្លែក ប៉ុន្តែពុំមែនមានន័យថាយើងពុំអាចសប្បាយរីករាយនោះទេ ។ យើងនៅតែអាចប្រារព្ធពិធីប្រសូតរបស់ព្រះអង្គសង្គ្រោះបាន » ។

ឪអាហ្គោបានងក់ក្បាល ។ វាមានការលំបាកណាស់ដែលពុំឃើញម៉ាក់ ប៉ុន្តែបុណ្យគ្រីស្ទម៉ាស់ *អាច* នៅតែសប្បាយដូចប៉ាទើបបាននិយាយ ។ ឪអាហ្គោចង់ធ្វើឲ្យបុណ្យគ្រីស្ទម៉ាស់នេះជាគ្រាមួយដ៏រីករាយ ។

គាត់បានទៅបន្ទប់របស់គាត់ដើម្បីគិតពីរឿងនោះ ។ ជួនកាលពេលបុណ្យគ្រីស្ទម៉ាស់ ពួកគេធ្វើការបម្រើជាគ្រួសារ ។ តើឆ្នាំនេះពួកគេនឹងធ្វើអ្វី ?

ឪអាហ្គោ បានមើលជុំវិញបន្ទប់របស់ខ្លួន ។ គាត់បានឃើញឡានជ័រមួយដែលគាត់ឈប់លេងវា ។ គាត់បានរើសវាឡើង ហើយបង្វិលកង់ឡាននោះ ។ ឡាននោះពុំទាន់ខូចនៅឡើយទេ ។ ប្រហែលជាគាត់ និង ប៉ា ព្រមទាំងសាំយូអែល អាចឲ្យប្រដាប់ប្រដាក្មេងលេងមួយចំនួនទៅក្មេងៗដែលគ្មានប្រដាប់លេងទាំងនោះ !



រូបភាពដោយ ក្រីស្ទីន ក់ន់

ដោយ ជេន ម៉ាកប្រាយដ៍ ឆូត
ផ្អែកទៅលើដំណើររឿងពិត



គាត់បានរកឃើញប្រដាប់ប្រដាក្មេងលេងមួយចំនួនទៀត ហើយដាក់វានៅក្នុងកាបូបជាមួយនឹងឡានជ័រនោះ ។

នៅពេលឪអាហ្គោបានប្រមូលវាហើយ គាត់បានយកកាបូបនោះទៅបន្ទប់របស់សាំយូអែល ។ គាត់បានសួរថា « តើបងអាចជួយសម្អាតបន្ទប់ប្អូនបានទេ ? វានឹងធ្វើឲ្យប៉ាមានការភ្ញាក់ផ្អើល » ។

សាំយូអែលបានងាកចេញពីរូបភាពដែលគាត់កំពុងគូរ ។ « បាទបាន » ។

ក្មេងប្រុសទាំងពីរបានធ្វើការរួមគ្នាសម្អាតបន្ទប់របស់សាំយូអែល ។ ឪអាហ្គោបានប្រាប់គាត់អំពីផែនការនោះ ។ ពួកគេបានរកឃើញប្រដាប់ប្រដាក្មេងលេងមួយចំនួន ដែលសាំយូអែលឈប់លេងវា ហើយដាក់វាបន្ថែមចូលទៅក្នុងកាបូប ។

ពេលពួកគេបានសម្អាតចប់ហើយ នោះពួកគេបានយួរកាបូបចុះមកជាន់ក្រោម ។ ឪអាហ្គោបាននិយាយថា « ប៉ា ពួកកូនមានប្រដាប់ប្រដាក្មេងលេងមួយចំនួន ដែលពួកកូនឈប់លេងវាទៀតហើយ ។ តើពួកកូនអាចឲ្យវាទៅក្មេងៗដែលគ្មានប្រដាប់ប្រដាលេងទាំងនេះបានទេ ? »

ប៉ាបានមើលដោយក្ដីរំភើប ហើយរីករាយ ។ « នោះជាយោបល់ល្អណាស់ ! ចូរយើងយកវាទៅមជ្ឈមណ្ឌលដែលមើលថែអ្នកដែលគ្មានផ្ទះនារសៀលនេះ » ។

ការទៅលេងមជ្ឈមណ្ឌលនោះសប្បាយណាស់ ។ ឪអាហ្គោ និង សាំយូអែលលេងជាមួយក្មេងៗទាំងនោះ ពេលប៉ាបាននិយាយជាមួយមនុស្សពេញវ័យ ។

នៅតាមផ្លូវទៅផ្ទះវិញ ប៉ាបានសួរថាតើមានអ្វីខ្លះទៀតដែលពួកគេអាចធ្វើដើម្បីឲ្យបុណ្យគ្រីស្ទម៉ាស់នេះពិសេសនោះ ។

ឪអាហ្គោបាននិយាយថា « កាលពីបុណ្យគ្រីស្ទម៉ាស់ឆ្នាំមុនយើងបានធ្វើនំឲ្យអ្នកជិតខាងយើង » ។

ប៉ាបាននិយាយថា « យើងអាចធ្វើវាបាន ។ តោះយើងទៅទិញគ្រឿងមកធ្វើនំយុកឃី » ។

សាំយូអែលបានគិតថា ធ្វើនំយុកឃីជាយោបល់ *ដ៏ល្អ* មួយ ។

កូនប្រុសទាំងពីរនាក់បានជួយប៉ាទិញគ្រឿងផ្សំនៅហាងទំនិញ ។ នៅផ្ទះ ពួកគេបានលាយម្សៅ ហើយកាត់វាជារាងរូបផ្កាយ និង រូបដើមឈើ ។ ឪអាហ្គោ និង សាំយូអែលបានដាក់ក្រែមនំយុកឃីជាពណ៌លឿង និង ពណ៌បៃតង ។ ក្រោយមកពួកគេបានយកថង់នំយុកឃីទាំងនោះទៅឲ្យអ្នកជិតខាងរបស់ពួកគេ ។

នៅយប់នោះ ឪអាហ្គោអស់កម្លាំង ប៉ុន្តែមានចិត្តរីករាយ ។ គាត់ និង សាំយូអែល ព្រមទាំងប៉ាបានធ្វើកិច្ចការល្អៗជាមួយគ្នាជាគ្រួសារ ហើយបានជួយមនុស្សដទៃ ។ ប៉ាមានប្រសាសន៍ត្រូវណាស់ ។ បុណ្យគ្រីស្ទម៉ាស់នេះប្លែកពីមុន ប៉ុន្តែវានៅតែសប្បាយ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស.រ.អា. ។*



**ការធ្វើជាគំរូ**
ប៉ារបស់ខ្ញុំពុំទៅព្រះវិហារ ប៉ុន្តែខ្ញុំព្យាយាមគោរពបទបញ្ញត្តិនៅពេលខ្ញុំនៅផ្ទះរបស់គាត់តាមរយៈគំរូរបស់ខ្ញុំ អំពីរបៀបដែលខ្ញុំរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។
**ដាស្សែល ភី អាយុ ៦ ឆ្នាំ រដ្ឋ ខូឡូរ៉ាដូ ស.រ.អា.**

កុមារដែលឈរវឹងប៉ឹង

# ពរជ័យ មកពី ប្លេះស៊ី

ជំរាបសួរ ! ខ្ញុំឈ្មោះ ប្លេះស៊ី ។

ខ្ញុំរស់នៅប្រទេសឥណ្ឌាជាមួយគ្រួសារខ្ញុំ ។ ខ្ញុំត្រូវដាក់ផែនការសកម្មភាពពិសេសមួយ សម្រាប់សាលារៀនរបស់ខ្ញុំ ហើយចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់ខ្ញុំ !

១

**អ្នកផ្សព្វផ្សាយសាសនាវ័យក្មេង**

*អ្នកដឹកនាំថ្នាក់បឋមសិក្សារបស់ខ្ញុំ បង្រៀនថាយើងគួរធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ជួនកាលខ្ញុំអញ្ជើញមិត្តភក្តិរបស់ខ្ញុំឲ្យទៅព្រះវិហារ ។ ភាគច្រើនពួកគេបដិសេធខ្ញុំ ។ ខ្ញុំគិតថាប្រហែលជាខ្ញុំនៅក្មេងពេកដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។*



២

**ការអញ្ជើញជាគ្រួសារ**

*ក្រោយមក នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ប៉ាបានសំណូមពរដល់គ្រួសាររបស់យើងឲ្យនាំមនុស្សម្នាក់មកព្រះវិហាររៀងរាល់ខែ ។ ខ្ញុំចង់ធ្វើវា ប៉ុន្តែវាពិបាកណាស់ ! ខ្ញុំបានសូមជំនួយពីប៉ា ។ គាត់បានប្រាប់ថា ឲ្យខ្ញុំអធិស្ឋាន ។ ដូច្នោះខ្ញុំក៏បានអធិស្ឋាន ។*





## ៣

### យោបល់

*ថ្ងៃស្អែកឡើងនៅឯសាលារៀន នាយកសាលាបានសួរយោបល់សម្រាប់សកម្មភាពបុណ្យគ្រីស្ទម៉ាស់នៅសាលា ។ ខ្ញុំមានគំនិតអស្ចារ្យមួយ ! ខ្ញុំបានប្រាប់គាត់ថា កុមារនៅក្នុងថ្នាក់បឋមសិក្សាទាំងអស់អាចមកលេងព្រះវិហាររបស់ខ្ញុំ ។ គាត់បានទូរសព្ទទៅឪពុកម្ដាយរបស់ខ្ញុំ ហើយពួកគាត់បាននិយាយជាមួយប៊ីស្សពដើម្បីដាក់ផែនការពីសកម្មភាពនោះ ។ ពួកអ្នកដឹកនាំថ្នាក់អង្គការបឋមសិក្សា និង អ្នកផ្សព្វផ្សាយសាសនាបានជួយកិច្ចការនោះផងដែរ ។*



## ៤

### ថ្ងៃដ៏រំភើប

*មិនយូរប៉ុន្មានថ្ងៃនោះបានមកដល់ ។ ខ្ញុំមានអារម្មណ៍ភិតភ័យ និង រំភើបក្នុងពេលជាមួយគ្នា ។ នៅពេលប៉ាបានយកខ្ញុំទៅសាលារៀន ខ្ញុំបានឃើញពួកគេនៅទីនោះ ហើយត្រៀមខ្លួនរួចជាស្រេច ។ មានសិស្ស និង គ្រូបង្រៀនជិត ៥០០ នាក់បានមក !*



## ៥

### ទាំងអស់គ្នានៅព្រះវិហារ

*នៅព្រះវិហារយើងបានមើលវីដេអូមួយអំពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ យុវមជ្ឈិមវ័យ និង អ្នកផ្សព្វផ្សាយសាសនាបានច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ។ ប៊ីស្សព និង ប៉ារបស់ខ្ញុំបាននិយាយអំពីរបៀបដែលព្រះយេស៊ូវស្រឡាញ់ក្មេងតូចៗ និង អំពីសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ។ ខ្ញុំបាននិយាយអំពីបុណ្យគ្រីស្ទម៉ាស់ ។ អ្នកទាំងអស់គ្នាមានគ្រាដ៏រីករាយមួយ ! នាយកសាលា និង គ្រូបង្រៀនរបស់ខ្ញុំបានសួរសំណួរនានាដល់អ្នកផ្សព្វផ្សាយសាសនា ។*



### យោបល់របស់ប្លេះស៊ី ដើម្បីឈរយ៉ាងរឹងប៉ឹង

- អធិស្ឋានសូមជំនួយ ។
- អញ្ជើញមនុស្សឲ្យមកព្រះវិហារ ទោះបីអ្នកគិតថាពួកគេបដិសេធអ្នកក៏ដោយ ។
- ចូរចាំថាព្រះវរបិតាសួគ៌នឹងជួយអ្នក ។

# ការអញ្ជើញរបស់មរ៉ូណៃ

បន្ទាប់ពីឪពុករបស់លោកគឺមរមនបានស្លាប់ទៅ មរ៉ូណៃបានសរសេរលើផ្ទាំងមាស ។ គាត់បានសរសេរអំពីបព្វជិតភាព សាក្រាម៉ង់ និង បុណ្យជ្រមុជទឹក ។ គាត់បានអញ្ជើញយើងឲ្យអានព្រះគម្ពីរមរមន ហើយទូលសួរព្រះវរបិតាសួគ៌ ប្រសិនបើវាជាព្រះគម្ពីរពិត ។ ប្រសិនបើយើងអធិស្ឋាន ហើយស្ដាប់រកមើលចម្លើយ នោះព្រះវិញ្ញាណបរិសុទ្ធអាចប្រាប់យើងថាគម្ពីរនេះពិត ។ មរ៉ូណៃបានកប់ផ្ទាំងនោះទុកក្នុងដី ដើម្បីរក្សាទុកវាឲ្យមានសុវត្ថិភាព ។



ខ្ញុំបានអានព្រះគម្ពីរជាមួយប៉ារបស់ខ្ញុំរៀងរាល់ថ្ងៃ ។ ការធ្វើបែបនេះ ជួយឲ្យខ្ញុំទទួលបានទីបន្ទាល់ ។ ខ្ញុំនឹងមិនបោះបង់វាចោលឡើយ !

**ស្ពែនសើរ ភី អាយុ ១០ ឆ្នាំ រដ្ឋ វីស្កុនសិន ស.រ.អា.**




*« ផ្ទាំងមាស » ដេកុប ឌី អាយុ ១១ ឆ្នាំ ណូវ៉ា ស្កុធៀ ប្រទេសកាណាដា*

ខាងក្រោមខាងឆ្វេង ៖ រចនារូបភាព ដោយ យ៉ារ៉េឌ បេកស្ទ្រែន

កាត់ បត់ ហើយរក្សាកាតប្ដេជ្ញាចិត្តនេះ !




## ខ្ញុំអាចទទួលយកការអញ្ជើញនោះ !

- ☐ ទន្ទេញ មរ៉ូណៃ ១០:៥ ។
- ☐ ធ្វើតាមការអញ្ជើញរបស់មរ៉ូណៃ ! អធិស្ឋានទូលសូមព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយអ្នកឲ្យដឹងថា ព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត ។
- ☐ សូមមើលគេហទំព័រ scripturestories.lds.org ដើម្បីមើលវីដេអូ ៥៣–៥៤ នៃរឿងក្នុងព្រះគម្ពីរមរមន ។
- ☐ ខ្ញុំប្ដេជ្ញាចិត្តខ្លួនខ្ញុំដើម្បី . . .

______________________________

## បទគម្ពីរសម្រាប់ខែនេះ

បន្ទាប់ពីអ្នកអានវគ្គបទគម្ពីរមួយហើយ សូមផាត់ពណ៌លើផ្នែកមានចុះលេខដែលត្រូវគ្នាលើរឿងព្រះប្រសូត្រកម្ម !

១ នីហ្វៃទី ១ ១១:១៤-២៨

២ នីហ្វៃទី ២ ១៩:៦

៣ ម៉ូសាយ ១៥:១-៤

៤ អាលម៉ា ៥:៤៨

៥ នីហ្វៃទី ៣ ៩:១៥

៦ ម៉ាថាយ ១:១៩-២៥

៧ ម៉ាថាយ ២:៧-១១

៨ លូកា ១:២៧-៣១




រូបភាពដកស្រង់មកពី *ព្យុការីអេសាយព្យាករពីការប្រសូតរបស់ព្រះគ្រីស្ទ* ដោយ ហារី អែលឌើរសុន ទេទ្បូរ; រូបភាពដោយ ម៉ាគេ ប៊ើកស្ទើ



## ចូរស្រមៃពីក្រោលសត្វ

នៅពេលម៉ារា និង យ៉ូសែបបានធ្វើដំណើរទៅបេថ្លេហិម មានកន្លែងតែមួយប៉ុណ្ណោះដែលពួកគាត់អាចស្នាក់នៅបានគឺក្រោលសត្វ ។ ព្រះយេស៊ូវគ្រីស្ទបានប្រសូតនៅក្នុងក្រោលសត្វនោះ ហើយបានដាក់នៅក្នុងស្នូក ។ ពួកអ្នកគង្វាល និង ពួកហោរាបានដើរតាមផ្កាយមួយទៅរកព្រះយេស៊ូវ ។ ពួកសាសន៍នីហ្វៃក៏បានឃើញផ្កាយនេះដែរ ហើយបានដឹងថាព្រះយេស៊ូវបានប្រសូត្រហើយ ។ យើងប្រារព្ធពិធីបុណ្យគ្រីស្ទម៉ាស់ ដើម្បីចងចាំពីការប្រសូតរបស់ទ្រង់ ។ ■

ចម្លើយមកពីសាវក



# តើខ្ញុំអាចមានអារម្មណ៍កាន់តែខិតជិតព្រះអង្គសង្គ្រោះតាមរបៀបណា ?

ដោយ អែលឌើរ ឌេល ជី រេនឡាន់
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់




ដកស្រង់ចេញពី « *That I Might Draw All Men unto Me* » Liahona *ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ៣៩-៤២ ។*

# ប័ណ្ណសាក្សីពិសេស

សូមប្រើប័ណ្ណទាំងនេះដើម្បីរៀនបន្ថែមទៀតអំពីសមាជិកក្នុងគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អ្នកអាចថតចម្លងប័ណ្ណនេះ ហើយបង្កើតល្បែងផ្គូផ្គង ។ អ្នកអាចបោះពុម្ពជាច្រើនច្បាប់ទៀតតាមរយៈ គេហទំព័រ **liahona.lds.org.** ។



### ប្រធាន រ័សុល អិម ណិលសុន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ជាវេជ្ជបណ្ឌិតវះកាត់បេះដូង
- បានធ្វើជាវេជ្ជបណ្ឌិតនៅក្នុងកងទ័ពសហរដ្ឋក្នុងប្រទេស កូរ៉េ និង ជប៉ុន
- មានកូន ១០ នាក់—ស្រី៩នាក់ និង ប្រុសម្នាក់

### ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ
*ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ*

- រត់គៀសខ្លួនជាមួយគ្រួសារទៅប្រទេស អាល្លឺម៉ង់ភាគខាងលិច ជាជនភៀសខ្លួនដោយសារសង្គ្រាម
- ជាអ្នកបើកយន្តហោះ
- ចូលចិត្តលេងជិះស្គីជាមួយកូន និង ចៅៗរបស់លោក

### ប្រធាន ហិនរី ប៊ី អាវិង
*ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ*

- បានលេងកីឡាបាល់បោះនៅវិទ្យាល័យ
- បានរៀនរូបវិទ្យាពីឪពុករបស់លោកនៅលើក្ដារខៀនបន្ទប់ក្រោមដីរបស់ពួកគាត់
- ធ្វើជាប្រធានមហាវិទ្យាល័យ រីក ឥឡូវនេះជាប្រធានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–អៃដាហូ

### ប្រធាន ថូម៉ាស អេស ម៉នសុន
*ប្រធានទី ១៦ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*

- ត្រូវបានហៅបម្រើការពីអាយុ ២២ ឆ្នាំដើម្បីបម្រើជាប៊ីស្សពនៅក្នុងវួដមួយ ដែលមានស្ត្រីមេម៉ាយជាច្រើន
- បានធ្វើការនៅក្នុងកន្លែងបោះពុម្ព និង រោងពុម្ពកាសែត
- ជាប្រធានបេសកកម្មក្នុងប្រទេសកាណាដា

### អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- គឺជាដៃគូបេសកកម្មជាមួយអែលឌើរយុក នៅក្នុងប្រទេសអង់គ្លេស
- បម្រើការឲ្យប្រព័ន្ធអប់រំសាសនាចក្រ
- ធ្លាប់ធ្វើជាប្រធានសាកលវិទ្យាល័យព្រិកហាំ យ៉ង់

### អែលឌើរ រ៉ូប៊ឺត ឌី ហែល
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានចម្រើនវ័យធំឡើងនៅទីក្រុងនូវ យ៉ោក ស.រ.អា.
- បានធ្វើជាអ្នកបោះបាល់ឲ្យក្រុមបាល់ឱបរបស់សាលារបស់លោក
- ជាអ្នកបើកយន្តហោះចំបាំងនៅក្នុងកងទ័ពអាកាសសហរដ្ឋ

### អែលឌើរ អិម រ័សុល បាឡឺដ
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ត្រូវបានគេដាក់ងារថា ជា « លោកប៊ីស្សព » នៅក្នុងមហាវិទ្យាល័យដោយព្រោះបទដ្ឋានដ៏ខ្ពស់របស់លោក
- បានបើកហាងលក់ឡាន
- លើកទឹកចិត្តសមាជិកឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនា

### អែលឌើរ ដាល្លិន អេក អូក
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានសម្អាតហាងជុសជុលវិទ្យុដែលជាមុខរបរមុនគេបង្អស់
- ជាមេធាវី និង ចៅក្រមកំពូលនៅរដ្ឋ យូថាហ៍
- ធ្លាប់ធ្វើជាប្រធានសាកលវិទ្យាល័យព្រិកហាំ យ៉ង់















ដើម្បីអានរឿងបន្ថែម
ទៀតអំពីព្យាការី និង
សាវក សូមមើល
គេហទំព័រ

**lds.org/**
**prophets-and**
**-apostles/what-are**
**-prophets**

## អែលឌើរ នែល អិល អាន់ឌើរសិន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានចម្រើនវ័យធំឡើងនៅក្នុងកសិដ្ឋានចិញ្ចឹមគោក្នុងរដ្ឋអៃដាហូ ស.រ.អា.
- បានបម្រើជាអ្នកផ្សព្វផ្សាយសាសនា និងជាប្រធានបេសកកម្មក្នុងប្រទេសបារាំង ។
- បានជួយដឹកនាំការដាក់ឲ្យប្រើប្រាស់គេហទំព័រ Mormon.org

## អែលឌើរ ឌី ថត គ្រីស្តូហ្វើសិន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានធ្វើនំប៉័ងសម្រាប់គ្រួសារខ្លួននៅពេលលោកធំពេញវ័យ
- បានចូលរួមការសម្ដែងនៅក្នុងកម្មវិធីកូនក្មេង គូម៉ូវ៉ាកាលនៅវ័យជំទង់
- បានបម្រើបេសកកម្មក្នុងប្រទេសអាហ្សង់ទីនដែលអែលឌើរស្កុតជាប្រធានបេសកកម្មរបស់លោក

## អែលឌើរ ឃ្វីនថិន អិល ឃុក
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានទទួលទីបន្ទាល់មួយអំពីការអធិស្ឋានជាមួយបងប្រុសរបស់លោក
- ធ្លាប់គឺជាប្រធានក្រុមសិស្សនៅអនុវិទ្យាល័យ ជាមួយអនាគតភរិយារបស់លោកឈ្មោះ ម៉ារី ជាអនុប្រធាន
- ធ្លាប់ធ្វើជាថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងប្រទេស ហ្វីលីពីន និងប៉ាសុីហ្វិក

## អែលឌើរ ដេវីឌ អេ បែដណា
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- គឺជាខ្សែប្រយុទ្ធនៅក្នុងក្រុមកីឡាបាល់ឱបនៅវិទ្យាល័យរបស់លោក
- បន្ទាប់ពីបម្រើបេសកកម្មរួចបានធ្វើបុណ្យជ្រមុជទឹកឲ្យឪពុកលោកដើម្បីក្លាយជាសមាជិកសាសនាចក្រ
- ធ្វើជាប្រធានមហាវិទ្យាល័យ រីកឥឡូវនេះជាប្រធានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–អៃដាហូ

## អែលឌើរ ឌេល ជី រេនឡាន់
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ឈ្មោះកណ្ដាលរបស់លោកគឺ ហ្គាន់នើរ មានន័យថា « ទាហានដ៏អង់អាច »
- ប្ដូរទៅរស់នៅប្រទេសស៊ុយអែតកាលនៅវ័យជំទង់
- បម្រើការជាវេជ្ជបណ្ឌិតផ្នែកបេះដូង

## អែលឌើរ ហ្គែរី អ៊ី ស្ទីវិនសុន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បម្រើជាអ្នកផ្សព្វផ្សាយសាសនា និងជាប្រធានបេសកកម្មក្នុងប្រទេសជប៉ុន
- ចាប់ផ្ដើមធ្វើជំនួញផលិតឧបករណ៍ហាត់ប្រាណ
- បម្រើជាប៊ីស្សពលើសាសនាចក្រទាំងមូល

## អែលឌើ រ៉ូណាល អេ រ៉ាសបាន
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ធ្វើជាប្រធានបេសកកម្មនៅក្នុងទីក្រុង នូវ យ៉ោក
- មានបាវចនាថា « មានតែមនុស្សទេដែលសំខាន់បំផុត »
- ឧទ្ទិសឆ្លងអគារសាសនាចក្រ អិល. ឌី. អេស.ដំបូងគេនៅក្នុងសាធារណរដ្ឋឆែក

# ទំព័ររបស់យើង



ដោយ ដានីយ៉ែលឡា អិម អាយុ ៩ ឆ្នាំ ទីក្រុង ខតធេស ប្រទេសហុងឌូរ៉ាស




« ព្រះអង្គមួយអង្គបានប្រសូត » ដោយ ស៊ូហ្វីយ៉ា អិម អាយុ ៧ ឆ្នាំ ទីក្រុង ខតធេស ប្រទេសហុងឌូរ៉ាស



ដោយ លូហាន ប៊ី អាយុ ៩ ឆ្នាំ ទីក្រុង សៅ ប៉ូឡូ ប្រទេសប្រេស៊ីល



*រៀងរាល់ថ្ងៃ ប៉ោឡាស្ដាប់បទចម្រៀងថ្នាក់អង្គការបឋមសិក្សាតាមរយៈស៊ីឌី ហើយបានរៀនចេះចម្រៀងមួយចំនួន ។ នាងពិតជាចូលចិត្តបទ « ធ្វើតាមព្យាការី » ។ នាងក៏ចូលចិត្តអាន រឿងក្នុងព្រះគម្ពីរមរមន ជាមួយម្ដាយនាងផងដែរ ។ ថ្មីៗនេះនាងបានទៅសួរសុខទុក្ខសាច់ញាតិមួយចំនួនរបស់នាង ហើយបានប្រាប់ពួកគេអំពីរឿងរបស់អាំម៉ូន និង ពួកសាសន៍លេមិន ។*

ប៉ោឡា ស៊ី អាយុ ៣ ឆ្នាំ អូសាកា ប្រទេស ម៉ិកស៊ីកូ



កុមារថ្នាក់អង្គការបឋមសិក្សានៅក្នុងទីក្រុងរ៉ូមប្រទេសអ៊ីតាលី បានធ្វើដើមគ្រីស្ទម៉ាស់ដោយដៃជំនួយរបស់ពួកគេ ។

# ការសន្យាដ៏ពិសេសរបស់មរ៉ូណៃ



មរមនមានកូនប្រុសម្នាក់ឈ្មោះ មរ៉ូណៃ ។ បន្ទាប់ពីមរមនបានស្លាប់ទៅ មរ៉ូណៃបានសរសេរលើផ្ទាំងមាស ។



មរ៉ូណៃបានសរសេរអំពីការអធិស្ឋានប្រសិទ្ធពរសាក្រាម៉ង់ ។ លោកបានសរសេរថា អ្វីៗទាំងអស់ដែលល្អគឺមកពីព្រះ ។

រចនារូបភាពដោយ អាបឺល ស្តុត



ម៉ូរ៉ូណៃបានសរសេរថា ព្រះយេស៊ូវស្រឡាញ់កុមារទាំងអស់ ។ លោកមានប្រសាសន៍ថា យើងអាចអធិស្ឋានដើម្បីមានសេចក្ដីស្រឡាញ់ក្នុងដួងចិត្តយើង ។



ម៉ូរ៉ូណៃបានធ្វើការសន្យាដ៏ពិសេសមួយ ។ លោកបានសរសេរថា ប្រសិនបើយើងអានព្រះគម្ពីរមរមន ហើយទូលសួរដល់ព្រះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងប្រាប់យើងថាគម្ពីរនេះពិត ។ ក្រោយមកម៉ូរ៉ូណៃបានកប់ផ្ទាំងនោះទុកក្នុងភ្នំគូម៉ូរ៉ា ដើម្បីរក្សាទុកវាឲ្យមានសុវត្ថិភាព ។



ច្រើនឆ្នាំក្រោយមក ម៉ូរ៉ូណៃបានមកកាន់ផែនដីវិញក្នុងសភាពជាទេវតា ។ ទេវតាម៉ូរ៉ូណៃបានបង្ហាញយ៉ូសែប ស្ម៊ីធ នូវកន្លែងដែលបានកប់ផ្ទាំងមាសនោះ ។ ព្រះបានប្រទានពរដល់យ៉ូសែបនូវព្រះចេស្ដា ដើម្បីបកប្រែពាក្យនៅលើផ្ទាំងនោះ ។ សព្វថ្ងៃនេះយើងអាចអានពាក្យរបស់ម៉ូរ៉ូណៃនៅក្នុងព្រះគម្ពីរមរមនបាន ! ■

# ខ្ញុំស្រឡាញ់គ្រួសារខ្ញុំ



រចនារូបភាពដោយ អាបរីល ស្តុត



ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# និស្ស័យដ៏ពិតនៃព្រះ

*ព្រះយេស៊ូវគ្រីស្ទគឺជាភស្តុតាងដ៏ល្អឥតខ្ចោះនៃការខ្វល់ខ្វាយដ៏ខ្លាំងក្លារបស់ព្រះវរបិតា ។*

បន្ទាប់ពីព្យាការីជាច្រើនជំនាន់បានព្យាយាមបង្រៀនគ្រួសារនៃមនុស្សលោកពីព្រះឆន្ទៈ និង របៀបរបស់ព្រះវរបិតា ដែលតែងតែមានជោគជ័យតិចតួច នោះនៅក្នុងកិច្ចខិតខំដ៏ខ្ពង់ខ្ពស់របស់ទ្រង់ ព្រះបានឲ្យយើងស្គាល់ទ្រង់ ហើយបានបញ្ជូនព្រះរាជបុត្រាបង្កើតតែមួយ និង ឥតខ្ចោះរបស់ទ្រង់ ដែលបានបង្កើតឡើងដូច និង មានរូបកាយដូចទ្រង់ ដើម្បីរស់នៅ ហើយបម្រើនៅក្នុងជីវិតរមែងស្លាប់ដ៏លំបាករៀងរាល់ថ្ងៃនេះ ។

ដោយយាងមកលើផែនដីជាមួយនឹងការទទួលខុសត្រូវបែបនេះ ដើម្បីឈរជំនួសឲ្យអេឡូហីម—មានបន្ទូលដូចដែលទ្រង់មានបន្ទូល ជំនុំជម្រះ និងបម្រើ ស្រឡាញ់ ហើយព្រមាន អត់ធ្មត់ ព្រមទាំងអភ័យទោសដូចដែលទ្រង់នឹងធ្វើ—នេះគឺជាកាតព្វកិច្ចដ៏មហិមា ដែលអ្នក និង ខ្ញុំពុំអាចយល់នូវរឿងបែបនេះបានទេ ។ ប៉ុន្តែនៅក្នុងភាពស្មោះត្រង់ និង ការប្ដេជ្ញាចិត្តដែលជាបុគ្គលិកលក្ខណៈនៃកូនរបស់ព្រះ នោះព្រះយេស៊ូវអាចយល់ពីវា ហើយទ្រង់បានធ្វើវា ។ នៅពេលការកោតសរសើរ និង កិត្តិយសបានចាប់ផ្ដើមកើតឡើង នោះទ្រង់បានដឹកនាំការកោតសរសើរទាំងអស់ដោយរាបសាទៅកាន់ព្រះវរបិតា ។

ទ្រង់មានបន្ទូលដោយស្មោះអំពីព្រះទ័យថា « ព្រះវរបិតា . . . ធ្វើកិច្ចការនេះ » ។ « ព្រះរាជបុត្រាពុំអាចនឹងធ្វើការអ្វីដោយព្រះអង្គទ្រង់បានទេ ធ្វើបានតែការអ្វីដែលឃើញព្រះវរបិតាធ្វើ ដ្បិតការណ៍អ្វីក៏ដោយដែល [ ព្រះវរបិតា ] ធ្វើ នោះព្រះរាជបុត្រាក៏ធ្វើ



ដូច្នោះដែរ » [ យ៉ូហាន ១៤:១០; យ៉ូហាន ៥:១៩ ] ។ មានគ្រាមួយនោះទ្រង់បានមានបន្ទូលដូចនេះ ៖ « ឯខ្ញុំៗនិយាយតែសេចក្ដីណាដែលខ្ញុំបានឃើញ នៅឯព្រះវរបិតាខ្ញុំ » [ យ៉ូហាន ៨:៣៨ ] ។ . . .

. . . មនុស្សមួយចំនួននៅក្នុងសម័យជាមួយគ្នានេះរងទុក្ខមកពីការអន់ចិត្តនឹងការភាន់ច្រឡំអំពី [ ព្រះជាព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង ] ។ ក្នុងចំណោមការយល់ច្រឡំទាំងនោះមានទំនោរមួយដែលមានអារម្មណ៍នៅឆ្ងាយពីព្រះវរបិតា គឺធ្វើឲ្យលែងមានទំនាក់ទំនងជាមួយទ្រង់ ប្រសិនបើពួកគេជឿលើទ្រង់នោះ ។ . . . តាមរយៈការអានដោយយល់ខុសនេះ ( ហើយប្រាកដណាស់ ក្នុងករណីមួយចំនួនគឺដោយការបកប្រែខុស ) របស់ព្រះគម្ពីរប៊ីប ទាំងនេះ ហើយដែលនាំឲ្យយល់ឃើញថាព្រះជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់ មានបុគ្គលិកលក្ខណៈផ្សេងគ្នាយ៉ាងខ្លាំង ទោះបីការពិតថា ទាំងព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មីក្ដីបង្រៀនថា ព្រះរាជបុត្រានៃព្រះគឺជាអង្គតែមួយ ហើយដូចគ្នា ធ្វើកិច្ចការនានាដូចដែលទ្រង់តែងតែធ្វើក្រោមការដឹកនាំរបស់ព្រះវរបិតា ដែលព្រះអង្គទ្រង់ផ្ទាល់គឺនៅតែដដែល « ពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ » ។[១] . . .

ដូច្នេះ ការឲ្យអាហារដល់អ្នកស្រេកឃ្លាន ការព្យាបាលអ្នកឈឺ ការវាយផ្ចាលដល់មនុស្សលាក់ពុត ការទូលអង្វរសុំសេចក្ដីជំនឿ—គឺជារបៀបដែលព្រះគ្រីស្ទបានបង្ហាញយើងពីមាគ៌ានៃព្រះវរបិតាទ្រង់ ដែលជាអង្គ « ប្រកបដោយក្ដីមេត្តាករុណា និង ព្រះគុណ កម្រនឹងព្រះពិរោធ អត់ធ្មត់ និងពោរពេញដោយសេចក្ដីល្អ » ។[២] នៅក្នុងជីវិតរបស់ទ្រង់ និង ជាពិសេសនៅក្នុងការសុគតរបស់ទ្រង់ នោះព្រះគ្រីស្ទកំពុងប្រកាសថា « នេះគឺជាសេចក្ដីមេត្តាករុណា *របស់ព្រះ* ដែលយើងកំពុងបង្ហាញដល់អ្នក ព្រមទាំងវាក៏ជាសេចក្ដីមេត្តាករុណារបស់យើងផ្ទាល់ផងដែរ » ។ នៅក្នុងការបង្ហាញដ៏ល្អឥតខ្ចោះរបស់ព្រះរាជបុត្រាអំពីការខ្វល់ខ្វាយដ៏ខ្លាំងក្លារបស់ព្រះវរបិតា នៅក្នុងការរងទុក្ខរួមគ្នារបស់ទ្រង់ ហើយបានចែករំលែកក្ដីទុក្ខព្រួយចំពោះអំពើបាប និង ការខូចចិត្តរបស់ពួកយើងទាំងអស់គ្នា នោះយើងឃើញពីអត្ថន័យដ៏ធំធេងបំផុតនៅក្នុងប្រកាសដូចនេះ ៖ « ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកិយ ដើម្បីនឹងជំនុំជម្រះលោកិយនោះទេគឺ ឲ្យលោកិយបានសង្គ្រោះដោយសារទ្រង់វិញ » [ យ៉ូហាន ៣:១៦–១៧ ] ។ ■

*ដកស្រង់មកពី « The Grandeur of God »* Liahona *ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ៧០–៧៣ ។*

**កំណត់ចំណាំ**
១. ឧទាហរណ៍ នីហ្វៃទី ១ ១០:១៨; នីហ្វៃទី ២ ២៧:២៣; មរ៉ូណៃ ១០:១៩; គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១២ ។
២. *Lectures on Faith* ( ឆ្នាំ ១៩៨៥ ) ទំព័រ ៤២ ។

*ស្ត្រីដែលបានប្រោសឲ្យជា ដោយ ជេ ឃើរ តែង*

# ការយល់ដឹង



**ក្រុមគ្រួសារ ៖ លំនាំសេឡេស្ទាល**

« ក្រុមគ្រួសារមិនគ្រាន់តែជាមធ្យោបាយដើម្បីធ្វើឲ្យអ្វីៗដំណើការទៅដោយរលូនលើផែនដីនេះ និងមិនត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ប៉ុណ្ណោះទេ ។ ផ្ទុយទៅវិញ វាគឺជា របៀប នៃស្ថានសួគ៌ ។ វាគឺជានិមិត្តរូបមួយនៃលំនាំសេឡេស្ទាល ឲ្យបានដូចគ្រួសារអស់កល្បជានិច្ចរបស់ព្រះ » ។

**ប្រធាន ឌៀថើរ អេស្វ អុជដុហ្វ**, ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ, "In Praise of Those Who Save," *Liahona*, ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ៧៧ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

### សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ៖ **គុណធម៌ដែលវេញត្របាញ់ចូលគ្នា**

នៅពេលយើងមិនដាក់សេចក្ដីជំនឿត្រួតលើសេចក្ដីសង្ឃឹម ហើយ សេចក្ដីសង្ឃឹមត្រួតលើសេចក្ដីសប្បុរស ដូចយើងតម្រៀបដុំឥដ្ឋ—នោះ គុណធម៌ដ៏សំខាន់ទាំងនេះត្រូវតែវេញត្របាញ់បញ្ចូលគ្នានៅក្នុងជីវិតរបស់យើង ដើម្បីជួយយើងឲ្យប្រែក្លាយជាអ្នកដើរតាមដ៏ពិតរបស់ព្រះអង្គសង្គ្រោះ ។

ទំព័រ ៤៤



## សម្រាប់យុវវ័យ



### ចូរធ្វើជាវីរបុរសដ៏ ***ពិត***

ទំព័រ ៥២

សូមគិតស្រមៃមបន្តិចថាមានអ្វីកើតឡើងប្រសិនបើ ព្យាការីពីបុរាណពុំបានគោរពប្រតិបត្តិដូចដែលពួកលោកបានធ្វើនោះ ។ សំណាងណាស់សម្រាប់ពួកយើង ដែលពួកលោកពុំបានអង្គុយនៅស្ងៀម ប៉ុន្តែពួកលោកបានធ្វើការ—ដូចជាវីរបុរសដ៏អស្ចារ្យ— ។ អ្នកក៏អាចធ្វើបានដែរ ។

## សម្រាប់កុមារ

### បុណ្យគ្រីស្ទម៉ាស់ដ៏ប្លែកមួយ

ទំព័រ ៦៤

ឌីអាហ្គោពុំដឹងថា បុណ្យគ្រីស្ទម៉ាស់ដែលគ្មានវត្តមានរបស់ម្ដាយគាត់នោះនឹងដូចមុនដែរឬទេ ប៉ុន្តែក្រោយមកគាត់មានយោបល់មួយ ដើម្បីជួយឲ្យបុណ្យគ្រីស្ទម៉ាស់ក្លាយជាគ្រាកាន់តែប្រសើរឡើងសម្រាប់មនុស្សដទៃទៀត !



CAMBODIAN
4 02132 92258 6

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ